# សិក្សាអំពីដើមកំណើតនៃអំណាចនៅស្រុកខ្មែរ

*ប្រសាទ ព្រហ្មបាយ័ន*



សរសេរដោយ ឧប សៅ សង្ហា -២២មិថុនា២០១៣

# មាតិការឿង


សេចក្ដីផ្ដើម ______ 1

ជំពូក ទី១ - អំណាចនៃរាជាធិបតេយ្យ ______ 9

ជំពូក ទី២ - រដ្ឋខ្មែរ ហើយនឹង ការរៀបចំក្នុងសម័យដើម ______ 41

ជំពូក ទី៣ - រដ្ឋខ្មែរ ហើយនឹងការរៀបចំអំណាចក្នុងសម័យអាណានិគមបារាំង ______ 64

សេចក្ដីសន្និដ្ឋាន ______ 85

# សេចក្ដីផ្ដើម

បើចង់សិក្សាអំពីដើមកំណើតនៃអំណាចនៅស្រុកខ្មែរ គឺចាំបាច់ត្រូវតែសិក្សាអំពីអំណាចនៃព្រះមហាក្សត្រខ្មែរ ពីព្រោះព្រះមហាក្សត្រខ្មែរជាអ្នកកាន់អំណាចដំបូងមុនគេបំផុត ហើយជាអច្ឆិន្ទ្រៃរហូតមកដល់ឆ្នាំ១៨៦៣ ដែលជាឆ្នាំដែលព្រះមហាក្សត្រខ្មែរដាក់ប្រទេសខ្លួនឲនៅក្រោមអាណាព្យាបាលប្រទេសបារាំង។ មុនពេលបង្កើត របបគ្រប់គ្រងអាស្រ័យរដ្ឋសភានៅស្រុកខ្មែរនាឆ្នាំ១៩៤៧ របបនយនស្រុកខ្មែរជារាជាធិបតេយ្យ។ ក្នុងរបបនេះគេទុកព្រះមហាក្សត្រជា អាទិទេពលើប្រថិពី ដែលជាអង្គម្ចាស់ជីវិតប្រកបដោយអនុភាព របស់ **អាណាប្រជានុរាស្ត្រ**[1] លក្ខណៈអាទិទេព របស់មហាក្សត្រមិនមែនថិតនៅត្រឹមតែជាជំនឿនោះឡើយ ពួកវា គេខំធ្វើយ៉ាងណាឲលក្ខណៈនេះមានភាពជាការពិតមួយសំរាប់ឲរាស្ត្រឃើញដើម្បីឲគោរពកោតខ្លាច ដូចយ៉ាងនៅក្នុងគ្រប់រាជពិធីជាផ្លូវការ នៅពេលដែលព្រះមហាក្សត្រ ព្រះអង្គយាងចេញធ្វើសាធារណសវនាការឬ យាងចេញធ្វើរាជដំណើរក្នុងរាជាណាចក្រ យោងតាមឯកសាររបស់ជនជាតិម្នាក់ឈ្មោះជីតាន់ ដែលបានម ធ្វើទស្សនាកិច្ចជាឯកជននៅស្រុកខ្មែរក្នុងសតវត្សទី១៤ បានសរសេរទុកថានៅពេលដែលអាណាប្រជានុរាស្ត្រ និងគ្រប់សព្វមុខមន្ត្រីរាជការ ឮសម្លេងស័ង្ខក្នុងរាជាពិធីក្ដី ឬក្នុងរាជក្បួនហែព្រះរាជាក្ដី ត្រូវនាំគ្នា**ប្រណំ**[2] លើកអញ្ជលីអោនក្បាល ឲថ្ងាដល់ដីរហូតលុះត្រាតែឈប់ឮសម្លេងស័ង្ខទើបអាចមានសិទ្ធិងើបមុខវិញបាន។ សភាគតិរាស្ត្របែបនេះ ដែលត្រូវតែមានជាចាំបាច់ចំពោះព្រះរាជាជាកាតព្វកិច្ចមួយដែលពួកវាំងគេបង្កើតឡើង សំរាប់ឲរាស្ត្រទទួលស្គាល់មហាក្សត្រខ្មែរជាអាទិទេព។

---

[1] អាណាប្រជានុរាស្ត្រ ឬរាស្ត្រ=Le peuple ; **les sujets**។

[2] ប្រណំ=se prosterner ;s’incliner។

ការទុក**ខេមរិន្ទ**[3] ជាអាទិទេពសំរាប់ធ្វើជា**ឆាយា**[4] នៃអំណាចផ្តាច់ការ ដោយព្រះមហាក្សត្រខ្លួនឯង និង**អមាត្យ**[5] គឺគេបាននាំគ្នាធ្វើឡើង ក្នុងគោលបំណងជា អនែក ឲអាណាប្រជានុរាស្ត្ររស់ក្រោមទិព្វបរមី ទទួលស្គាល់ជានិច្ចនៅក្នុងគំនិតនូវអំណាចផ្តាច់ការព្រះមហាក្សត្រ ហើយនាំគ្នាគាំទ្រនិងការពារដោយផ្ទាល់ ឬ មិនផ្ទាល់ក្តីដើម្បី ឲរបបរាជាធិបតេយ្យឲមានជីវិតជានិរន្តរ។ គេឃើញក្នុងសម័យអង្គរអាណាប្រជានុរាស្ត្រខ្មែរមានជំនឿជាអនែកលើគំនិត «ស្តេចអាទិទេព និង **ស្តេចមតកជន**»[6] ឬ «ប្រលឹងរបស់**ជិនក**»[7] ក្នុងគំនិតនេះ គេជឿថានៅពេលដែលព្រះមហាក្សត្រទ្រង់សោយទិវង្គត ប្រលឹងក្សត្រយាងចាកផែនដីព្រះអង្គទៅសោយរាជសម្បត្តិនៅ**ទេវនាគរី**[8] ជាថានព្រះឥសូរ វិស្ណុឬព្រះនិព្វានបន្តទៅទៀត ហេតុនេះឯងបានជាគេកសាងព្រះរាជចេតិយស្តេចមតកជនជា**ប្រតិរូប**[9] តាមជំនឿព្រហ្មញ្ញសាសនា ទុកដូចជាភ្នំសុមេរុថិននៅចំកណ្តាលសកលលោក។ ឥឡូវ ជំនឿនេះវារំសាយទៅហើយ ប៉ុន្តែវាសណ្ឋិតក្នុងគំនិតប្រជាពលរដ្ឋខ្មែរជាអនុស្សាវរីយ៍មួយដែលឥតអាចបំភ្លេចបានឡើយ ដូច្នេះប្រជាពលរដ្ឋខ្មែរ នៅតែមានអារម្មណ៍ជានិច្ចថាព្រះមហាក្សត្រជាសូរវង្សអាទិទេព អារម្មណ៍នេះឯងដែលនាំ ឲអំណាចផ្តាច់ការបន្តត្រកូលរបស់ព្រះមហាក្សត្រ ក្នុងចិត្តគំនិតខ្មែរ ថាជាអំណាចស្របច្បាប់ធម្មជាតិផងនិង ជាអំណាចជាធម្មានរូបផង។

ចំណេរកាលតៗមក គេសង្កេតឃើញថា **ទិព្វរាជ្យ**[10] ខ្មែររលាយអត្តរសខ្លួន ដោយខ្លួនឯងបន្តិចម្តងៗ នៅសល់ត្រឹមតែជាកំណត់ដែលគេបានចារទុកក្នុងប្រវត្តិសាស្ត្រជាតិតែប៉ុណ្ណោះ។ បន្តមកទៀត នៅថ្ងៃដែលស្តេចសីហនុទី១ប្រកាសរដ្ឋធម្មនុញ្ញខ្មែរជាដំបូងនាឆ្នាំ១៩៤៧ នៅពេលនោះរបបរាជាធិបតេយ្យ ដែលជាគូនិងទិព្វរា

---

[3] ខេមរិន្ទ=Indra khmer ;Titre qu’on donne parfois au roi khmer។
[4] ឆាយា=Ombre ; ម្លប់។
[5] អមាត្យ=Conseillers du roi ;Ministres។
[6] ស្តេចមតកជន=Rois- Défunts។
[7]ជិនក=Aïeul ;Ancêtre )ជិនីសំរាប់ប្រើចំណោះភេទស្រី) គេអាចប្រើថាជាបិតារបស់ព្រមហាក្សត្យក៏បាន។
[8]ទេវនាគរី=Cité des dieux។
[9]ប្រតិរូប=Reproduction។
[10]ទិព្វរាជ្យ=Royauté divine។

ជ្សុក៏រំលាយខ្លួនដោយអនុលោមតាមឧត្តមច្បាប់ជាតិ ក្នុងនោះមានចែងច្បាស់ថា ប្រជាពលរដ្ឋខ្មែរជាអធិបតីនៅក្នុងប្រទេសរបស់ខ្លួន។

យើងឃើញថាអស់រយៈពេលដ៏យូរអង្វែងមួយ ប្រជាពលរដ្ឋខ្មែរ គាត់បានរស់នៅក្នុងឋានៈជា អាណាប្រជានុរាស្ត្ររបស់ព្រះមហាក្សត្រ គាត់ឥតដែលបានស្គាល់អ្វីដែលហៅថា សិទ្ធិមនុស្ស សិទ្ធិប្រជាជន សេរីភាពជាសរវន្តរបស់បុគ្គល ជាពិសេសគាត់មិនដែល**ពិលាប**11) អំពីសណ្ឋាននៃជីវិតរបស់គាត់នោះឡើយ ព្រោះគាត់យល់ឃើញថា ការទាំងនេះជា**ក្រិត្យ**12 របស់រាស្ត្រម្នាក់ៗ។

អវត្តមាននៃ**អភិញ្ញាណ**13 នេះនាំឲប្រជាពលរដ្ឋខ្មែររស់ក្នុង**លោកន្តរ**14 ទុកទិព្វរាជ្យ ជាធម៌តែមួយគត់ សំរាប់ជីវិតរស់នៅរបស់ខ្លួន ដែលមានគោលការណ៏ដូចជា សេវភាព ការស្មោះត្រង់ និង ពលិកម្ម ចំពោះព្រះមហាក្សត្រដើម្បីសេរិយសព្រះអង្គ ដែលជាម្ចាស់ជីវិតលើត្បូង គឺថាក្បាលរបស់អាណាប្រជានុរាស្ត្រត្រូវចាំបាច់ថិតនៅក្រោមល្អងធូលីព្រះបាទាព្រះមហាក្សត្រ ដើម្បីព្រះអង្គជាន់លើជាអាធារ សំរាប់ឲខ្លួនក្លាយទៅជានរោត្តម ។

ជា សេវភាព ការស្មោះត្រង់ និង ពលិកម្ម ចំពោះព្រះមហាក្សត្រដើម្បីសេរិយសព្រះអង្គ ដែលជាម្ចាស់ជីវិតលើត្បូង គឺថាក្បាលរបស់អាណាប្រជានុរាស្ត្រត្រូវចាំបាច់ថិតនៅក្រោមល្អងធូលីព្រះបាទាព្រះមហាក្សត្រ ដើម្បី ព្រះអង្គជាន់លើជាអាធារ[15] សំរាប់ ឲខ្លួនក្លាយទៅជា**នរោត្តម**16។

ការទំនាក់ទំនងស្ដេចនិងរាស្ត្របែបនេះ នាំឲគេចោទជាសំណួរថាតើគារវៈរបស់រាស្ត្រចំពោះស្ដេច មានវិស្សសភាពពិតមែនដែរឬទែ? គួរយើងលើកយកគោលការ

---

[11]ពិលាប=se plaindre។
[12]ក្រិត្យ=Obligation morale។
[13]អភិញ្ញា= Connaissance។
[14]លោកន្តរ=Monde des ténèbres។ឋាននរកងងឹតសូន្យ។
[15] អាធារ= Support។
[16] នរោត្តម=Plus élevé des hommes។

ណ៏របបរាជាធិបតេយ្យនៅបណ្តាបស្ចិមប្រទេស នាយុគកណ្តាល (សតវត្សទី៥ដល់ទី១៥)មកពិនិត្យមើលដែរ ដើម្បីធ្វើការប្រៀបធៀបខ្លះនឹងរបបរាជានិយមសក្តិភូមិខ្មែរ ថាតើវាមានគោលការណ៏ដូចគ្នាដែរឬទេ?

តាមការសិក្សាលោក Montesquieu17 ដែលយើងលើកយកមករៀបរាប់ដូចខាងក្រោមនេះគឺ៖

«*របបរាជាធិបតេយ្យ សន្មត់ថាមាន វណ្ណៈខ្ពង់ខ្ពស់មួយ ក្នុងសង្គមដែលមានកំណើតពីជម្មជាតិហើយវណ្ណៈនេះ មានគោលការណ៏របស់គេគឺ"**កិត្តិយស**"របស់វណ្ណៈ។ កិត្តិយសនេះជាកម្លាំងថាមវ័ន្តនៃគ្រប់អង្គការនយោបាយរបស់របបផ្ញើសហរិយកម្មក្នុងជំនឿរួមថាអ្វីដែលគេកំពុងធ្វើគឺដើម្បីស្វែងរកសាធារណប្រយោជន៏ផង និង ប្រយោជន៏ឯកជនផង។ តាមពិតកិត្តិយសក្នុងទស្សនៈបែបនេះ ជាកិត្តិយសមិនពិតនោះឡើយ ព្រោះថាការិយកម្មរបស់ខ្លួនគឺធ្វើឡើងសំរាប់តែបំរើតែប្រយោជន៏ឯកជនតែប៉ុណ្ណោះ ដូចយ៉ាង របបរាជាធិបតេយ្យ គេបង្ខំឲអាណាប្រជានុរាស្ត្រធ្វើកិច្ចការធ្ងន់ធ្ងរបំផុត គ្មានរង្វាន់ ដោយសំអាងថាកិច្ចការនេះ ជាពលិកម្ម សំរាប់ប្រយោជន៏ជាតិតែការពិតពាក្យប្រយោជន៏ជាតិនេះគ្រាន់តែជាពាក្យពាក្យឃោសនាតែប៉ុណ្ណោះ*»

ក្នុងចំណុចនេះនាំឲយើងលើកយកការកសាងប្រាង្គប្រាសាទជាច្រើន ដែលស្តេចខ្មែរកសាងឡើងនៅក្នុងសម័តដើម សួរជាសំណួរថា តើការកសាងនេះ ធ្វើឡើងសំរាប់សាធារណប្រយោជន៏ពិតដែរឬទេ? បើខ្មែរបច្ចុប្បន្នយល់ឃើញថាប្រាសាទទាំងនោះជាមោទនភាពជាតិ ត្រូវខ្មែរគិតពិចារណាឲច្បាស់ថាក្នុងមោទនភាពនេះ អ្វីខ្លះដែលអាចចាត់ទុកថាជាប្រយោជន៏សំរាប់ប្រជាពលរដ្ឋ ជាពិសេសក្នុងបច្ចុប្បន្ននេះ គាត់កំពុងរស់ក្នុងភាពក្រីក្រជាទីបំផុ។ ក្នុងសម័យដើម ដូចលោកម៉ុងទេសគៀបានសរសេរដូចខាងលើនេះ រាស្ត្រខ្មែរបានត្រូវរបបរាជាធិបតេយ្យកែន ឲ

[17]De l'esprit des lois។

គាត់ចោលស្រែចំការ ចោលគ្រួសារ មកកសាងប្រាសាទដើម្បីសេចក្តីថ្កុំថ្កើងរបបតែពួកវាំង្គ គេពន្យល់រាស្ត្រថា ពលិកម្មឥតរង្វាន់នេះជាប្រយោជន៍ជាតិខ្មែរ ដែលមានខ្លួនជាម្ចាស់ ដូច្នេះប្រយោជន៍ដែលមានម្ចាស់នេះ គឺជាប្រយោជន៍ **ខត្តិយះ**[18] ឬ ប្រយោជន៍ឯកជនតែប៉ុណ្ណោះ។ ដូច្នេះមោទនភាពរបស់ខ្មែរមិនត្រូវយកស្តេចជាប្រតិមានោះឡើយ មោទនភាពពិតគឺសេចក្តីចេះដឹងខ្មែរក្នុងផ្នែកសំណង និងការប៉ិនប្រសប់ខ្មែរក្នុងវិស័យវិចិត្យសិល្បៈ ប៉ុន្តែខ្មែរយើងត្រូវចងចាំក្នុងគំនិតជានិច្ចថាក្នុងស្ថាបនកម្មនោះ មានខ្មែររាប់ម៉ឺននាក់ ដែលគេកែនមកធ្វើជាកម្មករជាពលស្តេច ធ្វើការងារដ៏ធ្ងន់ធ្ងរក្នុងឋានៈជាទាសៈដើម្បីបំរើប្រយោជន៍វណ្ណៈស្តេច។ កម្មករ និងអ្នកបច្ចេកទេសគ្រប់វិស័យសំណង់ទាំងនោះឯងហើយ ដែលយើងត្រូវទុកគាត់ជាវិរបុរសជាតិខ្មែរ ដែលជាមោទនភាពខ្មែរពិត។

ខ្មែរយើងត្រូវដឹងថារាប់សហស្សវត្សមកហើយ រាស្ត្រខ្មែររស់ក្នុង**កាលធម៌**[19] ដ៏ស្រងេះស្រងោចមួយ ភាពនោះត្រូវបាន លោកបណ្ឌិត**កេងវ៉ាន់សាក់** លោកយកមកតែងជាកំណាព្យមួយគួរឲស្រណោះដល់វាសនារាស្ត្រខ្មែរក្នុង**ជគត**[20] យើងនេះ ដែលមានសេចក្តីដូចខាងក្រោមនេះ៖

*កើតតាមយំ ធំតាមឃ្លាន មានតែក្រ។*

*ឈើកំដរ គទល់ស្លាប់ ចាប់វាសនា។*

*រស់ជាខ្ញុំក្រុមដេកស៊ី ដោយរាជការ។*

*ពួកអាត្មាអារកខ្មែរ រាស្ត្រស្នេហាជាតិ។*

រហូតមកដល់បច្ចុប្បន្ននេះ យើងឃើញច្បាស់ណាស់ថា របបរាជាធិបតេយ្យនៅស្រុកខ្មែរទោះបីក្លាយខ្លួនជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញក៏ដោយ តែនៅខំរស់

[18] ខត្តិយះ=Noble ;guerrier de la caste de la lignée royale។
[19] កាលធម៌=La loi du destin។
[20]ជគត=Monde ;Terre ; ce monde=ជគតយើងនេះ។

នៅក្នុងអំណាចផ្តាច់ការដែលជាគូជាគុដើមនឹងទិព្វរាជ្យរបស់ខ្លួន ចូលដៃនឹងក្រុមចោរប្លន់បំរើយួនកុម្មុយនិស្ត ធ្វើនយោបាយក្នុងពុតអាក្រក់ ដោយប្រើប្រជាភិថុតិបំភាន់គំនិតរាស្ត្រខ្មែរថា ស្តេចសីហនុជាបីតាឯករាជ្យផង និងសន្តិភាពផង ដែលពួកគេនាំគ្នាឃោសនាថាស្នាដៃនេះឯងជាប្រយោជន៍ខ្មែរ តែការពិតយើងឃើញជាក់ច្បាស់ថា ឯករាជ្យជាតិខ្មែរបច្ចុប្បន្ននេះ ជាឯករាជ្យនៅក្រោមអំណាចយួនកុម្មុយនិស្ត ឯចំណែកសន្តិភាពវិញ គឺជាសន្តិភាពសំរាប់ជនជាតិយួនចូលមករស់ក្នុងទឹកដីខ្មែរដោយសេរី និងអនាធិបតេយ្យ។ឯករាជ្យ និងសន្តិភាពពិតអាចមានបានលុះត្រាតែនៅស្រុកខ្មែរ រាស្ត្រមានសេរីភាព មានសុវត្ថិភាព រស់ជាប្រជាពលរដ្ឋថ្លៃថ្នូរហើយជាម្ចាស់របស់ជាតិ។ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញបច្ចុប្បន្ននេះ ជារបប**ចោរម័ទ**[21] ផង ផ្តាច់ការផង និងរណបយួនផង ធាតុទាំងបីយ៉ាងនេះ **បោរាណ**[22] ខ្មែរយើង លោកមានជំនឿថា បីចង្រៃស្លាប់ «គ្រប់មេគ្រប់ពង» សូត្របីដង ផ្លុំបីដង ព្រួសបីដង បាចបីដង ចងបីដង ពាត់បីដង។ល។ ជាក្បួនសំលាប់បំបាត់ ដេញបន្សាប (វៃបីដង)។ល។

**ច្បាប់ត្រីនេតិ៖**

*នាសតិរាជា នឹងក្សីណក្សត្រា ពុំលែងឡើយហោង។*

*បីៗអសារ បីៗឥតការ បីៗសូន្យសោះ។*

*បីៗហីនហោច បីៗត្រមោច បីៗសាធារណ៍។*

*ម្តេចហៅហីនហោច ត្រមោចឥតការ ម្តេចហៅសាធារណ៍។*

*នាហៅសាធារណ៍ មានព្រៀងឥតការ បំបែកកិច្ចកល។*

*បីៗសាមាន្យ បីអន្តរធាន បីៗអាស្រូវ។*

---

[21] របបចោរម័ទ)របបនយោបាយពុករលួយ=Kleptocratie(
[22] បោរាណ= ចាស់ទុំ។

*នាហៅសាមាន្យ សង់ផ្ទះនាស្ថាន ទៀបផ្សារពុំជា។*

*គប់នូវអ្នកពាល សាធារណ៍មោហា។*

(ដកស្រង់ពីឯកសារលោក កេង វ៉ាន់ សាក់)

នោះបីរបបរាជានិយមខ្មែរខំបង្ហាញថាមហាក្សត្រខ្មែរ គេច្រើសតាំងឡើងតាមនិតិវិធីនៃលទ្ធិប្រជាធិបតេយ្យ គឺការបោះឆ្នោតក៏ដោយ តែអ្នកមានសិទ្ធបោះឆ្នោតគឺជាមនុស្សមួយចំនួនតូច មានវណ្ណៈឧត្តមៈ ជ្រើសរើសតាំងស្តេចតាមរបៀប**ការជ្រើសតាំងសមាជិកដោយខ្លួនឯង**[23] គ្មាន**បទដ្ឋានគតិយុត្ត**[24] សំរាប់ឲដឹងអំពី**លក្ខណវិនិច្ឆ័យ**[25] នៃជម្រើសរបស់ក្រុមអ្នកមានសិទ្ធបោះឆ្នោត។ ឧទាហរណ៍ដូចយ៉ាងជម្រើសស្តេចសីហមុនីជាមហាក្សត្រ រាស្ត្រខ្មែរឥតដឹងអ្វីបន្តិចសោះអំពីលក្ខណវិនិច្ឆ័យ របស់ក្រុមប្រឹក្សារាជ្យសម្បត្តិ ការធ្វើបែបនេះហាក់បីដូចជាគ្មានតម្លៃអ្វីសំរាប់រាស្ត្រឲគាត់ទុកស្តេចជ្រើសបែបនេះជាឧត្តមបុគ្គល ជាសភាជន សំរាប់ជាតិខ្មែរ។ ក្នុងជម្រើសគ្មានបទដ្ឋានគតិយុត្ត ដែលតម្រូវឲស្តេចសីហមុនីគោរពកោតខ្លាច និង អស់គុណអស់មួយជីវិត ចំពោះសមាជិកក្រុមប្រឹក្សារាជ្យសម្បត្តិបច្ចុប្បន្ន ដែលរាស្ត្រខ្មែរដឹងច្បាស់ថាសុទ្ធជាចោរប្លន់ជាតិ និងក្បត់សាសនា។ ក្នុងសណ្ឋានបែបនេះខ្មែរយើងអាចសួរថា តើស្តេចសីហមុនីជាព្រះរាជាបែបណាទៅ បើអ្នកជ្រើសរើសតាំងព្រះអង្គសុទ្ធជា**ទុរាចារ**[26] ជន ? តើប្រជាពលរដ្ឋខ្មែរអាចគោរពព្រះអង្គជាមហាក្សត្រមានសក្ការៈបានដោយស្មោះដែរឬទេ? ភាពគ្មានតម្លៃសោះ នៃរបបរាជានិយមបច្ចុប្បន្នមានជាក់ស្តែងបើយើងយោងទៅតាមសេចក្តីថ្លែងការណ៍ របស់ទ្រង់រណឫទ្ធិថ្មីនេះ ថាទ្រង់មិនធ្វើនយោបាយ ឬ មិនចូលគណបក្សសង្គ្រោះជាតិទេ ព្រោះលោកហ៊ុនសែន បានស្បថចំពោះមុខសពបីតាទ្រង់ថាមិនរំលាយរបបរាជានិយមទេ ដូច្នេះទ្រង់បានធ្វើអនុសាសន៍ឲព្រះរាជវង្ស

---

[23]ការជ្រើសតាំងសមាជិកដោយខ្លួនឯង=Cooptation។
[24] បទដ្ឋានគតិយុត្ត=Règle de droit។
[25]លក្ខណវិនិច្ឆ័យ=Critère។
[26]ទុរាចារ=Mauvais conduite។

នុវង្សកុំចូលធ្វើនយោបាយ ព្រោះរបបរាជានិយមមានអ្នកធានាការពារឲរស់បានទៅមុខទៀត។ រឿងធ្វើអនុសាសន៍ មិនឲព្រះរាជវង្សានុវង្ស ធ្វើនយោបាយជាការមួយល្អហើយ តែនិយាយកំភែលថា អាយុជីវិតរបបរាជានិយម នៅក្នុងកណ្តាប់ដៃ ហ៊ុន សែន ជាការប្រមាថដោយខ្លួនឯងនូវរបបរាជានិយម ដែលពួកស្តេចខ្លួនឯង មានជំនឿថា ជាស្ថាប័នសហស្សវត្ស ដែលមានការគាំទ្រដោយស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋខ្មែរ។សំដីកំភែលបែបនេះក៏បង្ហាញឲឃើញភាពផ្ទុយស្រឡះពីធាតុទុរពលរបស់របបរាចានិយមបច្ចុប្បន្ននឹង **សពាសងស្ការ**27 ជាសេរីយសនៃស្តេចសីហនុ ដែលទ្រង់រណឬទ្ធិទុកសពបីតាទ្រង់ជារាជហរិវង្ស។ បើទ្រង់ រណឬទ្ធិទុកលោក ហ៊ុន សែន ជាម្ចាស់ ជីវិតរបបរាជានិយម តើរបបនេះ វាថោកទាបបែបណាទៅ ?

---

[27] សពាសងស្ការ= បុណ្យសព។

# ជំពូក ទី១ - អំណាចនៃរាជាធិបតេយ្យ

## អត្ថរសនៃអំណាច គ្រឹះនៃអំណាច វិធាននៃអំណាច

នៅក្នុងនិក្ខេបបទ លោក **ជួន ជុំ**[28] លោកបានសរសេរថា ដើម្បីស្រួលយល់ដឹងអំពីអំណាចរាជាធិបតេយ្យនៅស្រុកខ្មែរ គេត្រូវសិក្សាអំណាចតាមការវិវឌ្ឍន៍នៃជំនឿនៅស្រុកខ្មែរ ពី «**ជំនឿលើធម្មជាតិ**»[29] មកដល់ជំនឿលើពុទ្ធសាសនា។ ការវិវឌ្ឍន៍អំណាចព្រះរាជានេះមានបីដំណាក់៖

១. ព្រះមហាក្សត្រជា **អាណត្តិគហក**[30] នៃព្រះធរណី។

២. ព្រះមហាក្សត្រជាអាណត្តិគហក នៃ **ច្បាប់លោកធាតុ**[31] និង ព្រាហ្មណិកធម៌។

៣. ព្រះមហាក្សត្រជាអាណត្តិគហកនៃច្បាប់លោកធាតុ និង ពុទ្ធកធម៌។

យើងយកការសិក្សាលោក ជួន ជុំ មកពិចារណា ព្រោះយើងយល់ឃើញថា ជាការសិក្សាវិទ្យាសាស្ត្រនយោបាយខ្មែរដោយកូនខ្មែរមុនគេ ហើយគួរឲចាប់អារម្មណ៍ ដើម្បីឲកូនខ្មែរយើងដឹងអំពីធាតុពិតនៃអំណាចរបស់ព្រះរាជាខ្លួន។ ការពិចារណារបស់យើងលើការសិក្សាលោក ជួន ជុំ គឺដើម្បីបន្ត រកធាតុអំណាចនៅស្រុកខ្មែរ ឥទ្ធិពល របស់វាមកលើការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដែលយើងដឹងច្បាស់ណាស់ថានាបច្ចុប្បន្ននេះនៅកំពុងរស់ក្នុងអំណាចផ្តាច់ការដ៏សាហាវមួយ ព្រោះវាអាចបំផ្លាញជាតិឲបាត់រលាយសូន្យនៅក្នុងអនាគតកាលដ៏ខ្លីមួយ។ ដូច លោក Montesquieu លោកបានសរសេរថា គោលការណ៍អំណាចផ្តាច់ការ គឺដឹកនាំជាតិ

[28] Le pouvoir monarchique au Cambodge-1952។
[29] ជំនឿលើធម្មជាតិ=Animisme។
[30] អាណត្តិគាហក=Mandataire។
[31]ច្បាប់លោកធាតុ=Ordre du cosmo។

ដោយយក **សង្កា**32 ជាមធ្យោបាយដឹកនាំ ធ្វើឲរាស្ត្រខ្លាចអំណាច ដូចខ្លាចខ្មោចបីសាច តាមធ្វើ**បាណាតិបាត**33 មនុស្សលោក ឲវិនាសអន្តរាយ។

និក្ខេបបទលោក ជួន ជុំ ជាឯកសារ សរសេរជាភាសារបារាំង ដែលជាជញ្ជាំងជាំងនៃការចេះដឹងរបស់លោក ពីរាស្ត្រសាមញ្ញខ្មែរ ហេតុនេះឯងបានជាយើងយកស្នាដៃសំខាន់នេះមកពិចារណា ហើយធ្វើចរន្តការ ក្នុងភាសាជាតិដើម្បីទុកជូនខ្មែរគ្រប់ប្រភេទ អាចមានលទ្ធភាព យកវាមកធ្វើជាប្រធាន នៃការពិភាក្សាខាងនយោបាយ ឲយល់អំពីទម្ងន់នៃអំណាចផ្តាច់ការ ដែលវាបានសង្កត់លើប្រជារាស្ត្រខ្មែរជានិច្ចកាល នាំឲរាស្ត្រខ្មែររស់ក្នុងភាពជាអ្នកឈឺចាប់គពូជ។ ដូច្នេះ យើងសួរថា តើរាស្ត្រខ្មែរ ពីជំនាន់មួយទៅជំនាន់មួយគាត់នៅមានសល់ថាមពលឯណាដើម្បីធ្វើសក្ការៈដល់ព្រះរាជា ឬ អ្នកដឹកនាំខ្លួន ដូចពាក្យកុហកថា គាត់ស្រឡាញ់ស្តេច ឬ អ្នកដឹកនាំដូចបីតារបស់គាត់ ?

## ផ្នែកទី១

## ព្រះមហាក្សត្រជាអាណាព្ហតមហកនៃព្រះធរណី

ជំនឿលើធម្មជាតិ គេឃើញមាននៅក្នុង **ក្រមក្សេត្រាជីវកម្មខ្មែរ**34 ដែលមានឈ្មោះថា «ក្រមព្រះឧកញ្ញាទេព» ក្នុងនោះមានចែងជាក្បួននិងវិធីការសំរាប់បន់ស្រន់ដល់ព្រលឹងដែលមាននៅក្នុងធម្មជាតិ ដើម្បីឲព្រលឹងនោះ ជួយថែរក្សា និងទាញយកប្រយោជន៍ពីវាសំរាប់សេចក្តីសុខរបស់ខ្លួន។ មុនពេលប្រជាពលរដ្ឋខ្មែរបានទទួលឥទ្ធពលអរិយធម៌ឥណ្ឌា ខ្មែរយើងមានជំនឿលើធម្មជាតិ ដូចយ៉ាងព្រៃ ដើមឈើ ទន្លេ ស្ទឹង ស្រះ ត្រពាំង។ល។ សុទ្ធជាវត្ថុមានព្រលឹងសណ្ឋិតនៅ។ ព្រលឹង

32 សង្កា= សេចក្តីខ្លាច ; Crainte។
33 បាណាតិបាត= ព្យាបាទ។
34 ក្រមក្សេត្រជីវកម្ម=Code rural khmer។

នេះ រស់ក្នុងជិបលោក ឥតរូប ជាមួយនឹងមនុស្សលោក មានទំនាក់ទំនងរវាងគ្នានឹងគ្នា ក្នុងជីវិតរស់នៅជាធម្មតារបស់មនុស្ស នៅពេលណាមនុស្សធ្វើអំពើអ្វីមួយខុសឆ្គងដល់ព្រលឹងណាមួយ ព្រលឹងនោះវាធ្វើបាតុកម្មក ម្ខាត់កម្ខាយ អ្នកធ្វើនោះឲវិនាស តាមជម្ងឺក្តី ធ្វើឲស័យជានិច្ច និង គ្រប់វិធីណាដែលអាចឲអ្នកធ្វើនោះឥតអាចរស់នៅបានជាសុវត្ថភាព។ បើចង់ចាកចេញផុតពីទណ្ឌកម្មរបស់ព្រលឹងនោះ ត្រូវអ្នកទទួលទុក្ខនោះ ធ្វើពិធីសែនសូមទោសដល់ព្រលឹងដែលខ្លួនបានធ្វើខុសឆ្គងទៅលើគេ។ ឧទាហរណ៍មួយគួរឲកត់សំគាល់ក្នុងជំនឿលើធម្មជាតិដែលមានចែងក្នុងក្រម ព្រះឧកញ្ញាទេព ដែលមានសេចក្តីដូចតទៅៈ

*«ក្របីណាដែលមកស្លាប់នៅលើស្រែចំការអ្នកដ៏ទៃ ម្ចាស់ក្របីនោះត្រូវទទួលខុសត្រូវតាមក្រមព្រហ្មទណ្ឌផង និង ក្រមរដ្ឋប្បវេណីផង បើប្រសិនម្ចាស់ក្របីនោះមិនធ្វើពិធីសែនដើម្បីសូមទោសដល់ព្រលឹងដែលសណ្ឋិតនៅក្នុងស្រែចំការនោះ ពិធីសែន ធ្វើឡើងដើម្បីឲម្ចាស់ស្រែចំការ ចាកផុតពី ទោមមនស្ស នៃព្រលឹងនោះមកលើរូបគេ»*។

ជំនឿបែបនេះមានច្រើនជាអនែក ដូចយ៉ាងការគោរពទេព្តាដី ព្រោះខ្មែរយល់ឃើញថាដីជាមូលដ្ឋានផ្តល់នូវស្រូវអង្ករជាអាហារសំខាន់ ដូច្នេះរៀងរាល់ឆ្នាំ ព្រះរាជាខ្មែរធ្វើពិធីរំលឹកគុណដល់ព្រះធរណី បួងសួងសូមទេព្តាដីជួយណែនាំរាស្ត្រឲបានដឹងអំពីផលនឹងអាចមានបានក្នុងរដូវធ្វើស្រែចំការសម្រាប់ឆ្នាំថ្មី។ ទំនៀមទម្លាប់នេះគឺពិធីច្រត់ព្រះនង្គ័ល បើករដូវធ្វើស្រែនោះឯង។

វិទូប្រវត្តិសាស្ត្រល្បីជាច្រើន ដូចជា លោក Sylvain Lévi, Przyluski Granet, Paul Mus, G. Coedès បានបញ្ជាក់ក្នុងការសិក្សារបស់គាត់ថា នៅស្រុកខ្មែរ និង ស្រុកចំប៉ាថា ប្រជាពលរដ្ឋដើម មានជំនឿ លើព្រះធរណីនេះ មុនខ្លួនបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា។ ជំនឿនេះ មិនត្រឹមតែមាននៅក្នុងស្រុកខ្មែរ និង ចំប៉ានោះទេ គេឃើញមាននៅក្នុងដំបន់អាស៊ីអគ្នេយ៍ ដូចយ៉ាងនៅប្រទេសឥណ្ឌូណេស៊ី វៀតណាម លាវ និង នៅប្រទេសចិនខាងត្បូងដែរ។

និមិត្តរូបនៃព្រះធរណី គឺជាថ្ម ដែលគេតាំងថ្មនោះក្នុងផ្ទៃដីមួយ ថ្មនោះអាចមានឫទ្ធិធ្វើឲធ្លាក់ភ្លៀង និងឲមាន **ពាហុផលភាព**35 លើកផ្ទៃដី ដែលគេតាំងខ្លួននៅទីនោះ។ បើនិយាយឲខ្លី ថ្មនោះ ជាព្រះ ជាទីកន្លែង ដែលគេតាំងខ្លួនតែម្តង។តាមទស្សនៈ លោក Paul Mus ជំនឿលើ **ព្រះសិលា**36 ជាបុព្វជំនឿ នៃជំនឿលើ **បដិមាករលិង្គព្រះឥសូរ** ដែលជាជំនឿសំខាន់មួយ របស់ព្រះវង្សានិវង្សមហាក្សត្រខ្មែរនៅសម័យអង្គរទោះបីព្រះរាជា ជាអ្នកកាន់ព្រហ្មញ្ញសាសនាក្តី អ្នកកាន់ពុទ្ធសាសនាក្តី។

ចំណេរកាលតៗមក រហូតមកដល់បច្ចុប្បន្នកាល ជំនឿលើព្រះសិលា បានក្លាយជាជំនឿលើអ្នកតា ជំនឿនេះ យើងអាចទុកជាជំនឿជាតិខ្មែរបាន ព្រោះនៅក្នុងស្រុកខ្មែរទាំងមូល គេឃើញមានខ្ទមអ្នកតា ពាសពេញភូមិស្រុក ហើយពិធីសែនអ្នកតា ត្រូវអ្នកស្រែចំការ ធ្វើឡើងរៀងរាល់ឆ្នាំ ដើម្បីឲដីចំការរបស់ខ្លួន មានពហុផលភាព សំរាប់ចិញ្ចឹមជីវិតគ្រួសារ។

ជំនឿលើអ្នកតារបស់ប្រជាពលរដ្ឋខ្មែរ មានលក្ខណៈ ពីរយ៉ាងៈ

១. ជាការសំម្តែងគំនិត នៃថាមពលធរណី ដែល ដីឃុំ ស្រុក ខេត្ត មានពហុផលភាព មានវិបុលភាព ដោយសារអ្នកតាប្រចាំឃុំ ស្រុក ខេត្តនិមួយៗនោះឯង។ ហេតុនេះឯង រៀងរាល់ឆ្នាំអ្នកស្រុក នាំគ្នាធ្វើពិធីសែន ដែលគេហៅថាបុណ្យលើកអ្នកតា ដើម្បីសូមសេចក្តីសុខ និង សេចក្តីចំរើនពីព្រះធរណីនេះ។

២. ជាការសំដែងគំនិត នៃការទុកអ្នកតាជាទីកន្លែងតែម្តង ដោយយក ព្រឹត្តិការណ៍ប្រវត្តិសាស្រ្ត និង អនុស្សាវរីយ៍ របស់ អ្នកស្រុកនៅទីកន្លែងនោះ មកបញ្ជាក់ថាជំនឿនេះគឺជាការពិត ដូចយ៉ាង អ្នកស្រុកនៅខេត្តពោធិសាត់ ទុកអ្នកតាឃ្លាំងមឿងជាខេត្តពោធិសាត់តែម្តង។ ដើមដំបូងនៃជំនឿនេះគឺ ក្នុងសតវត្សទី១៦ មានមេទ័ពខ្មែរម្នាក់ឈ្មោះឧកញ្ញាឃ្លាំងមឿង លោកសុខចិត្តបូជាជីវិតលោកខ្លួន

---

35ពាហុផលភាព=Fécondité។
36 ព្រះសិលា=La pierre-dieu។

ឯងដើម្បីការពារ **ពញាចន្ទ** ដែលជាប់ក្នុងបន្ទាយជ័យ ពីការឡោមព័ទ្ធរបស់កងទ័ពស្តេចកន។ ការបូជាជីវិតដោយខ្លួនឯងរបស់ឧកញ្ញាឃ្លាំងមឿង ចៅហ្វាយខេត្តពោធិសាត់ មានគោលបំណង ទៅកែនទ័ពខ្មោច ឲមកជួយវាយរំដោះ ពញាអង្គចន្ទ ពីការឡោមព័ទ្ធរបស់សត្រូវ[37] ចំណេរកាលតៗមក អ្នកស្រុកនៅខេត្តពោធិសាត់ ក៏នាំគ្នាជឿថា ព្រលឹងខ្មោច ឧកញ្ញាឃ្លាំងមឿង ក្លាយទៅជាអ្នកតារក្សាទឹកដីខេត្តពោធិសាត់ ហើយមកដល់បច្ចុប្បន្នកាល រាល់ខែមេសា គ្រប់មន្ត្រីប្រចាំខេត្តពោធិសាត់ និង អ្នកស្រុកនាំ គេគ្នាធ្វើពិធីបន់ស្រន់ដល់អ្នកតាឃ្លាំងមឿង ដើម្បីសូមសេចក្តីសុខសប្បាយពីម្ចាស់ទឹកដី។

ជំនឿបែបនេះ គេឃើញមានដែរនៅស្រុកត្បូងឃ្មុំ នៅក្នុងខេត្តកំពង់ចាម គ្រប់ចៅហ្វាយស្រុកថ្មី ត្រូវតែធ្វើពិធីបន់ស្រន់ដល់អ្នកតា អជូន នៅភូមិអជូន ដែលជាម្ចាស់ទឹកដីទីនោះ ដើម្បីសូមសេចក្តីសុខ។ ត្រូវដឹងថា អជូនជាអតីតចៅហ្វាយខេត្តត្បូងឃ្មុំ ក្នុងសតវត្សទី១៦ ដែលព្រះរាជា កាត់ទោសប្រហារជីវិត ពីបទធ្វើឃាតកម្ម ដោយចេតនា បំពានអាជ្ញាស្តេច លើបុគ្គលទុំ។ ចំណេរកាលតៗមក អ្នកស្រុកត្បូងឃ្មុំ មានជំនឿថា ព្រលឹង អជូន ក្លាយជាអ្នកតារក្សាទឹកដី ហើយនាំគ្នាធ្វើការបន់ស្រន់ ដើម្បីសូមសេចក្តីសុខ។ រឿងអជូននេះ ខ្មែរយើងភាគច្រើនដឹងច្បាស់ ដោយសារមាន អ្នកនិពន្ធខ្មែរម្នាក់ បានដកស្រង់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះមកតែងជា ប្រឡោមលោក ដ៏ល្បី ដែលមានចំណងជើងថា«រឿងទុំទាវ» ឬ ទាវឯក។

ជំនឿខ្មែរដើមនេះឯងហើយ ដែលព្រះបាទជ័យវរ្ម័នទី២(គ.ស.៨០២-៨៥០) ក្រោយពីបានរំដោះស្រុកខ្មែរពីប្រទេសជ្វា ឲមានឥស្សរភាព និង បង្រួបបង្រួម ឲមានឯកភាពឡើងវិញ នៅលើភ្នំគូលេន ព្រះអង្គបាន ប្រារព្ធធ្វើពិធីមួយជាមួយបុរោហិតព្រះអង្គ ឈ្មោះព្រាហ្មណ៍ សិវកៃវល្យ មានជំនួយពីព្រាហ្មណ៍ម្នាក់ទៀត ជាពិធី

---

[37]ដកស្រង់ពីឯកសារលោកអេងសុត មហាបុរសខ្មែរ ដកស្រង់ពីព្រះរាជពង្សាវតាខ្មែរ។

ករ ឈ្មោះ ហិរណ្យទាម ចេះមុខវិជ្ជាយ៉ាងច្រើនខាងមន្តអាគម។ ពិធីនេះហៅថា « ពិធីទេវរាជ» ក្នុងបំណងធ្វើឲព្រះអង្គឲមានឋានៈ ជាចក្រវាតីន (ស្តេច ចក្រវាល)។

ក្នុងពេល ជាមួយគ្នានេះ គេអភិសេកសេក សិវលិង្គ ដែលគេសន្មត់ថា ជាលិង្គព្រះឥសូរ។ ធ្វើដូច្នេះ គេអាចចាត់ទុកថា អាត្មន៍ពិសិដ្ឋ របស់ព្រះរាជា បានទៅសណ្ឋិតនៅក្នុងសិវលិង្គនោះ ដែលបាន ក្លាយជា តំណាង ឬ និមិត្តរូប នៃទេវរាជ។

ដូចយើងបាន និយាយខាងលើ រួចហើយថា ជំនឿលើ លិង្គព្រះឥសូរនេះ ជាជំនឿបែបថ្មីតែប៉ុណ្ណោះ នៅស្រុកខ្មែរ ព្រោះវាក្លាយចេញ ពីជំនឿព្រះសិលាឬអ្នកតា របស់ខ្មែរដើម។ ហេតុនេះឯងហើយ បានជា ជំនឿលើ លិង្គព្រះឥសូរនេះ មានប្រជាប្រិយភាព ក្នុងបណ្តាជនខ្មែរ នៅសម័យអង្គរ ព្រោះវា មានលក្ខណៈប្រហែលនឹង **ជំនឿអាយ**38 របស់ខ្មែរនោះឯង។

ហេតុនេះឯង បានជា វិទូប្រវត្តិសាស្ត្រ ជាច្រើន បានឲតម្លៃ ដល់ព្រះបាទជ័យវរ្ម័នទី ២ ថាជាព្រះរាជានេះ មានប្រជ្ញាបង្កើត ជំនឿជាតិមួយបាន ដោយធ្វើការ បូកបញ្ចូលគ្នា នូវជំនឿរបស់ព្រហ្មញ្ញសាសនា និងជំនឿអាយ ដើម្បីស្វែងរកឯកភាពជាតិផង និង ធ្វើព្រះអង្គក្លាយ ជាទេវរាជ នៅថានមនុស្សលោកផង។

នៅសម័យអង្គរ ព្រះរាជាខ្មែរ មានងារ ជា «**កំរាតែនផ្ទៃក្រោម**» មានន័យថា « ម្ចាស់ផែនដីខាងក្រោម»។ ក្នុងងារនេះឯងហើយ ដែលព្រះរាជាខ្មែរ ទុកខ្លួន ជាម្ចាស់ផែនដី ហើយ គ្រប់កិច្ចការ ដែលមាន ទំនាក់ទំនង នឹងរឿងដី ក្នុងព្រះរាជាណាចក្រ ត្រូវចាំបាច់ មានការអនុញ្ញាត ពីព្រះអង្គ ជាមុនសិន។ បើនិយាយឲខ្លី គឺប្រទេសជាព្រះអង្គ តែម្តង ដូចអ្នកស្រុក ទុកអ្នកតា ជាម្ចាស់ស្រុកនោះឯង។

ទោះបី មានការវិវឌ្ឍន៍លទ្ធិរាជាធិបតេយ្យ ពីព្រាហ្មណិកធម៌ ទៅពុទ្ធកធម៌ តែខ្មែរយើងនៅតែ មានជំនឿ ជាច្រើនបែបយ៉ាង នៅតាមដំបន់រស់នៅរបស់គេរៀងៗខ្លួន ដែលជាកត្តាមួយ នាំឲ សង្គមខ្មែរយើង មានលក្ខណៈ ជាសង្គមផ្តុំដោយក្រុម

---

38 ជំនឿអាយ= ជំនឿដើមរបស់អ្នកស្រុក។

មនុស្សតូចធំ ជាច្រើន ដែលជាការលំបាកមួយ ក្នុងការស្វែងរក ឯកភាពជាតិ។ ការនេះ នាំឲ អ្នកដឹកនាំគ្រប់សម័យ ជាពិសេសប្រទេសជិតខាង គេឆ្លៀតទាញយកប្រយោជន៍ ពី **ពហុភាពនៃគំនិតខ្មែរ**39 ដែលមាន ក្នុងខេមរៈសង្គម។

ខ្មែរយើងនិយាយថា បើនសិនជានគរខ្មែរ ឥតមហាក្សត្រ ច្បាស់ជាមាន កើតចលាចលជាពុំខាន ទស្សនៈនេះ ជាមរតករបស់បុព្វបុរសខ្មែរ ពីសម័យមួយទៅសម័យមួយ ដែលគាត់ទុកបន្ត ឲរាស្ត្រខ្មែរ រហូតមកដល់រាជ្យសម្តេចសីហនុ។ ក្នុងគំនិតនេះ រាស្ត្រខ្មែរប្រដូចព្រះមហាក្សត្រ នឹងអំណាច មជ្ឈិម មានមហានុភាពដែល ជាអំណាច សម្រាប់បង្រួបបង្រួមជាតិផង ជាអំណាច ស្តេចចក្រពត្តិផង និង ជាអំណាច សម្រាប់គ្រប់គ្រងប្រទេសផង ដែលជា នគរកើតមានឡើង ពីការប្រជុំរដ្ឋតូចធំ ជាច្រើន បើយោងតាមព្រះរាជពង្សាវតាខ្មែរ ចំនួនរដ្ឋតូចធំនោះមានរហូតដល់ ទៅមួយពាន់ស្រុកឯណោះ។ ការបែងចែកដែនដីប្រទេសខ្មែរនេះ បង្ហាញ ឲឃើញថា មានអនុអំណាចដំបន់ ស្រុកជាច្រើន នៅក្រោមអំណាចមជ្ឈិម តែអនុអំណាចនេះ មានស្វ័យរាជ្យត្រួតត្រាដំបន់ខ្លួនគ្រប់វិស័យ កតព្វកិច្ចតែមួយ ចំពោះអំណាច មជ្ឈិមដែលអនុអំណាច ត្រូវមាន គឺសេចក្តីស្មោះត្រង់គ្មានលក្ខខ័ណ្ឌ។ ការបង្ហាញការស្មោះត្រង់នេះ ត្រូវធ្វើឡើង តាមជំនួយគ្រប់បែបយ៉ាងដែល អំណាច មជ្ឈិម ត្រូវការជំនួយ ជាពិសេស គឺជំនួយយោធា ជាពលក្តី ជាសម្ភារៈក្តី នៅពេលដែលប្រទេស មានសង្រ្គាម និង ពលកម្ម សំរាប់គ្រប់ស្ថាបនកម្មរបស់ព្រះមហាក្សត្រ ដែលជា អាណត្តិគហក នៃព្រះធរណី។

ស្តេចដំបន់និមួយៗ ដែលខ្មែរយើងធ្លាប់ហៅថា «ស្តេចក្រាញ់» សុទ្ធជា អាណត្តិគហក នៃដែនដីស្រុកខ្លួន ដូចសព្វថ្ងៃនេះ អស់លោករដ្ឋមន្ត្រីគ្រប់ក្រសួង គាត់ទុកខ្លួនគាត់ ជាម្ចាស់របស់ក្រសួង ចៅហ្វាយខេត្ត ចៅហ្វាយស្រុក គាត់ទុកគាត់ជាម្ចាស់ខេត្ត ស្រុក។ កតព្វកិច្ច របស់ពួកគាត់ មានតែមួយគត់ គឺការពារប្រយោជន៍

---

39 ពហុភាពនៃគំនិតខ្មែរ=Multitude de la pensée khmère។

យួនកុម្មុយនិស្ត នៅស្រុកខ្មែរ ប្រយោជន៍នោះ គឺទុក សេរីភាព ឲយួនកុម្មុយនិស្ត ប្រើទឹកដីខ្មែរ តាមសេរី។

## ផ្នែកទី២

## ព្រះមហាក្សត្រជាអាណាព្ជគហកនៃព្រាហ្មណិកធម៌

តាមសិលាចារិកខ្មែរ អរិយធម៌ឥណ្ឌា មានឥទ្ធិពលយ៉ាងខ្លាំង មកលើ គោលការណ៍ នៃការបង្កបង្កើរដ្ឋខ្មែរ តាំងពីដើមទីមក ឥទ្ធិពលនេះ គេឃើញ មានក្នុងគ្រប់ផ្នែក ក្នុងរបបរាជានិយមខ្មែរ ដូចយ៉ាង ការអប់រំគតិយុត្ត នយោបាយដឹកនាំនិងទស្សនវិជ្ជាព្រហ្មញ្ញសាសនា ប៉ុន្តែ ឥទ្ធិពលនេះ មិនសូវជ្រៅកជ្រាបច្រើនណាស់ណាទេ នៅលើការរស់នៅជារៀងរាល់ថ្ងៃ របស់ប្រជារាស្ត្រខ្មែរ ព្រោះថា នៅចំពោះមុខការហៀរហូរ បាចសាចព្រាហ្មណិកធម៌ ក្នុងមជ្ឈដ្ឋាន អ្នកដឹកនាំ ប្រជារាស្ត្រខ្មែរ គាត់នៅ តែបន្ត ជឿលើ **ជំនឿអាយ** របស់ខ្លួនជានិច្ច ហើយ មិនមានការយកចិត្តទុកដាក់ច្រើនណាស់ណា លើជំនឿអ្នកដឹកនាំខ្លួន ដែលជាហេតុមួយ នាំឲមានចែក ក្នុងខេមរៈសង្គម ជាពីរ **សណ្តាប់ធ្នាប់**40៖

១. សណ្តាប់ធ្នាប់សង្គម ដែលជា របៀបរស់នៅរាល់ថ្ងៃ របស់ប្រជារាស្ត្រ។

២. សណ្តាប់ធ្នាប់ស្តេច ដែលជា របៀបដឹកនាំជាតិ ដោយយក ព្រាហ្មណិកធម៌ ជាមូលដ្ឋាន នៃ **រចនាសម្ព័ន្ធរៀបចំ**41 និង សណ្ឋាន នៃជំនឿ។ គឺថា គ្រប់ស្ថាប័នរបស់របបរាជាធិបតេយ្យ គេយកព្រហ្មណិកធម៌នេះ ជា **គ្រោងនយោបាយ**42 និង សាសនា។ គ្រោងនេះគេទុកជា សសរទ្រូង របស់របបដឹកនាំ។

---

40 សណ្តាប់ធ្នាប់ទីនេះប្រើក្នុងន័យផាសាបារាំង=Ordre។
41 រចនាសម្ព័ន្ធរៀបចំ=Structure organique។
42 គ្រោងនយោបាយ=Armature politique។

ក្នុងចំណោម **សិក្ខាបទ**43 ជាច្រើន របស់ព្រហ្មញ្ញសាសនា សិក្ខាបទ ដែលព្រះរាជាខ្មែរទទួលយកយ៉ាងងាយបំផុត គឺគោលទេវរាជ។ ចាប់ពីសតវត្សទី១០មក អ្នកដឹកនាំជាតិនាំគ្នា ទុកគោលការណ៍នេះ ជាអត្ថរស នៃរបបរាជានិយមតែម្តងព្រោះជំនឿនេះ វាមានមូលដ្ឋានរួចស្រេច ក្នុងជំនឿអាយ របស់ប្រជារាស្ត្រ គឺជំនឿលើព្រះធរណី ដែលមាន ព្រះមហាក្សត្រ ជាអណត្តិគហក គឺថាជាម្ចាស់ផែនដី។

ទ្រិស្តីទេវរាជ្យមានចែងក្នុង **គម្ពីរវេទ** និង នៅក្នុង អត្ថាធិប្បាយ តាមការរសូត្រធម៌ របស់ពួកព្រាហ្មណ៍ ដែលយើងលើកយកគោលការណ៍ធំៗខ្លះ មកជំរាបជូនអ្នកអាន ដូចខាងក្រមនេះ៖

ច្បាប់សត្វលោក ជាស្រមោលនៃច្បាប់លោកធាតុ ដូចយ៉ាងសណ្តាប់ធ្នាប់មនុស្សលោក សាសនា សីលធម៌ នយោបាយ និង គតិយុត្ត។ ច្បាប់ទាំងពីរនេះ បង្កើតដោយ **បញ្ញាព្រះ** (Prajapati) ដែលជា **ពិធីករតែមួយនៃពិធីបូជាសាសនា**44 ដែលជា ព្រះមានកម្លាំងទិព្វស្មើ នឹងព្រះព្រហ្មណ៍។

«**បញ្ញាព្រះ ព្រាហ្មណ៍**»45 ជា **បុព្វព្រះ**46 ជាគោលការណ៍ នៃជីវិតនិង ជា **បទដ្ឋានអាយាម៉ក**47 ក្នុងលោកធាតុ។ ជាព្រះ ដែលមាន លក្ខណៈព្រមគ្នា ជា «ជីវិត» ឬ បុគ្គលផង ជា «**និរជិវិត**» 48 ឬ វត្ថុផង ជា «អ្នកបង្កើត» ផង ជា «ការបង្កើត» ផង។ បញ្ញាព្រះ ជានិមិត្តរូប នៃច្បាប់លោកធាតុផង និង សុខដុម របស់លោកធាតុផង ដែលកើតមានឡើង ពីការធ្វើបូជាគ្រប់បែបយ៉ាង និង **ជាវិតីវាចា**49 របស់ព្រះអង្គ។ ព្រះអង្គ ជាអ្នកប្រកាសសណ្តាប់ធ្នាប់លោកធាតុ ដូចជា រដូ

---

43 សិក្ខាបទ=Enseignement។
44ព្រះពិធីករនៃពិធីបូជាសាសនា=Le sacrifice។
45 បញ្ញាព្រះ ព្រាហ្មណ៍=Prajapati-Brahmana។
46 បុព្វព្រះ ព្រះដែលមានតាំងពីដើមកំណើតលោកធាតុមក=L'Etre originel។
47បទដ្ឋានអាយាម៉ក=Norme régulatrice។បទដ្ឋានដែលធ្វើឲទៀងទាត់។
48 និរជីវិត=គតមានជីវិត។
49 និរជីវិត=គតមានជីវិត។

វ វស្សាកាល វេហា បុព្វហេតុ នៃចលនា និងចង្វាក់របស់វា។ ព្រះអង្គ ជា**អនន្ត**50ជា អមតៈ ជាឯកភាព និង ជាវិញ្ញាណ។

បញ្ញាព្រះ ជាអត្ថរស នៃ **អំណាចកុត្តរៈ**51 អំណាចនេះ នៅឋានមនុស្ស ទុកវណ្ណៈព្រាហ្មណ៍ ជាអ្នកកាន់កាប់ ព្រោះពួកគេ ទុកវណ្ណៈខ្លួនខ្ពស់ជាង វណ្ណៈក្សត្រិយៈ វេស្សៈ និង សូទ្រៈ។ វណ្ណៈព្រាហ្មណ៍ ជាអ្នកក្តាប់ នូវមុខវិជ្ជាសម្ងាត់ នៃវេទវិទ្យា ជាពិធីករគ្រប់ពិធីសាសនា និង ជាអ្នកចេះបច្ចេកទេស គ្រប់បែបយ៉ាង ក្នុងពិធីបូជាអាទិទេព ព្រោះបើគ្មានវិជ្ជានេះទេ អាទិទេពពុំអាច ទទួលបាន នូវបណ្ណាការទាំងឡាយ ដែលមនុស្សលោកចង់ថ្វាយព្រះអង្គ តាមរយៈព្រាហ្មណ៍។

ក្នុងលទ្ធិទេវរាជា ពិធីប្រគល់ **រាជទណ្ឌ**52 ដល់ព្រះមហាក្សត្រ ជាការប្រកាសជាផ្លូវការ ទុកស្តេច ជាអ្នកទទួលរក្សា ទុកក្បួនពិធីបូជា ដែលមានចែងទុក ក្នុងគម្ពីរវេទ ព្រះអង្គ ជានិមិត្តរូប នៃវ **អភិញ្ញាណ**53 ទ្វេ របស់ «បញ្ញាព្រះព្រហ្មណ៍» ដែលជា**និយតករ**54 ក្នុងលោកធាតុ។ មុនពេលធ្វើពិធីប្រសិទ្ធិបូជានេះ ព្រះមហាក្សត្រ ជាបុព្វគំណាងព្រះឥន្ទ្រ តែក្រោយពេលធ្វើពិធីប្រសិទ្ធីរួចមក ព្រះអង្គ ក៏បានក្លាយជាអធិបតីនៃបញ្ញាព្រះ លើលោកិយដែលបាន ទទួលបេសកកម្មអនុវត្តធម៌ដឹកនាំប្រទេស ឬ គ្រប់គ្រងមនុស្ស ដែលមានចែង ក្នុងគម្ពីរវេទ។ ពិធីប្រសិទ្ធស្តេចនេះ តាមពួកព្រាហ្មណ៍ គឺជាការចម្លង ដូចបេះបិទ ពីពិធីប្រសិទ្ធព្រះឥន្ទ្រ នៅ **ទេវនាគរី**55 ដែលមានចែង ក្នុងរឿងព្រេងមួយ ដែលយើងលើកយកដំណាល ដូចខាងក្រោមនេះ៖

*«ពួកទេវតា និង ពួកយក្ស បង្កើតឡើងដោយបញ្ញាព្រះ ក្រុមទីមួយ ជា "មាត់" អាច ជា "បញ្ញា" តែម្តង ក្រុមទីពីរ ជា "អវយវៈ" នាំគ្នាឈ្លោះគ្នា ដណ្តើមគ្នា ធ្វើ*

50 អនន្ត=គ្មានទីបញ្ចប់(infini)។
51 អំណាចកុត្តរៈ=Pouvoir spirituel។
52 រាជទណ្ឌ=ទិព្វអំណាច sceptre royal។
53 អភិញ្ញាណ=Connaissance។
54 និយតករ=អ្នកធ្វើឲមានការទៀងទាត់(Régulateur)។
55 ទេវនាគរី=ឋានសួគ៌។

*អធិបតី នៃលោកិយ ដោយប្រើ "ការបូជាអទិទេព" ជាអាវុធ។ ពួកទេវតា ទោះបីមានចំណេះច្រើន ក្នុងវិទ្យាបូជាយ៉ាងណាក៏ដោយ ក៏នៅតែចាញ់ដៃពួកយក្ស ក្នុងការប្រយុទ្ធនេះ នាំគ្នាទៅសូម ឲព្រះឥន្ទ្រជួយពួកខ្លួន។ ព្រះឥន្ទ្រ បន្ទាប់បានទទួលជ័យជំនះ លើពួកយក្សមក ព្រះអង្គបានសូម ឲ «បញ្ញាព្រះ» ធ្វើពិធីប្រសិទ្ធ ជាឧឡារិក ឲព្រះអង្គក្លាយ ជា «បញ្ញាព្រះ» តែម្តង ដើម្បីតាំងខ្លួនឯង ជាស្តេចលោកធាតុ គឺថា ជាស្តេចលោកិយផង និង ជាស្តេចទិព្វរាជ្យផង»។*

នៅក្នុងសម័យអង្គរ គ្រប់ព្រះមហាក្សត្រខ្មែរ ធ្វើបដិបត្តិព្រហ្មណិកធម៌ យ៉ាងហ្មត់ចត់ណាស់ ទោះបីស្តេចទាំងនោះ ជាព្រហ្មបរិស័ទក្តី ជាពុទ្ធបរិស័ទក្តី។ មកដល់បច្ចុប្បន្នកាលនេះ ទោះបីរាជានិយមខ្មែរ ជារបបអាស្រ័យព្រះពុទ្ធសាសនា ក៏ដោយ តែក្នុងពិធីអភិសេកព្រះមហាក្សត្រ គេនៅតែយក ពិធីព្រហ្មញ្ញសាសនា ជាពិធី ជាផ្លូវការជានិច្ច។ ក្នុងចំណោម **ទិស្សមានាការ**56 ជាច្រើន ក្នុងពិធីអភិសេកនេះ ទិស្សមានាការមួយ ដែលខ្មែរយើង ធ្លាប់ឃើញដែរ ក្នុងមង្គលការ គឺពិធី «**បង្វិលពពិល**» ពិធីនេះធ្វើឡើង សំរាប់ធ្វើឲ ព្រះមហាក្សត្រ ក្លាយជា ស្តេចលោកធាតុ គេប្រារព្ធធ្វើឡើង នៅថ្ងៃទីប្រាំ ក្នុងពិធីអភិសេកស្តេច គេប្រារព្ធឡើងបន្ទាប់ពី ពិធីស្រោចទឹក ដើម្បីប្រសិទ្ធិស្តេច ឲព្រះអង្គសណ្ឋិត នៅ **កណ្តាលលោកធាតុ**57 និង ឲអត្តរសព្រះអង្គ ឲទៅជាអត្តរស នៃច្បាប់លោកធាតុ។ ក្នុងពិធីនេះ ព្រាហ្មណ៍ពិធីករ អញ្ជើញព្រះអង្គម្ចាស់ទាំងឡាយ រដ្ឋមន្ត្រីគ្រប់មុខក្រសួងនិងគ្រប់អ្នកមានបណ្តាសក្តិ ឲមកអង្គុយផ្ទាល់នឹងដី ជុំវិញព្រះមហាក្សត្រ នាំគ្នាហុចតៗគ្នា ពីឆ្វេងទៅស្តាំ កូនថាស មានចំនួន៧ ដែលគេដោតទៀនដុតនៅលើថាសនេះ បង្វិលជុំវិញព្រះមហាក្សត្រ១៩ជុំ យកដៃស្តាំ បក់ផ្សែងទៀន ឲហើរទៅលើ ព្រះអង្គ។ក្នុងពិធីនេះ គេទុក ព្រះមហាក្សត្រ ជាមជ្ឈមណ្ឌល នៃលោកធាតុ ឯចំណែកអ្នកនៅជុំវិញព្រះអង្គ គេទុក ជា **ផ្កាយព្រះគ្រោះ**58។

---

56 ទិស្សមានាការ=ដំណាក់ការ(Phase)។
57 កណ្តាលលោកធាតុ=Centre du cosmos។
58 កណ្តាលលោកធាតុ=Centre du cosmos។

ការដឹកនាំប្រជាជាតិ តាមលទ្ធិព្រាហ្មណ៍ មានគោលការណ៍សំខាន់ បីយ៉ាង៖

១. ឯកភាពសាសនា និង ឯកភាពនយោបាយ។

២. គ្រឹះនៃ **ធម្មនុរូប**59 នៃរាជអំណាច គឺអំណាចផ្តាច់ការរបស់ព្រះរាជា។

៣. កំហិត នៃរាជអំណាច។

**១.ឯកភាពសាសនា និងឯកភាពនយោបាយ៖**

ព្រះមហាក្សត្រខ្មែរ ក្នុងសម័យអង្គរ ព្រះអង្គ យកលទ្ធិ «ទេវរាជ» ជា **សម្បទា**60 នៃការបង្រួបបង្រួមជាតិ និង ការសម្របសម្រួល នៃជំនឿអាយខ្មែរ ដែលមាន ជាច្រើន អនេក នៅក្នុងនគរ។ ជំនឿអាយនិមួយៗនេះ គេគិតតែ រក **អត្ថប្រយោជន៍** ជាអាទ៍ ដែលជាហេតុបង្កើត ឲមាន អនាធិបតេយ្យ ក្នុងសង្គមជាតិ ការនេះ វាជា ឧបសគ្គ នៃការស្វែងរកឯកភាពជាតិ ដូច្នេះ ការបង្កើតជំនឿទេវរាជ ដែលជា ជំនឿជាតិមូលតែមួយ គឺបង្កើតឡើង សំរាប់បំរើប្រយោជន៍នយោបាយ ហេតុនេះឯង បានជា អ្នកប្រវត្តិសាស្ត្រយល់ឃើញថា ទស្សនៈទេវរាជ នៅស្រុកខ្មែរ មានលក្ខណៈនយោបាយ ច្រើនជាង លក្ខណៈសាសនា។

បើព្រះមហាក្សត្រ ជាអាទិទេពតែមួយ លើព្រះទាំងឡាយ នៅក្នុង ព្រះរាជាណាចក្រ គឺព្រះអង្គ ជាអធិបតីតែមួយគត់ ក្នុងនគរ បើនិយាយ ឲចំទៅ គឺព្រះអង្គ ជាអាយុជីវិតជាតិ។ គ្រប់សម្បទា គ្រប់ស្ថាបនកម្ម គឺធ្វើឡើង ក្នុងគំនិត ទុកព្រះរាជាជាទេវរាជ ជាអាណត្តិគហក នៃទេវអំណាច ដែលជា ឧត្តមអំណាចនយោបាយទ្រទ្រង់ដោយទ្រឹស្តីសាសនា សំរាប់រក្សាឯកភាពជាតិ។

ដូចយើងធ្លាប់បានលើក យកបង្ហាញរួចហើយថា ព្រះបាទជ័យវរ្ម័នទី២ ជាស្តេចខ្មែរទីមួយ ដែលបាន យកទ្រឹស្តី «ទេវរាជ» មកអនុវត្ត ក្នុងរបបរាជានិយមខ្មែរ ទ្រឹស្តី

---

59 ធម្មានុរូប=ស្របច្បាប់(Légitimité)។
60 សម្បទា=ឧបាយ Artifice ; Moyen។

នេះឯងដែល ជាសម្បទា របស់ព្រះអង្គ សម្រាប់បង្រួបបង្រួម ចេនឡាដីគោក (ចេនឡាលើ ឬ ចេនឡាដើម) និង ចេនឡាទឹក (ចេនឡាក្រោម ឬ នគរភ្នំដែលមានឈ្មោះថាហ្វូណន់) ឲមានឯកភាពជាតិឡើងវិញ ដោយយកឈ្មោះ «**កម្ពុជា**» ដែលជា ឈ្មោះគ្រឹះ មានដើមកំណើតមកពី ឥសី **កម្ពុស្វយម្ភូវ** និង នាងទេពអប្សរ **មេរា** ដែលព្រះឥសូរ បានប្រទាន ឲជាមហេសី61 ការសម្ព័ន្ធ ឥសីកម្ពុ នឹងនាងមេរា នេះ ជាបុព្វហេតុ ដែលនាំ ឲកើតជាសូរ្យវង្ស ឬ អាទិច្ចវង្សឡើង នៅខាងចេឡា។ ជម្រើសឈ្មោះនេះទៀត គឺព្រះបាទជ័យវរ្មនទី២ ចង់បង្ហាញថា ការបង្រួបបង្រួមជាតិនេះ ជាស្នាដៃព្រះឥសូរ ដែលមាន ព្រះអង្គ ជាតំណាង តែមួយគត់ លើដែនដីកម្ពុជា។

យើងឃើញថា នៅស្រុកខ្មែរ មានការលំបាកខ្លាំងណាស់ ក្នុងការបែងចែកឲដាច់ រវៀងនយោបាយដឹកនាំ និងសាសនា ព្រោះអំណាចនយោបាយដឹកនាំ តែងទុកខ្លួន នៅពីលើសាសនាជានិច្ច ដូចយ៉ាង ព្រះរាជា ជាអ្នកប្រគល់ងារ ឲអ្នកដឹកនាំគណៈសង្ឃ ព្រោះព្រះអង្គ ជាមគ្គទេសក៍ នៃជំនឿសាសនា តែម្តង។

## ២. គ្រឹះនៃធម្មានុរូបនៃរាជអំណាច និង អំណាចផ្តាច់ការ របស់ព្រះរាជា៖

ព្រហ្មញ្ញសាសនា ទុកសណ្តាប់ធ្នាប់សត្វលោក ជាស្រមោល នៃច្បាប់លោកធាតុ។ ការរក្សា សណ្តាប់ធ្នាប់សត្វលោក មានគោលបំណង រក្សាសន្តិភាព វិបុលភាព និងយុត្តិធម៌ ក្នុងព្រះរាជអាណាចក្រ។ ដើម្បី ស្ថានភាពនេះ អាចមានបាន លុះត្រាតែព្រះរាជាគោរពដាច់ខាត ដោយហ្មត់ចត់ នូវគ្រប់ពិធីសាសនា ដែលមានព្រហ្មណ៍ជាពិធីករ។ ការថ្លោះធ្លោយជាកំហុសមួយ នាំមកនូវ មហន្តរាយ ដល់ប្រទេសនិងទុក្ខវេទនា ដល់ប្រជារាស្ត្រ។ បើយោងតាមទស្សនៈនេះ អំណាច របស់ស្តេច ជាអំណាចចាំបាច់ ដែលត្រូវតែ មានសំរាប់សេចក្តីសុខ របស់ប្រជារាស្ត្រ ហើយ ស្ថាប័នរាជានិយម ជាស្ថាប័ន ជាធម្មានុរូប ព្រោះជាស្ថាប័ន មានភព ចេញមកពីច្បាប់លោកធាតុ ដូច្នេះស្ថាប័ននេះ មាន **និតីសម្បទា**62 សាងរាជអាណាចក្រ នៅឋាន

---

[61] នេះជាទស្សនៈ លោក G.Coedès។
[62] និតីសម្បទា=Habilité។

លោកិយ ឲដូច នឹងនគរព្រះ នៅឋានសួគ៌ ជា**នាភីជីវិត**[63] សំរាប់សត្វលោក រស់ក្នុង ការស្រុះស្រួលគ្នា សមធម៌ និង ឧត្តមច្បាប់ដឹកនាំជាតិ។ ក្នុងទស្សនៈនេះ គេទុកព្រះមហាក្សត្រ ជាបុគ្គលតែមួយគត់ ដែលបានទទួលនូវអនុភាពទិព្វ ពីអាទិទេព ដើម្បីការពារមនុស្សជាតិ ឲរួចពី ភយន្តរាយ គ្រប់បែបយ៉ាង។ ការប្រគល់អំណាចទេវរាជនេះឯងហើយ ដែលគេទុក អំណាចស្តេច ជាអំណាចស្របច្បាប់ ត្រូវមានចំបាច់ សំរាប់សេចក្តីសុខ របស់ប្រជារាស្ត្រ។

ក្នុងលទ្ធិព្រាហ្មណ៍ ដែលមាននៅក្នុង ផ្នត់គំនិតខ្មែរយើង **សុក្រឹតភាព** របស់បុគ្គលម្នាក់ៗ អាចសម្រេចបាន ចំពោះជនណាដែលគេខំប្រឹងធ្វើ ប៉ុន្តែ **សមូហសុក្រឹតភាព** វិញ ត្រូវការពេលវេលាឆ្ងាយណាស់ ឬ អនន្តរវេលា ដើម្បីធ្វើ ឲសម្រេចបាន ព្រោះថា ការវិវឌ្ឍរបស់បុគ្គលម្នាក់ ចាប់ផ្តើមពីរុក្ខជាតិ បន្ទាប់មក ក្លាយជាសត្វ ជាមនុស្សមានប្រជ្ញា គ្រាន់ជាភាគសុខុមមួយ ក្នុងការវិវឌ្ឍ ក្នុងសាកលលោក។ អត្ថិភាពមនុស្សមិនមែន ជា **សមតា**[64] **ឋិនវន្ត**[65] ទេ ហើយ មិនថិតនៅ ក្នុងខណៈមួយ មិនចេះ ប្រែប្រួលនោះដែរ មនុស្សម្នាក់ៗ រស់ក្នុងចលនាជានិច្ចចាំបាច់ត្រូវ ចិញ្ចឹមជីវិតខ្លួនផង និង ស្វែងរកការរីកចំរើន នូវសម្បជញ្ញ ជា**មនុស្សលោក**[66] តាមមធ្យោបាយ របស់ខ្លួនម្នាក់ៗ។

ការប្រែរូបក្តី ចិត្តក្តី រហូតដល់ស្លាប់ មនុស្សម្នាក់រស់ ក្នុងចំណង់ ឲខ្លួនសម្រេច នូវសុក្រឹតភាព ជា **ឯកត្តភូត**[67]ទោះបី ខ្លួនរស់ ក្នុងសង្គមមនុស្ស ដែលតម្រូវ ឲខ្លួនគោរពច្បាប់នេះ ក្នុងឋានៈ ជា **ពលរដ្ឋ**[68]**។** លក្ខណៈជាឯកត្តភូត របស់បុគ្គលនេះឯង ដែលតម្រូវឲ មាន **និយតករ**[69] ក្នុងសង្គម ដើម្បីធ្វើ ឲមាន សមូហសុក្រិត។ ក្នុងសង្គមមានវណ្ណៈជាអាទ៍។ វណ្ណៈ និមួយៗ នាំគ្នាធ្វើ ឲមាន សុក្រិតភាព ក្នុងវណ្ណៈ

---

[63] នាភីជីវិត=ទីកម្លែងនៃជីវិត (Centre de vie)។
[64]សមតា(សៈមៈតា)=Equilibre។
[65] ឋិនវន្ត=Statique។
[66]មនុស្សលោក=Etre។
[67] ឯកត្តភូត=ផ្ទាល់ខ្លួន. Individuel។
[68] ពលរដ្ឋ=ទីនេះប្រើក្នុងន័យពាក្យបារាំងCitoyen។
[69] និយតករ=អ្នកធ្វើឲមានការទៀងទាត់.le régulateur។

ខ្លួន ដែលអាចមាន គោលដៅខុស ពីសុក្រិតភាព នៃវណ្ណៈដ៏ទៃទៀត ដែលជា កត្តាអាចបង្កើតជម្លោះមិនចេញមុខ ជារដើក **កលហៈ**70 ដែលអាច នឹងឆេះបានគ្រប់ពេលវេលា។ ម្យ៉ាងមួយទៀត គេទុកសង្គមមនុស្ស ជាសមូហភាពជូនកាលអាច មានការកែជាថ្មី ល្អ ឲចម្រើន ជូនកាលធ្លាក់ ក្នុងភាពពុករលួយនិង ជួបប្រទះ នឹងអកុសលគ្រប់បែបយ៉ាង។ ដូច្នេះ ដើម្បីជៀសវៀង កុំឲជួបនឹង**វិបរិយាល**71នេះ សង្គមមនុស្ស ត្រូវចាំបាច់ មាននិយតករ ជាអ្នកគ្រប់គ្រង អ្នកនាំផ្លូវផង ដែលមាន ការចេះដឹងធម៌ដឹកនាំសង្គមមនុស្ស មាន **ក្រិត្យ**72 ប្រចាំខ្លួន។

មគ្គុទ្ទេសក៍ ឬ និយតករ បែបនេះ គឺគ្មាននរណាក្រៅពី ព្រះមហាក្សត្រនោះឡើយ ក្នុងឋានៈព្រះអង្គ ជាអគ្គរស នៃលោកធាតុ ដែលជាអ្នករក្សា សេចក្ដីសុខរបស់សត្វលោក។ រូបភាពស្ដេច ជាអ្នករំដោះទុក្ខប្រជារាស្ត្របែបនេះ គេឃើញមានក្នុងសិលាចារិកខ្មែរជាច្រើ ដែលយើងយកមក បង្ហាញជូន ដូចខាងក្រោមនេះ៖

«*អាណាប្រជានុរាស្ត្រព្រះអង្គ លុងទឹក ក្នុងមហាសាគរ ដ៏មានជម្រៅ ឥតអាចឆ្លងបាន និង គួរខ្លាច ដូចរស់នៅ ក្នុងទុក្ខកាល ជា **កាលីយុគ**73 តែនៅពេលដែលរាស្ត្រ បានមកជួបព្រះអង្គ ដែលជាត្រើយដ៏ឧត្ដម រាស្ត្របានរកឃើញឡើងវិញ នូវសេចក្ដីសង្ឃឹមថ្មី* (បន្ទាយស្រី)»។

«*ព្រះអង្គកំទេចកាលី ដែលជាជនមានសង្ឃឹមថាខ្លួនអាចប្រព្រឹត្តបទឧក្រិដ្ឋឈ្លបមើលជានិច្ច គ្រប់ចំណុចខ្សោយ ដែលមានកើតឡើងក្នុងនគរ...*(ថ្នល់បារាយ)»។

«*ដ៏លិច ក្នុងមហាសាគរ នៃបាបធម៌ ព្រះអង្គ ជាអ្នកសង្គ្រោះមនុស្ស ឲរួចចេញ ពីបាបធម៌នេះ...*(អង្គរវត្ត)»។

---

70 កលហៈ=ជម្លោះ។
71 ដំណើរប្រែប្រួល.Vicissitude។
72 ក្រិត្យ=Obligation morale។
73 កាលីយុគ=សម័យកាលី.ក្នុងព្រហ្មញ្ញសាសនាគេទុកជាសម័យកើតមានចលាចលដែលនាំឲមានវិនាសកម្មដល់សត្វលោក។

យើងឃើញថា របបរាជានិយមខ្មែរ គេយក **ទេវកថា**74 សាសនា មកធ្វើ ជាហេតុការណ៍បែបសង្គមក្តី នយោបាយក្តី ដើម្បីបង្កើតអំណាច ដឹកនាំជាតិ។ គេទុករាជាអំណាច ជាឪសថ ប្រឆាំង នឹងភាព គ្មានសណ្តាប់ធ្នាប់ និង អនាធិបតេយ្យ ក្នុងសង្គម ដែលមានក្នុងធាតុសង្គម ពីកំណើតមក។ យើងសួរ ជាសំណួរថា ដោយយោង ទៅលើការវិវឌ្ឍន៍ជានិច្ច របស់សង្គមមនុស្ស តើរបបរាជានិយមខ្មែរ ចេះមានលំនាំ ខ្លួនរស់ ត្រូវតាម ការវិវឌ្ឍន៍នេះ បានដែរឬទេ?

**៣.កំហិតនៃរាជអំណាចៈ**

**បញ្ញាព្រះ** ដែលស្តេច យកមកធ្វើ ជាបញ្ញាដឹកនាំជាតិ មិនមែន ជា «បញ្ញាព្រះ» របស់អាទិទេពនោះទេ គឺជា «បញ្ញាព្រះ» សំរាប់រក្សា សណ្តាប់ធ្នាប់លោកធាតុ ដែលមាន គោលការណ៍ ជាអាយាម័ក មានចែងទុក ក្នុងច្បាប់លោកធាតុ។គោលការណ៍នេះ ជាគោលការណ៍ការពារ សុខដុម សាកលលោក និង ជាអ្នកបំរើធម៌សាសនា។ វិបាកកើតចេញពីទស្សនៈនេះ គឺការយល់ឃើញថា ស្តេចមិនមែនជាអធិបតីពិតប្រាកដ ក្នុងនគរនោះទេ អធិបតីពិត គឺ «**ធម្ម**» ដែលមានចែងក្នុង ច្បាប់លោកធាតុ។

ធម្មគោរព ជាកាតព្វកិច្ច របស់ស្តេច មិនអាចដាក់បែរបាននោះឡើយ បើមិនគោរពធម៌ គឺនាំបង្កើតទុក្ខ គ្រប់បែបយ៉ាងដល់នគរ រហូតនាំឲ ព្រះអង្គវិនាស ជាពុំខានទៅទៀត ដូចខ្មែរយើងធ្លាប់និយាយថា ស្តេចប្រកបដោយធម៌ ជាស្តេចមានទសពិធធម៌ បើស្តេចគ្មានធម៌នេះទេ ស្តេចបែបនេះ គេទុកជា ស្តេចពាលឥតអាសា ដូច្នេះកំហិត នៃអំណាចស្តេច គឺទសពិធធម៌នោះឯង។ បើស្តេច មានទសពិធធម៌ ព្រះអង្គពុំអាចដឹកនាំជាតិ តាមតែអំពើចិត្ត របស់ព្រះអង្គបាននោះឡើយ។

---

74 ទេវកថា=Mythe។

ក្នុងជំនឿខ្មែរ គេយក គោបា ជាតំណាងធម្ម ដែលបាក់ជើងម្តងមួយៗ តាមយុគនៃមនុស្សជាតិ ហើយ មកដល់ «កាលីយុគ» គោបា នៅសល់តែជើងមួយគត់ ដូច្នេះ ភារកិច្ច របស់ព្រះរាជា គឺបដិបត្តិធម្ម ឥតឲមានខ្ចោះ ដើម្បីធ្វើឲគោបាពិការ មានជើងបួនឡើងវិញ។ គេសរសេរ សរសើរ អំពី **បារមិត**[75] ព្រះមហាក្សត្រ ដែលកើតមានឡើង ពីបដិបត្តិធម្ម ដើម្បីជួយគោបាពិការនេះ មានសេចក្តីដូចតទៅ៖

*«នោះបីជើងនៅសល់តែមួយគត់ ហើយ ត្រូវ**កាលី** កំពុងវាយ បំបាក់ឲអស់ តែគោបា យកផលធម្ម របស់ព្រះរាជា ជាពំនឹង ដូចជា សសរមាំអស្ចារ្យ ឲខ្លួន អាចឈរ ជាប់មាំទាំដូចខ្លួននៅមានជើងបួន ដើម្បីសួរពិរុទ្ធ នឹងការវាត់វែង របស់កាលី»* (សិលាចារិកហង់ជៃ)។

ការយក **«ធម្ម»** ជាអធិបតេយ្យភាព របស់រដ្ឋនេះ ជាកំហិតទី១ នៃអំណាចផ្តាច់ការ របស់ព្រះមហាក្សត្យ។ គេដឹកថា កំហិតទី២ គឺមាននៅក្នុង លទ្ធិរបបរាជានិយមអាស្រ័យព្រហ្មញ្ញសាសនា តែម្តង ទុកអំណាចកុត្តរះស្តេច ជាអំណាចមានកំហិត ព្រោះក្នុងធម៌ មានចែងរួចស្រេច ក្នុងផ្នែកអំណាចកុត្តរះ ស្តីអំពីករណីយកិច្ច និង កាតព្វកិច្ចរបស់ស្តេច។

នៅសម័យអង្គរ ព្រះមហាក្សត្យខ្មែរ ត្រូវចាំបាច់មាន បុរោហិត ដែលខ្មែរយើង ហៅថាព្រះរាជគ្រូ ជាទីព្រឹក្សាជាន់ខ្ពស់ របស់ព្រះអង្គ ទទួលបន្ទុក អប់រំស្តេច ក្នុងផ្នែកសាសនា នយោបាយដឹកនាំរដ្ឋ និង គ្រប់មុខវិជ្ជាទាំងឡាយ ដែលមាននៅក្នុងគម្ពីរវេទ។ នៅប្រទេសឥណ្ឌា ក្នុងរជ្ជកាល ព្រះបាទ **Chandragupta** ព្រះគ្រូ របស់ព្រះអង្គ មាននាម ព្រាហ្មណ៍ **Kautilya** ជាព្រាហ្មណ៍ ដ៏ខ្លាំងពូកែ ល្បីល្បាញ ក្នុងរាជាណាចក្រ។ ព្រាហ្មណ៍នេះ ជាអ្នកសរសេរ ក្បួនដឹកនាំប្រទេស និង គ្រប់គ្រងមនុស្សលោក ដែលមាន ឈ្មោះថា **Arthaçastra**[76]។

---

[75] បារមិត=Vertu suprême។

[76] Artha=Utile et profit  ប្រយោជន៏។Arthaçastraអាចប្រែជាភាសាខ្មែរថាអត្ថសាស្ត្រា។

គេអាចសួរថា សំនួរបានថា គោលការណ៍បី ក្នុងព្រាហ្មណ៍សាសនា **ធម្ម អត្ថ** និង **កាមា** ដែលព្រះមហាក្សត្រ ត្រូវបដិបត្តិចាំបាច់ ដើម្បី ដឹកនាំប្រទេស ក្នុងគោលបំណង ស្វែងរកសុភមង្គល ជូនដល់ប្រជារាស្ត្រ តើអាចទប់ អំណាចផ្តាច់ការ របស់ព្រះមហាក្សត្រ បានដែរឬទេ ? ការពិត គេសង្កេតឃើញថា គ្រឿងទប់នេះ មិនសូវមាន ប្រសិទ្ធិភាពច្រើននោះឡើយ ព្រោះថា ពួកបុរោហិត និង ព្រះរាជគ្រូស្តេចដែលមាន តួនាទីជា **ពិរទ្ធាបេក្ខ**[77] ពួកគាត់គិតតែ ការពារប្រយោជន៍វណ្ណៈព្រាហ្មណ៍ និង បុព្វសិទ្ធិខ្លួន ច្រើនជាងគិត ការពារយុត្តិធម៌ និង សមធម៌ ជូនដល់ប្រជារាស្ត្រ ម្យ៉ាងទៀតវណ្ណៈព្រាហ្មណ៍ច្រើនមាន ញាតិពន្ធ ជាមួយវណ្ណៈក្សត្រ ដែលជា កត្តាមួយ ឲវណ្ណៈទាំងពីរ ចូលដៃគ្នាការពារញាតិខ្លួន ដែលជា អំពើនាំឲ ខូចដល់ប្រយោជន៍ប្រជាជាតិ។ គួរដឹងដែរថា នៅស្រុកខ្មែរ ពេលណា ស្តេចដាច់ពូជ ឡើងគ្រោងរាជសម្បត្តិ ញាតិរបស់ព្រះគ្រូ ជាកំណើតព្រាហ្មណ៍ អាចឡើងសោយរាជ្យបាន។ ត្រូវដឹងថា អំណាចស្តេច មានធម្មជាតិ ជាអំណាច **អប្បជនាធិបតេយ្យ**[78]ដែលជា ធាតុ ឬ ដើមហេតុពិត នៃការរំលោភ និង អំណាចផ្តាច់ការ ហេតុនេះឯង បានជា របបរាជានិយម ត្រូវប្រជាពលរដ្ឋ វាយរំលំ ស្ទើតែអស់ ក្នុងពិភពលោកនេះ។ ប្រត្យាស្ថាប័ន[79] របបរាជានិយមខ្មែរ ជាគ្រោះថ្នាក់ ជាប្រវត្តិសាស្ត្រ តែប៉ុណ្ណោះ ប៉ុន្តែ យើងមានជំនឿថា ការវិលត្រឡប់នេះ មិអាច ឋិតថេរបាននោះឡើយព្រោះ របបនេះ ទោះបី គេដាក់ខ្លួន នៅក្រោមច្បាប់ជាតិ យ៉ាងណាក៏ដោយតែរបបនេះនៅមាន ធាតុជា របបចង្រៃ សំរាប់ជាតិខ្មែរ បំរើ អំណាចផ្តាច់ការរណបបរទេស ដូច្នេះរបបនេះ នឹងរលាយជាមួយ របបប ចោរប្លន់ជាតិខ្មែរ សព្វថ្ងៃ ជាពុំខាន។ ការលំនេះ គឺវានៅចាំ តែពេលវេលាវា ដែលនឹងត្រូវ មកដល់ នៅពេល ឆាប់នេះ ជាពុំខាន។

## ផ្នែកទី៣

---

[77] ពិរទ្ធាបេក្ខ=អ្នកចាប់ពិរុទ្ធ.Censeur។
[78] អប្បជនាធិបតេយ្យ=របបដឹកនាំជាតិដែលនៅក្នុងកណ្តាប់ដៃមនុស្សមួយក្រុមតូច.Oligarchie។
[79]ប្រត្យាស្ថាប័ន=ការបង្កើតឡើងវិញ។

## ព្រះមហាក្សត្រជាអាណាព្យាបាលនៃពុទ្ធសាសនាធំ

បើយោងតាម **វស្សិកប្រវត្តិសាស្ត្រ**80 របស់ចិន ព្រះពុទ្ធសាសនា ចាប់ផ្តើមមានឥទ្ធិពលមកលើ ប្រជារាស្ត្រខ្មែរ តាំពី សត្តវត្សទី៧មកម្លេះ ក្នុងពេលជាមួយគ្នានោះដែរ ជំនឿលើព្រះឥសូរ ក៏កំពុង ជ្រួតជ្រាបខ្លាំងឡើងៗ ក្នុងព្រះរាជវាំង និង ក្នុងមជ្ឈដ្ឋាន អ្នកដឹកនាំ។ ជំនឿនេះ ហាក់បីគ្មានទំនាស់អ្វី គួរឲកត់សំគាល់ ចំពោះពុទ្ធសាសនានោះឡើយ។ ជំនឿទាំងពីរនេះ រស់ជាមួយគ្នា ប្រកបដោយ សុវត្ថិភាព នៅក្នុងស្រុកខ្មែរ។ តាមសិលាចារិ ចុះក្នុងឆ្នាំ៧៩១ នៃគ.ស. បានចារទុកថា នៅស្រុកខ្មែរ ក្នុងជំនាន់នោះ មានកសាង រូបបដិមាក ព្រះពុទ្ធ «**លោកិស្សរ**»។ គេអាចសួរ ជាសំណួរថា ព្រះពុទ្ធសាសន និងព្រហ្មញ្ញសាសនា តើសាសនាណាមួយ បានជ្រាបចូលមក ស្រុកខ្មែរមុនគេ ? ប្រវត្តិសាស្ត្រវិទូយល់ឃើញថា ចម្លើយ នឹងសំណួរនេះគ្មានសារ:សំខាន់អ្វី ច្រើននោះឡើយ គេគ្រាន់តែដឹកថា អារ្យធម៌ឥណ្ឌា បានហូរចូលមកស្រុកខ្មែរ តាមរយ: ពួកឈ្មួញសមុទ្រ ឬ តាមពួកអ្នកផ្សាយសាសនា ព្រាហ្មញ្ញសាសនាក្តី ពុទ្ធសាសនាក្តី។

ក្នុងសម័យអង្គរ ចាប់តាំងពីសត្តវត្សទី១០មក ព្រះពុទ្ធសាសនាចាប់ផ្តើមមានឥទ្ធិពលខ្លះៗមកលើព្រះមហាក្សត្រខ្មែរ ដូចមានក្នុងរជ្ជកាល៖

- ព្រះបាទជ័យវរ្ម័នទី៥ (៩៦៨-១០០១)។

- សូរ្យវរ្ម័នទី១ (១០០២-១០៥០)។

- តារានិន្ទ្រវរ្ម័នទ (១១៥០-១២២០)។

ជាពិសេសនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២២០?) ព្រះពុទ្ធសាសនាបានស្គាល់សិរីយសខ្ពង់ខ្ពស់របស់ខ្លួនក្នុងរាជាណាចក្រកម្ពុជា ហេតុនេះឯងបាន

80 វស្សិកប្រវត្តិសាស្ត្រ=Annales។

ជាព្រះរាជានេះមានកេរ្តិ៍ឈ្មោះល្បីលេចឮសាយមកដល់បច្ចុប្បន្ននេះ ព្រោះព្រះអង្គជាស្តេចខ្មែរធ្វើសង្គ្រាមវាតទឹកដីបានធំទូលាយជាងពេលណាៗទាំងអស់ បានកសាងប្រាសាទជាច្រើន ដូចជាប្រសាទបាយ័ន បន្ទាយក្តី តាព្រហ្ម ព្រះខាន់ នាគព័ន្ធ តាសោម ក្រោលគោ បន្ទាយឆ្មារ វត្តនគរ នឹងតាព្រហ្មនៅបាទី។ ក្នុងវិស័យ មនុស្សធម៌ ព្រះអង្គបានសាងសាលាសំណាក់ចំនួន១២១ និងមន្ទីរពេទ្យចំនួន ១០២ តែស្នាព្រះហស្ថចម្បងរបស់ព្រះអង្គគឺពង្រឹងក្រុងអង្គរទី៣ សាងកំពែងនិងគូទឹកព័ន្ធជុំវិញមានគោបុរៈ៥ និងមានប្រាសាទបាយ័ននៅចំកណ្តាល។ ប្រវត្តិសាស្ត្រវិទូជាច្រើន យល់ឃើញថា **អំពើលលារកភាពសំបើម**[81]នេះ ជាដើមមូលហេតុនៃការរលំមហានគរខ្មែរ ដោយសារព្រះរាជាអង្គនេះប្រើធនធាននគរឲអស់សូន្យក្នុងសេចក្តីប្រាថ្នាស្វែងរកកិតិយសរបស់ព្រះអង្គឲមានជាអមតៈ។

ត្រូវដឹងថាព្រះពុទ្ធសាសនានៅសម័យអង្គរជា ព្រះពុទ្ធសាសនា**មហាយាន**(យានធំ) ឯចំណែក **ហីនយាន** (អាចរិយវាទ) វិញ មានប្រភពចេញពីប្រទេសសៀម ហូរចូលស្រុកខ្មែរខ្លាំងបន្តិចម្តងៗ ចាប់តាំងពីសតវត្សទី១៤ ហើយក៏បានក្លាយទៅជាសាសនាតែមួយរបស់ប្រជារាស្ត្រខ្មែរ ដែលនាំឲរបបរាជានិយមខ្មែរ ខំកែប្រែកិរិយាខ្លួន យ៉ាងហោចណាស់ក្នុងទំនង **វាចកៈក្រៅ**[82] នៃជំនឿដើមរបស់ខ្លួន ដើម្បីឲវាស្របទៅនឹងសិក្ខាបទនៃហិនយាន ដែលទុកមនុស្ស ជាអត្តរស របស់ធម៌ ច្រើនជាង មហាយាន និងព្រហ្មញ្ញសាសនា។

យើងលើកយក ព្រះពុទ្ធសាសនាក្នុងរបបរាជាធិតេយ្យខ្មែរមកសិក្សាក្នុងពីរសម័យ គឺថាក្នុងសម័យអង្គរ គឺជាសម័យមហាយាន និងសម័យក្រោយអង្គរ គឺជាសម័យហិនយាន ដើម្បីតាមយល់អំពីប្រភពនៃអំណាចនៅស្រុកខ្មែរៈ

## ១. សម័យអង្គរ សម័យពុទ្ធសាសនាមហាយាន

---

[81] អំពើលលារកភាពសម្បើម= Folie de grandeu។
[82] វាចកៈ= សណ្ឋានក្រៅ ; Forme extérieure។

ក្នុងសម័យអង្គរ នោះបើមានមហាក្សត្រខ្មែរខ្លះលើកព្រះពុទ្ធសាសនាមហាយានជាសាសនាជាផ្លូវការរបស់ព្រះអង្គ ក៏ការលើកនេះមិនរំខានអ្វីខ្លាំងនោះឡើយដល់ពិធីព្រហ្មញ្ញសាសនាក្នុងព្រះរាជវាំង ព្រោះថាពិធីទាំងឡាយនោះ វាបានក្លាយរួចស្រេចទៅហើយជាទម្លាប់របស់រាជអាជ្ញា និងអំណាចរបស់ព្រះមហាក្សត្រ ដូចយើងបានរៀបរាប់ខាងលើរួចមកហើយថាលទ្ធិទេវរាជជាគ្រឹះនៃឯកភាពជាតិ និងអំណាចផ្តាច់ការរបស់ព្រះមហាក្សត្រខ្មែរជំនាន់អង្គរ ដែលព្រះអង្គទុកព្រះអង្គជាព្រះឥន្ទ្រ និងជា **បញ្ញាព្រះ**ផង ក្នុងឋានលោកិយ។ គំនិតបែបនេះ វាមានដូចក្នុងទ្រឹស្តីព្រះពុទ្ធសាសនាមហាយាន ដែលទុកព្រះពុទ្ធដែលបានត្រាស់រួចមកហើយនិងព្រះពុទ្ធដែលនឹងបានត្រាស់នៅក្នុងអនាគតកាល ជា **សេរីរៈគោរពធម៌តឹងរ៉ឹង**[83] ដែលមានឈ្មោះថា **ធម្មាកាយា** (Dharmakaya) ដែលគេទុកធម៌នេះ ជាឥរិយាបថរបស់ព្រះពុទ្ធ។

ក្នុងទស្សនៈនេះ គេទុកព្រះមហាក្សត្រ តាមអត្ថរស់របស់ព្រះអង្គជាព្រះ ជាធម្មាកាយា គឺថា ជាព្រះពុទ្ធជាម្ចាស់ដ៏មានមហានុភាព ដែលជាស្រមោលរបស់ព្រះពុទ្ធដ៏វិសេសវិសាល និងពោធិសត្វផង គឺ **ព្រះពុទ្ធលោកិស្សរ។** ក្នុងឋានៈនេះ ព្រះអង្គមានអំណាចអស្ចារ្យ និង អំណាចជា អធិធម្មជាតិ ក្នុងលោកិយ ជាអនុភាព ដ៏ឧត្តមនៃពុទ្ធធម៌សង្គ្រោះ។ បើយើងសង្ខេបក្នុងទស្សនៈនេះ គឺថាក្នុងព្រហ្មញ្ញសាសនាក្តី ក្នុងពុទ្ធសាសនាមហាយានក្តី ព្រះមហាក្សត្រខ្មែរក្នុងសម័យអង្គរ ព្រះអង្គទុកសេរីរៈព្រះអង្គជាតំណាងព្រះឥន្ទ្រ និងព្រះអរិយៈក្នុងរាជាណាចក្ររបស់ព្រះអង្គ បើយើងប្រៀបធៀបគំនិតនេះទៅនឹងនយោបាយដឹកនាំវិញ គឺថាព្រះអង្គប្រាថ្នាដណ្តើមយកតែម្នាក់ឯងនូវអំណាចដឹកនាំផ្តាច់ការ ដោយទុកវាថា មានធម្មានុរូប ចេញមកពីព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ព្រោះព្រះអង្គទុកខ្លួនជាបុគ្គលប្រកបដោយ ធម្មបីតិ ជា ព្រះអរិយៈ ដែលជា ម្ចាស់ របស់ អាណាប្រជានុរាស្ត្រ ប្រទេស និងជា មគ្គទេសក៍ នៃសាសនាជាតិ។

---

[83] សេរីរៈគោរពធម៌តឹងរ៉ឹង ; Corps mystique។

ភាពខុសគ្នាក្នុងលទ្ធិពុទ្ធសាសនាមហាយាន និងហិនយាន គឺថិតនៅត្រង់ថាមហាយាន ពោលអះអាងថានៅក្នុងលោកនេះមានព្រះពុទ្ធច្រើនអង្គ ចុះមកចាប់កំណើតក្នុងរូបកាយ **ព្រះពុទ្ធលោកិស្សរ** ជារូបកាយមនុស្ស ដែលជារូបកាយមានសណ្ឋានត្រៃសេរិរៈ(**Trikaya**) ដែលមាន **សារជាតិបីយ៉ាងខុសគ្នា**[84] ក្នុងសេរីរៈរបស់ព្រះពុទ្ធមួយអង្គៗ៖

១. **ធម្មាកាយា** (Dharmakaya) គឺជាឧត្តមសច្ចៈដែលជាសញ្ញានៃអត្តសញ្ញាណរបស់ពួកអ្នកមានសម្បជញ្ញៈសព្វកាល(ព្រះពុទ្ធ) ជាសេរីរៈរស់ជាអនន្ត ដាច់ខាត អ្វីដែលមានកើតឡើងគឺជាអត្ថរសព្រះពុទ្ធ ដូច្នេះគ្រប់អំពើទាំងឡាយដែលមានកើតឡើងក្នុងលោក គឺជាអំពើរបស់ព្រះអង្គ។

២. **សម្ភូរកាយា** (Sambhogakaya) ជាសេរីរៈប្រកបដោយកិត្តិគុណ និងប្រកបដោយភាពក្សេមក្សាន្ត របស់ព្រះពុទ្ធ។

៣. **នាគាកាយា**(Nirmakaya) ជាសេរីរៈរបស់ ព្រះ**សក្យមុនី** ដែលមនុស្សលោកយកតម្រាប់ ដើម្បីឲចេះយល់ធម្ម តាមបែបបទនៃពុទ្ធធម៌ ដើម្បីទុកក្នុងសតិជា**សន្និដ្ឋានចេតនា**(៧) **ព្រះសក្យមុនី** មិនមែនជាមនុស្សដូចមនុស្សលោកឯទៀតនោះឡើយ ព្រះអង្គជាស្រមោលរបស់ព្រះពុទ្ធអធម្មជាតិ និងនិព្វាន គឺជាការសំដែងជារូបធម្មតារបស់ព្រះអង្គគ្រប់ពេលវេលាក្នុងលោកតែប៉ុណ្ណោះ។ លទ្ធិត្រៃសេរីរៈ គេឃើញមានក្នុងចារិកសាស្ត្រជាច្រើន ជាពិសេសចារិកសាស្ត្រពីរសំខាន់ដែលមានសេចក្តីដូចខាងក្រោមនេះ៖

ទី១. សិលាចារិកនៅវិមានអាកាស៖

*«ខ្ញុំច្រៀងរៀបរាប់អំពីសេរីរៈតែមួយគត់ក្នុងលោកនេះ ត្បិតមានតែមួយ តែសេរីរៈនេះបែងចែកជាបី មាន**ធម្មាកាយា សេចក្តីត្រេកត្រអាលកាយា** និង**ការបង្កើត***

---

[84] Hypostase។

***កាយា*** *; ដោយមានសន្តិភាពពិតជាគោលល្អ កើតពីគុណធម៌ គឺការចាកចេញឲផុតពីទុក្ខគ្រប់បែបយ៉ាង»។*

ទី២. សិលាចារិកនៅភ្នំបន្ទាយណាង៖

*«ការរកក្តីដល់ឧត្តមសច្ចៈប្រៀបបាននឹងវេហា ដែលបានរំដោះទុក្ខបីយ៉ាងរបស់សត្វលោក ដើម្បីពាក់ជាថ្មីនូវសេរីៈបី មាន* ***ធម្មាកាយា សេចក្តីត្រេកត្រអាលកាយា*** *និង* ***ការប្រែប្រួលកាយា*** *»។*

ត្រូវដឹងថា គ្រឹះនៃទស្សនៈរបស់មហាយានអំពីការសង្គ្រោះមនុស្សលោក គឺមិនមែនថិតនៅការកំចាត់ចោលនូវ **អាត្មន**[85] របស់បុគ្គលដើម្បីនិព្វាននោះទេ ប៉ុន្តែធ្វើយ៉ាងណាឲវាមានលក្ខណៈដ៏ប្រសើរដូចព្រះពោធិសត្វ ដែលជាមាគ៌ា នៃការចេះដឹងធម៌ ដែលជាយាននាំបុគ្គលទាំងឡាយឲអាចក្លាយទៅជាព្រះពុទ្ធពិតប្រាកដ។ គ្រប់មនុស្សទាំងឡាយអាចត្រាស់ដឹងដូចព្រះពុទ្ធ ដោយយកមាគ៌ាព្រះអង្គជាគំរូស្វែងរកការរំដោះ តាមការខំប្រឹងប្រែងរបស់ខ្លួន ចេញផុតពីអាត្មនដែលជាប្រភពនៃ **អត្តទត្តភាព**[86] ដើម្បីឲខ្លួនក្លាយជាអរហន្ត នៅពេលនោះខ្លួនមិនត្រឹមតែអាចសង្គ្រោះខ្លួនឯងបាននោះទេ គឺអាចជាចំណែកមួយក្នុងការសង្គ្រោះសត្វលោក និងការបង្កើតអ្វីៗគ្រប់យ៉ាងសំរាប់មនុស្សលោក។

ទស្សនៈនេះឯង ដែលព្រះមហាក្សត្រ ជាពុទ្ធសាសនិកជន នៅសម័យអង្គរយកមកធ្វើជាគ្រឹះនៃអំណាចរបស់ខ្លួនចំពោះអាណាប្រជានុរាស្ត្រ ដែលនាំគ្នាទុកព្រះមហាក្សត្រ របស់ខ្លួនជាស្រមោលរបស់ព្រះពុទ្ធ ជាព្រះកំពូល លើអ្វីទាំងអស់ក្នុងលោក ហេតុនេះឯងបានជាព្រះមហាក្សត្រខ្មែរ ព្រះអង្គទុកខ្លួនជាតួអង្គព្រះពុទ្ធដ៏ប្រសើរ ជាពោធិសត្វមានអត្តរសជាសេរីៈគោរពធម្មាកាយាដូចព្រះពុទ្ធទាំងពួង។

---

85 អាត្មន= Individualité។
86 អអត្តទត្តភាព= អាត្មានិយម។

គេអាចទុកបានថា **ធម្មកាយា** ជាស្នូលនៃលទ្ធិថ្មីក្នុងរបបទេវរាជធិបតេយ្យ និយមព្រះពុទ្ធសាសនាមហាយានក្នុងសម័យអង្គរ ដូចគ្នានឹង **បញ្ញាព្រះ** ជាស្នូលនៃលទ្ធិរបបទេវរាជាធិបតេយ្យ និយមសាសនាព្រហ្មញ្ញនោះដែរ។ លទ្ធិទាំងពីរនេះមានគោលចេតនាដូចគ្នា គឺផានាដល់ព្រះមហាក្សត្រខ្មែរឲព្រះអង្គមានសេរីភាពគ្រប់បែបយ៉ាង ដើម្បីបំពេញតួនាទីជាអ្នកដឹកនាំប្រជាជាតិក្នុងផ្នែកសាសនា និងនយោបាយដឹកនាំរាជអាណាចក្រផង។ **ធម្មកាយ** ក្នុងនាមជា **ច្បាប់លោកធាតុ** ដែលមានព្រះមហាក្សត្រជា អាណត្តិគហក ហើយផ្តល់ជាវត្ថុធាតុសំរាប់បង្ហាញជាភស្តុតាងនូវភាពជាទេវរាជ ដែលមាននៅក្នុងបុគ្គលព្រះរាជា ហើយក៏ជាកសិណគ្រប់គ្រាន់សំរាប់ទុករាជាអំណាច និងលទ្ធិផ្តាច់ការរបស់ព្រះអង្គជាអំពើស្របច្បាប់នោះឯង។

## ក. ឯកភាពនៃច្បាប់លោកធាតុ ធម្មកាយា និងរាជាណាចក្រ

ដូចយើងធ្លាប់ជំរាបខាងលើរួចមកហើយថា នៅក្នុងសម័យរាជាអធិតេយ្យ និយមព្រហ្មញ្ញសាសនា អធិបតេយ្យនយោបាយដឹកនាំជាតិមានគ្រឹះនៅលើអធិបតេយ្យសាសនារបស់រាជាណាចក្រ។ ផែនទីនៃសាសនាក្នុងប្រទេសខ្មែរក្នុងជំនាន់នោះបែងចែកជាភាគតូចៗជាច្រើន ហើយឋិតនៅក្រោមអាជ្ញារបស់អាទិទេពខុសៗគ្នា ហើយអាទិទេពនិមួយៗជាម្ចាស់ទឹកដីរៀងៗខ្លួន ដូច្នេះការចាំបាច់ត្រូវមានការសម្របសម្រួលភាគតូចៗទាំងនោះ ដើម្បី យកមកដាក់ ក្រោមអង្គភាពនយោបាយតែមួយ ដែលជាអង្គភាពមានកម្លាំងអំណាចពេញទំហឹង ត្រួតលើអាជ្ញាតូចៗទាំងឡាយនោះ។ ដល់មកសម័យរាជាធិបតេយ្យ និយមពុទ្ធសាសនាមហាយានវិញ នៅពេលដែលព្រះមហាក្សត្រទុកធម្មកាយាជាអត្តរស់ខ្លួន ព្រះអង្គដែលជាសេរីរៈដើមមានក្នុង «**ធម្មវាចា**» របស់ព្រះពុទ្ធ ដែលព្រះអង្គបង្កើតឲស្របនឹងទំហំលោកធាតុដើម្បីសេចក្តីត្រូវការរបស់លោកធាតុ។ ក្នុងឋានៈជាព្រះធម៌ព្រះមហាក្សត្រខ្មែរនិយមមហាយាន យកឋានៈនេះមកធ្វើឲមាន **សមាបត្តិ**[87]ឯកភាពសាសនា ដើម្បីយកឯកភាពនេះទៅធ្វើឲសម្រេចឯកភាពនយោបាយក្នុងនគរ។

---

[87] សមាបត្តិ= ធ្វើឲបានសំរេច ; Réalisation។

ក្នុងឧបាយកលនេះ ស្ដេចកាន់ព្រះពុទ្ធសាសនាមហាយាន យកមកអនុវត្តក្នុងនយោបាយដឹកនាំរបស់ខ្លួនដោយតាំងខ្លួនឯងជានិមិត្តរូបឯកភាពជាតិ។ ស្ថាប័ននៃជំនឿលើ**ពុទ្ធរាជ** ត្រូវព្រះមហាក្សត្រ យកមកជំនួសជំនឿលើ**ទេវរាជ។** លទ្ធិទេវរាជ ក៏ដូច លទ្ធិពុទ្ធរាជ មាន**អភិមានៈ**[88] ដូចគ្នា ទុកខ្លួន ជាលទ្ធិសកល។

ក្នុងលទ្ធិពុទ្ធរាជនេះ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គយកវាមកធ្វើជាគ្រឹះនយោបាយដឹកនាំដើម្បីរក្សាឯកភាពជាតិ របៀបរយ និងវិន័យក្នុងសង្គមជាតិ មិនតែប៉ុណ្ណោះ ព្រះអង្គយកលទ្ធិនេះ មកបំរើនយោបាយវាតទឹកដី ដើម្បីកសាងមហានគរខ្មែរ។ លទ្ធិទេវរាជក៏ដូចពុទ្ធរាជដែរ មានអាការៈពីរ គឺជាទ្វេកម្លាំង៖

ទី១ ជាកម្លាំងឃ្លាតចាកមជ្ឈមណ្ឌល ដែលជាកម្លាំងអូសនយោបាយវាតទឹកដីនៃមហានគរខ្មែរ។

ទី២ ជាកម្លាំងចូលរកមជ្ឈមណ្ឌល ដែលជាកម្លាំងប្រមូលដែនដីដំបន់ទាំងឡាយឲមកថិតនៅក្រោមរាជទណ្ឌ។

ដើម្បីឲព្រះរាជាមានទ្វេកម្លាំងនេះ គេមានធ្វើពិធីស្រោចទឹក ពិសិដ្ឋថ្វាយព្រះរាជា ហើយទឹកពិសិដ្ឋ គេយកពីគ្រប់ទីកន្លែងក្នុងមហានគរ ស្រោចលើព្រះអង្គដើម្បីឲរូបព្រះអង្គក្លាយជា ជិវមជ្ឈមណ្ឌល នៃមហានគរខ្មែរ។ ក្នុងសិលាចរិកនៅប្រាសាទព្រះខាន់មានចារថា៖

*« រៀងរាល់ថ្ងៃព្រាហ្មបុរោហិតយកទឹកដែលព្រះសុរិយាមានា ព្រះរាជានគរជ្វា យួន ចំប៉ា (មានស្ដេចពីរព្រះអង្គ) មកធ្វើពិធីជំរះកាយព្រះបាទជ័យវរ្ម័នទី៧ ដែលជាមហាក្សត្រមានអធិរាជភាពលើនគរទាំងឡាយនោះ »*។

---

[88] អភិមានៈ= Universalité។

ឯកភាពសាសនា ឯកភាពនយោបាយដឹកនាំជាតិ ដែលយកគ្រឹះលទ្ធិពុទ្ធរាជ និង ធម្មាកាយាជាពំនឹង ជាលទ្ធិផ្តល់ជាវត្ថុធាតុសំរាប់ធ្វើនិមិត្តរូបចំបាច់នៃអារ្យធម៌ និង ជំនឿខ្មែរនៅក្នុងសម័យអង្គរ និយមពុទ្ធសាសនាមហាយាន។

**ខ. ធម្មានុរូបនៃអំណាចរាជានិយម ទស្សនៈដែលទុកព្រះរាជាជាអ្នកសង្គ្រោះមនុស្សជាតិ**

គេឃើញមានក្នុងលទ្ធិពុទ្ធសាសនាមហាយាន ដែលរាជាធិតេយ្យ យកមកធ្វើជាសម្បទាននយោបាយដឹកនាំជាតិ ទុកសណ្តាប់ធ្នាប់មនុស្សលោក ជាសណ្តាប់ធ្នាប់មួយ មានធម្មជាតិដូចជាសណ្តាប់ធ្នាប់សាកលលោក ហើយវាដើរស្របគ្នាជានិច្ច។ ច្បាប់លោកធាតុដែលជាច្បាប់អភិបាលលើសណ្តាប់ធ្នាប់មនុស្សលោកក្នុងព្រហ្មណ៍ធម្ម ដែលមាន **បញ្ញាព្រះ** (ព្រះបូជា ដែលមានកម្លាំងស្មើនឹងព្រះឥន្ទ្រ) ជាគ្រឹះនេះត្រូវបានគេយកពុទ្ធធម៌មកជំនួសវិញ។ ដូចយើងដឹងរួចហើយ គេទុកធម្មាកាយាជាការសំដែងរូបនៃព្រះពុទ្ធដ៏វិសេសវិសាល ហើយជូនការព្រះអង្គមានឈ្មោះជា «បីតាសត្វលោក»។

ព្រះមហាក្សត្យខ្មែរ ដែលព្រះអង្គរំលាយអត្តរសរបស់ព្រះអង្គក្នុងធម្មាកាយា ដែលជាធម្ម នៃព្រះពុទ្ធទាំងឡាយ ក៏ក្លាយតាមរបៀបនេះ ជាស្រមោលរបស់ព្រះពុទ្ធអធិធម្មជាតិតែម្តង ហើយក្នុងឋានៈនេះ ព្រះអង្គបានទទួលអំណាចពីព្រះពុទ្ធដើម្បីថែរក្សាការប្រព្រឹត្តល្អរបស់សត្វលោក និងរក្សាសន្តិភាពក្នុងលោកិយនិងសុខដុមក្នុងសាកលលោក។ ទស្សនៈនេះគ្មានអ្វីខុសផ្លែកពីទស្សនៈព្រហ្មញ្ញសាសនានោះឡើយ តែពុទ្ធសាសនាមិនយកការបូជា និង **វិតីវាចា**[89] មកធ្វើជាពិធីសាសនារបស់ខ្លួននោះទេ។ ចំពោះពុទ្ធសាសនាមហាយាន មានតែធម័ព្រះពុទ្ធមួយគត់ដែលគេទុកជាអត្តរសរបស់សាសនា ហើយគេនាំគ្នាលើកធម៌នេះស្មើនឹង **គំនិតទូទៅ**[90]

---

89 វិតីវាចា= Parole rituel។
90 គំនិតទូទៅ= Concept។

នៃ **បរមត្ថវិជ្ជា**[91]។ ទ្រឹស្តីនេះ ជាមួយគ្នានឹងទ្រឹស្តីការវិវឌ្ឍន៍របស់ **ចក្ររាសីនៃលោក**[92] គេទុកបុគ្គលស្តេចជាអ្នកដឹកនាំជាតិ និងមនុស្សហើយដើម្បីការពារប្រយោជន៍រួម ព្រះអង្គត្រូវមានអំណាច ប្រើវាដើម្បីបង្ក្រាបភាពឥតសណ្តាប់ធ្នាប់ និងកំចាត់ទុគិតភាព។ ពុទ្ធសាសនាមហាយាន ក៏ដូចព្រហ្មញ្ញសាសនាដែរ មានជំនឿថា ការវិវឌ្ឍន៍ នៃមនុស្សជាតិមិនមានលក្ខណៈជាការវិវឌ្ឍន៍ត្រង់ដូចបន្ទាត់នោះទេ ប៉ុន្តែជាការវិវឌ្ឍន៍តាមរបៀបកាឆ្លាស់គ្នា។ វឌ្ឍនភាពនៃមនុស្ស ក្នុងដំណើររួមគ្នា គឺគ្មានទីបញ្ចប់នោះឡើយ ដូចគេឃើញក្នុងប្រវត្តិសាស្ត្រមានការប្រែប្រួលខ្លាំង ការវិករ បន្តក្នុងចក្ររាសី នៃវិបុលភាព រួចហើយមានការត្រឡប់ចុះឡើងឥតមានឈប់ពីទុក្ខទៅសប្បាយ ហើយពីសប្បាយមកទុកវិញរបស់មនុស្សលោក ហេតុនេះឯងហើយ បានជាប្រជារាស្ត្រចង់មានអ្នកការពារខ្លួននៅចំពោះមុខដំណើរប្រែប្រួលនេះ ហើយអ្នកការពារនោះគឺគ្មាននរណាក្រៅពីព្រះមហាក្សត្រ។ សុវណ្ណកាល នឹងអាចដល់បាន សំរាប់មនុស្សជាតិ នៅពេលណា **ព្រះទុចិត្តា** (**Tusita**)ជាអ្នកធ្វើឲស្រាកទុក និង**ព្រះមេត្រីយ** (**Maitreya**) ព្រះអង្គចុះពីឋានសួគ៏មកជួយរំដោះទុក្ខមនុស្សលោក។ នៅពេលដែលព្រះអង្គពុំទាន់យាងចុះមក គឺព្រះមហាក្សត្រប្រកបដោយធម៌ ជាស្តេចនាថ ដែលត្រូវប្រជារាស្ត្របានតែងតាំងព្រះអង្គក្នុងមុខនាទីជាអ្នកការពារខ្លួន និងសត្វលោក ទ្រង់ជាតំណាងព្រះពុទ្ធពីរអង្គនេះ។ ក្នុងគំនិតនេះ លោក Paul Mus បានសរសេរថា៖

« *នៅពេលដែលព្រះបាទជ័យវរ្ម័នទី៧ប្រកាសថា ព្រះអង្គនឹងជំរះបាបកម្មឲអស់ពីលោកនេះ ដោយមិនមានការបារម្ភណ៏អ្វីបន្តិចសោះអំពីភាពកំណាចនៃពេលវេលា គឺច្បាស់ជាព្រះអង្គទុកព្រះអង្គជាឧត្តមអ្នកជួយសង្គ្រោះ ដែលមានអត្តរស់ជាព្រះពុទ្ធនោះឯង ដូចគេឃើញមានចារលើសិលាចារិនៅប្រាសាទតាព្រហ្មណ៏ថា៖មាតារបស់ព្រះបាទជ័យវរ្ម័ន៏ទី៧ជាប្រាជ្ញាព្រះមាតា គឺជាជាមាតារបស់ព្រះពុទ្ធ ដូចគ្នា*

---

91 បរមមត្ថវិជ្ជា= ការស្រាវជ្រាវតាមវិចារណញ្ញាណលើចំណោះនៃសត្វលោក មានវិញ្ញាណ ធម្មជាតិ អាទិទេព មូលហេតុ នៃសាកលលោក ; Métaphysique។
92 ចក្ររាសីនៃលោក= Cycle du monde។

*នេះដែរ លើសិលាចារិកនៅប្រាសាទព្រះខាន់ មានចារថា ជ័យពុទ្ធា ជាឧត្តមអ្នកសង្គ្រោះរាស្ត្រ»។*

ក្នុងទស្សនៈទុកព្រះរាជាជាអ្នកសង្គ្រោះរាស្ត្រនេះ ដែលនាំឲប្រជារាស្ត្រទទួលស្គាល់ថា អំណាចផ្តាច់ការព្រះមហាក្សត្រខ្លួនជាអំណាចស្របពុទ្ធធម៌ បើស្របពុទ្ធធម៌ គឺពិតជាស្របច្បាប់នោះឯង។

**គ. អំណាចផ្តាច់ការនិយម**

របបរាជាធិតេយ្យ និយមពុទ្ធសាសនាមហាយាន ទុកធម៌ព្រះពុទ្ធជាប្រភពគ្រប់ច្បាប់នៃមនុស្សលោក ក្នុងវិស័យសីលធម៌ក្តី គតិយុត្តក្តី។ ដោយយកពុទ្ធធម៌ជាអត្ថរសរបស់ខ្លួន ពុទ្ធស្តេចទុកព្រះអង្គស្មើនឹងពុទ្ធធម៌ គឺថាជាស្តេចនៃច្បាប់ហើយទទួលស្គាល់តែពុទ្ធធម៌ជាធម៌ដែលទុកជាកំរិតនៃអំណាចរបស់ព្រះអង្គ។ ការទុកពុទ្ធធម៌ជាអធិភាពលើអំណាចខ្លួននេះ ក៏ជាការប្រកាស ជាមួយគ្នាដែរថាអំណាចផ្តាច់ការស្តេច ជាអំណាចនយោបាយដឹកនាំជាតិ តែមួយគត់ឥតមាននរណាប្រកែកបាន ដូច្នេះរាជាអាជ្ញា គឺគ្មានលក្ខណៈជាអាជ្ញាបំពានទៅលើសិទ្ធិសេរីភាពរបស់អាណាប្រជានុរាស្ត្រនោះឡើយ ព្រោះថារាជាអាជ្ញានេះជាពុទ្ធធម៌។ ការពិតក្នុងការទាក់ទងរវាងព្រះរាជាជាមួយនឹងបព្វជិត គឺឋិតនៅត្រឹមកំរិតការទាក់ទងក្នុងវិស័យសាសនាតែប៉ុណ្ណោះ ដូច្នេះនៅចំពោះមុខរាជាអំណាច គឺគ្មានអំណាចទីពីរណាមួយ អាចមានទម្ងន់ស្មើនឹងវានោះឡើយ។ កំរិតនៃអំណាចផ្តាច់ការរបស់ស្តេចគឺជាស្វ័យកំរិត គឺថាក្នុងការិយាកម្មនៃអំណាចនេះ គឺវាគ្មានអ្វីអាចកំរិត ហាមស្តេច មិនឲធ្វើអ្វីមួយបាននោះឡើយ។

ពិតមែនគេឃើញមាននៅក្នុងរាជា **បសំសកថា**[93] សរសើរថា ព្រះរាជាប្រកាសដោយខ្លួនថា ព្រះអង្គជាស្តេចគោរពធម៌ ហើយធ្វើតាមសិក្ខាបទឥតខ្ចោះរបស់ព្រះ

[93] បសំសកថា= សុន្ទរកថាសរសើ ; Panégyrique។

ពុទ្ធ តែតាមការពិតវិញ ការសរសេរសរសើរនេះ គឺឋិតនៅត្រឹមជាអក្សរសាស្ត្រដែលគេសរសេរឡើងសំរាប់ចតែច ពីរោះស្តាប់តែប៉ុណ្ណោះ។

គេដឹងថា គ្រប់អំណាចផ្តាច់ការមាននៅក្នុងជាតុខ្លួនជានិច្ច នូវការរំលោភ និងអំពើកំណាច ទៅលើមនុស្ស ដូច្នេះអំណាចនេះ វាមានភាពផ្ទុយស្រឡះពីឱវាទរបស់ព្រះសម្មាសម្ពុទ្ធ។ ដូចយើងដឹងថារាជាអំណាចជាអំណាចឥតមានកំរិត ដូច្នេះអំណាចនេះ មានធម្មជាតិជាអំណាចផ្តាច់ការ ព្រោះថាជាអំណាចឥតបញ្ញាចំរើននៃព្រះមានព្រះភាគ ដែលទ្រង់មានភាគនៃអត្ថរស ធម្មរស វិមុត្តិរស អធិសីល អធិចិត្ត និងអធិបញ្ញា។

## ២.សម័យក្រោយអង្គរ សម័យពុទ្ធសាសនាហិនយាន

នៅស្រុកខ្មែរ ចាប់ផ្តើមពីសតវត្សទី១៤មក ពុទ្ធសាសនាមហាយាន បានត្រូវគេប្តូរ យកពុទ្ធសាសនាហិនយាន ដែលជាលទ្ធិសាសនាជិតនឹងលទ្ធិដើមរបស់ព្រះសម្មាសម្ពុទ្ធ មកជំនួស។ លទ្ធិហិនយាន ដែលមានដើមកំណើតនៅប្រទេសសេរីលង្កា ដែលគេយកភាសាបាលីជាយាន សំរាប់សិក្សាធម៌ព្រះពុទ្ធ។ លទ្ធិនេះមានឈ្មោះថាលទ្ធិ «**ទេរតា**»។

ទិដ្ឋភាពនៃលទ្ធិថ្មីនេះ វាខុសគ្នានឹងលទ្ធិចាស់ គឺថា មហាយានចសេរះសំខាន់ទៅលើ **បរិកប្ប**[94] **បរមត្ថវិជ្ជា** ដែលជាទិដ្ឋភាពមួយដូចមានក្នុងព្រហ្មញ្ញសាសនា គឺថាគេទុកព្រះពុទ្ធជា **អតិសេដ្ឋជន**[95] **អធិធម្មជាតិជន**[96] **ធម្មាកាយា** ដែលជាសេរីរៈនៃវាចាទូន្មានអប់រំរបស់ព្រះពុទ្ធ ត្រូវបានពួកបព្វជិតមហាយាន យកមកធ្វើជាសេរីរៈធម៌វិន័យ ដែលមានកំរិតតឹងរ៉ឹងបំផុត។ ក្នុងគំនិតនេះពួកគេពន្យល់ថា ការស

---

[94] បរិបក្ប= ការសិក្សាខាងទ្រឹស្តី. Spéculation។
[95] អតិសេដ្ឋជន= ឧត្តមជន ; Etre transcendant។
[96] អធិធម្មជាតិជន= Etre surnaturel។

ង្គ្រោះមនុស្សលោកមិនមែនទូន្មានឲមនុស្សស្វែងរកឋាននិព្វាននោះទេ គឺទូន្មានអាត្មា តាមផ្លូវធម៌ ដើម្បីបំបាត់ **ទោសៈ មោហៈ មានៈទិដ្ឋិ កាម កិលេស** ។ល។

ក្នុងទស្សនៈហិនយាន គេទុកបុគ្គលលក្ខណៈរបស់ព្រះពុទ្ធជាមនុស្សលោកធម្មតា មានអនុភាពក្នុងចិន្តា និងមានវិចារណាកិច្ចពិសេស ដែលនាំឲការទាក់ទងរវាងព្រះរាជានឹងរាស្ត្រ ឥតមានសភាពតឹងរ៉ឹង ដែលជាការបង្កើតមូលដ្ឋានមេត្រីភាព ប្រកបដោយសេចក្តីស្ងប់កើតមកពីសន្តិភាពត្រឹមត្រូវតាមសីលធម៌។ ក្នុងការទាក់ទងនេះ ព្រះរាជា លែងទុកព្រះអង្គជាស្រមោលនៃ «អ្នកសង្គ្រោះរាស្ត្រដ៏ឧត្តម» ផ្ទុយទៅវិញ ទ្រង់ទុកខ្លួនព្រះអង្គ ជាមនុស្សដូចមនុស្សដ៏ទៃទៀត ឥតកំណាញ់វណ្ណៈ ដែលជាបុគ្គលបានទទួលគុណូបការជាផល បានមកពីការប្រព្រឹត្តអំពើល្អពីជាតិមុនៗ ដែលនាំឲព្រះអង្គកើតក្នុងជាតិថ្មី ក្នុងស្ថានភាពខ្ពស់លើមនុស្សទាំងឡាយ ប្រកបដោយសុក្រឹតភាពខ្លាំងទៀត អាចឲព្រះអង្គពាក់ងារ ជា «ព្រះធម៌» ដែលជាអ្នកការពារអាណាប្រជានុរាស្ត្រ រស់ក្នុងសង្គមពុទ្ធបរិស័ទ ដែលមានព្រះអង្គជាមគ្គទេសក៏ ដូចគ្នានៅក្នុងវត្តអារាម ដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គបានទូន្មានដល់សមណៈទាំងឡាយ ឲចេះគោរពគ្រូអាចារ្យខ្លួនដូចជាបិតា។ បើព្រះរាជា ជាព្រះធម៌ ដូច្នេះព្រះអង្គ ជាបិតារបស់ពុទ្ធបរិស័ទនោះឯង ដូច្នេះការទាក់ទងរវាងព្រះរាជានឹងពុទ្ធសាសនិកជនទាំងឡាយក្នុងនគរ គឺជាការទាក់ទងឈរលើភក្តីភាព។ ក្នុងគំនិតនេះ ប្រជាពលរដ្ឋខ្មែរ គាត់ទុកព្រះមហាក្សត្រ ជាបិតា ដែលជាមនុស្សមានអត្តរសប្រសើរ ដែលជាបិតាបានទទួលរាជសម្បត្តិកើតពីគុណូបការ របស់ព្រះអង្គដែលទ្រង់បានសាងពីជាតិមុនៗមក។គំនិតស្តេចជាបិតា របស់រាស្ត្រ ត្រូវបានអ្នកតែងច្បាប់ គេកត់ទុកក្នុងមាត្រា៤៧នៃ «**ក្រមស្រុក**» ហើយគេឃើញមានដែរក្នុងឃ្លាមួយនៃច្បាប់ «**ត្រៃភូមិ**» ដែលមានចែងថា៖

«*ប្រជារាស្ត្រដឹកនាំដោយស្តេចដែលជាបិតា ដែលជាវ័រ្ងន័ ជាពុទ្ធសាសនិជន ទុកធម៌ជាករណីយកិច្ច យកបព្វជិតជាទីប្រឹក្សាសំរាប់នាំផ្លូវឲដើរតាមកន្លងធម៌វិន័យ និងធ្វើបដិបត្តិគឺចំរើនធម៌ដើម្បីសំរេចនូវធម៌ដែលរំលត់កិលេស រំលត់ទុក្ខ*»ដូច្នេះស្តេចល្អ គឺជាស្តេចមាន**ទសពិធធម៌**៖

សេចក្តីសប្បុរស (Dana) គុណធម៌ ឬសីលធម៌ (Sila) ភក្តីភាព ឬ អត្តពលកម្ម (Pariccaga) សេចក្តីទៀងត្រង់ (Ajjava) ចិត្តល្អ និងសេចក្តីអាសូរ (Maddava) សេ

ចក្តីតឹងរ៉ឹង (Tapa) ភាពស្ងប់ (Akkodha) អហិង្សា (Avihimsa) ខន្តី (Khanti) **អនាគតិ**[97] (Avirodhita) ។

គេមើលឃើញថានៅស្រុកខ្មែរ ពុទ្ធធម៌ គ្មានឥទ្ធិពលទៅលើ របនាសម្ព័ន្ធសង្គមនោះទេ ដែលជាសង្គមមានធាតុជាសង្គមសក្តិភូមិ ដែលអ្នកដឹកនាំ គេខំថែរក្សាវាឲថិតថេរជានិច្ច ដើម្បីការពារបុព្វសិទ្ធិរបស់ពួកគេ ដែលជាពួកកំណាញ់វណ្ណៈ។ក្នុងអំពើនេះ ពុទ្ធធម៌ គ្មានសារៈសំខាន់អ្វីបន្តិចឡើយចំពោះពួកគេ។ ពិតមែនមានព្រះរាជាខ្មែរ បានយកលទ្ធិហិនយានមកគោរពបូជាដោយបដិបត្តិបូជាដែលនាំឲព្រះអង្គក្លាយជា វរៈក្សត្រ ប៉ុន្តែបើយើងបានសិក្សាអំពីប្រវត្តិសាស្ត្រជាតិខ្មែរ យើងឃើញថា ព្រះមហាក្សត្រ ប្រភេទបែបនេះមានភាគតិចបំផុត។ មហាក្សត្រខ្មែរមួចំនួនធំ ព្រះអង្គបានដឹកនាំព្រះនគរ តាមវិធីផ្តាច់ការ តាមភាពកំណាច ជួនកាលរហូតដល់ប្រើអំពើគតមនុស្សធម៌ ដែលនាំឲប្រជារាស្ត្រកើតសេចក្តីក្តៅក្រហាយក្នុងសតិ រស់ក្នុងទុក្ខ ទុកការប្រកាសរបស់ស្តេចខ្លួនថាព្រះអង្គជាបិតារបស់ប្រជារាស្ត្រ ជា **វញ្ជនការ**[98] ហើយជួនកាល រហូតហ៊ានធ្វើកុបកម្មប្រឆាំងនឹងស្តេចតែម្តង។

ការរំលោភ និងអំពើកំណាចលើប្រជារាស្ត្រគឺពុំអាចកាត់ចេញបានពីប្រព័ន្ធផ្តាច់ការខ្មែរបាននោះឡើយ មិនថាឡើយ ក្នុងរបបរាជាធិបតេយ្យនិយមព្រហ្មញ្ញសាសនា ឬ និយមពុទ្ធសាសនា សូម្បីក្នុងរបបប្រជាធិបតេយ្យ អាស្រ័យរដ្ឋនុញ្ញបច្ចុប្បន្ន ក៏នៅតែមានការរំលោភ និងអំពើកំណាចលើប្រជារាស្ត្រជានិច្ច ព្រោះថាអំណាចផ្តាច់ការនៅស្រុកខ្មែរ វាមាននៅក្នុងធម្មជាតិរបស់សង្គមខ្មែរ ដែលជាកត្តាលំបាកមួយក្នុងការសាងលទ្ធិប្រជាធិបតេយ្យ។ យើងឃើញច្បាស់ ទោះស្តេចមិនស្តេច អ្នកដឹកនាំខ្មែរនៅពេលណាខ្លួនមានអំណាច តែងតែមានសភាវគតិជាតិរប្បានជានិច្ច ប្រើអំណាចសំរាប់ការពារប្រយោជន៍ខ្លួនតែប៉ុណ្ណោះ ហើយធ្វើប្រជាភិថុតិ យកសាសនាជាឧបាយកលរបស់ខ្លួន សំរាប់ជាជំហរនិងបិទបាំង

---

[97] អនាគតិ= Impartialité។
[98] វញ្ជនការ= អាការបោកប្រាស។

អំណាចផ្តាច់ការរបស់ខ្លួន។ ការនេះជាទុក្ខធំសំរាប់ប្រជាជាតិខ្មែរ ដែលធ្វើឲជាតិខ្មែរគ្មានពន្លឺ មិនរុងរឿង ដែលនាំឲប្រជាពលរដ្ឋមិនយល់ច្បាស់ មិនប្រាកដអំពីសិទ្ធិរបស់ពលរដ្ឋ។

# ជំពូក ទី២ - រដ្ឋខ្មែរ ហើយនឹង ការរៀបចំក្នុងសម័យដើម

## ផ្នែកទី១

## គំនិតទូទៅនៃរដ្ឋខ្មែរ

យើងបានដឹងរួចហើយថាអំណាចស្តេច ក្នុងសម័យដើមជាប្រព័ន្ធអំណាចផ្តាច់ការ និយមអាទិទេព ដែលជាអំណាចផ្អែកលើច្បាប់លោកធាតុ ដែលមានស្តេចជាប្រតិភូ ជាអ្នកដឹកនាំរដ្ឋដោយ យក ឬក៏[99] ព្រហ្មណ៍ធម៌ ឬក៏ ពុទ្ធធម៌ ជា ពាំនឹងអំណាច ទៅតាមជំនឿសាសនារបស់ស្តេច។

ការនេះបង្ហាញឲយើញថា ការរៀបចំរាជអាជ្ញាក្តី រចនាសម្ព័ន្ធអំណាចក្តី ការបែងចែកមុខងារ ដូចជាមុខការប្រតិបត្តិ តុលាការ ជាពិសេសផ្នែកបញ្ញាតិ ឋិតនៅក្នុង **អនិស្សរភាព**[100] នៃធម៌សាសនារបស់ព្រះរាជា និងការសម្របសម្រួលជាមួយនឹងជំនឿប្រជារាស្ត្រនៅតាមដំបន់នានា ដើម្បីរក្សាឯកភាពជាតិ។ គេសួរជាសំណួរពីរថា៖

១. តើនរណាជាម្ចាស់អំណាចពិតក្នុងរាជាណាចក្រ ព្រះមហាក្សត្រ ? ឬ ស្ថាប័នរដ្ឋ ?

[99] ឬក៏= Soit។
[100] អនិស្សរភាព= នៅក្នុងចំណុះ ; Dépendre។

២. តើការរៀបចំរដ្ឋ និងការរៀបចំអំណាចស្តេច តើការរៀបចំ ណាមួយដែលមានភាពខ្ពស់ជាងគេ ?

បើយើងយកទ្រឹស្តីសុទ្ធ របស់រាជអំណាចមកបកស្រាយ យើងឃើញថាអធិបតេយ្យនៃស្តេច គ្រាន់ជាអធិបតេយ្យជារាជប្រតិភូតែប៉ុណ្ណោះ ព្រោះថាអធិបតេយ្យនេះវាឋិតនៅក្នុងអនិស្សរភាពច្បាប់លោកធាតុ។ ក្នុងចំណុចនេះ គេអាចសួរជាសំណួរបានទៀតថា តើនរណាជាអ្នកប្រគល់អធិបតេយ្យនេះដល់ព្រះរាជា ?

បើយោងតាម **សិទ្ធិបញ្ញការ**[101] របស់ស្តេច ដែលអាទិទេពថ្វាយព្រះអង្គ ដែលគេទុកវាជា **និតិអត្តនោម័តិ**[102] របស់ព្រះអង្គ ដែលជាច្បាប់ រស់និត្យនៅក្នុងតែគំនិតព្រះអង្គផ្ទាល់ និង **អាជ្ញាគតិយុត្ត**[103] របស់ព្រះអង្គ ជាអំណាចព្រះរាជា ដែលព្រះអង្គមានបំណងក្នុងគំនិត ឲគ្រប់ស្តេច ស្នងរាជ្យ បន្តពីព្រះអង្គ នាំគ្នាគោរពអំណាចនេះជានិច្ច គេអាចសន្និដ្ឋានបានថា ដោយផ្អែកលើសិទ្ធិ និងអាជ្ញាខាងលើនេះ អ្នកដែលប្រគល់អធិបតេយ្យដល់ស្តេចគឺស្តេចខ្លួនឯងតែម្តង។

តែបើគេទុក **រាជ្យ**[104] ជាវត្ថុពិតអរូប មាននិច្ចភាព ហើយជាវត្ថុវិសេសវិសាល (អតិសេដ្ឋ) ដែលមានបុគ្គលស្តេចជាតំណាង ដែលជាបុគ្គលមិនឋិតថេរ ដូចមនុស្សធម្មតា មានតួនាទីក្នុងតំណែងស្តេចជាអ្នកបង្គាប់ ដូច្នេះ **អាជ្ញាគតិយុត្ត** របស់ព្រះអង្គ ដែលព្រះអង្គបានតាក់តែងឡើងក្នុងរជ្ជកាលព្រះអង្គ មិនអាចឋិតថេរបាននោះឡើយ បើគ្មាន **រាជ្យ** ដែលជាអង្គភាពមានលក្ខណៈជានិច្ចភាព ជាអ្នករក្សា **អាជ្ញាគតិយុត្ត**ស្តេច ដូច្នេះគេអាចសន្និដ្ឋានបានថារាជ្យ ជាអធិបតេយ្យរបស់ជាតិ ហើយបានប្រគល់អធិបតេយ្យនេះ ដល់ព្រះរាជា។

---

101 សិទ្ធិបញ្ញាការ= Droit de commendement។
102 នីតិអត្តនោម័តិ= ច្បាប់ដែលមាននៅតែក្នុងគំនិត ; Droit subjectif។
103 អាជ្ញាគតិយុត្ត= Ordonnancement juridique។
104 រាជ្យ= Royauté។

ក្នុងចំណុចនេះលោក G. Coedès អ្នកប្រវត្តិសាស្ត្របារាំង បានធ្វើការបកស្រាយដូចតទៅ៖

ក្នុងសម័យអង្គរ (សតវត្សទី៩) សម័យដែល ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០)បានធ្វើ **ប្រត្យាស្ថាប័ន**[105] មហានគរខ្មែរបានឡើងវិញ ហើយនិងការបង្កើតជំនឿថ្មីសំរាប់ជាតិខ្មែរ មានឈ្មោះថាជំនឿ"**ទេវរាជ**"ក្នុងគោលបំណងយក **រាជ្យ** ដែលជាអង្គភាពមាននិច្ចភាព មកធ្វើជាមធ្យោបាយ សំរាប់ធ្វើឲ វង្សសក្តារបស់ព្រះមហាក្សត្យខ្មែរ ដែលសុទ្ធជា **អនិច្ចបុគ្គល**[106] ដូចជាមនុស្សឯទៀត ឲមានលក្ខណៈជានិច្ចភាពដូច **រាជ្យ** គឺជាការបង្កើតអត្ថរស នៃរបបរាជានិយមខ្មែរ ដូច្នេះទង្វើនេះមិនមែនជាសកម្មភាពធម្មតា ហើយគ្រាន់ជាការកាត់ស្មានយល់ក្នុងវិញ្ញាណរបស់អ្នកប្រវត្តិសាស្ត្រនោះទេ ព្រោះគេឃើញមានចារទុកលើសិលាចារិកខ្មែរជាច្រើនដូចនៅប្រាសាទកោះកែ បញ្ជាក់ថា *«ម្ចាស់នៃលោកគឺរាជ្យ»* ដូច្នេះស្តេចគ្រាន់ជាអ្នកបន្ត ក្នុងមុខងារព្រះអង្គ នូវនិច្ចភាព របស់ **រាជ្យ** តែប៉ុណ្ណោះ។

ក្នុងទស្សនៈនេះ គេឃើញមានដែរនៅក្នុងទ្រឹស្តីនៃ «**រដ្ឋខ្មែរ**» ដែលជាអង្គភាពឈរលើអត្ថរសនៃ **រាជ្យ** ដែលជា **ហេតុនៃនិតិសិទ្ធកម្ម**[107]។ ការយកនិច្ចភាពនៃ **រាជ្យ** មកធ្វើជាគោលការណ៍នេះ គឺគ្មានអ្វីក្រៅពីមានគោលបំណងចង់ **ចាក់ឫសសំណង់គតិយុត្តជាតិ**[108] ដែលលគេទុកជាការគោលការណ៍ នៃ **និតិរដ្ឋ** ខ្មែរ ក្នុងសម័យអង្គរ។

សិលាចារិកនៅភ្នំបាខែង ជាកសិណ នូវលក្ខណៈ និច្ចភាពនៃ **រាជ្យ** ដែលមានសេចក្តីដូចតទៅ៖

*«ក្នុងឆ្នាំដែលព្រះបាទជ័យវរ្ម័នទី៥ (៩៦៨-១០០០) បានឡើងគ្រោងរាជសម្បត្តិបន្តពីព្រះបាទរាជេន្ទ្រវរ្ម័នទី២(៩៤៤ ៩៦៨) ព្រះអង្គបញ្ញាឲរាជេន្ទ្រាភិបាលប្រថាប់គ្រា*

---

[105] ប្រត្យាស្ថាប័ន= ការស្ថាបនាឡើងវិញ ; Restaurer។
[106] អនិច្ចបុគ្គល= បុគ្គលដែលត្រូវតែទទួលអនិច្ចកម្ម។
[107] ហេតុនៃនិតិសិទ្ធកម្ម= Sujet de droit titulaire។
[108] ចាក់ឫសសំណង់គតិយុត្តជាតិ= Fonder l’édifice juridique national។

*ទុកជាផ្លូវការគ្រប់រាជកិច្ចរបស់ **រាជបុញ្ញាការី**[109] ព្រះអង្គ ទុកជាច្បាប់ជាធរមានសំរាប់រជ្ជកាលរបស់ព្រះអង្គ»។*

ដោយគ្មានរដ្ឋធម្មនុញ្ញ នៅជំនាន់នោះ ជាអ្នកជានារក្សានូវនិច្ចភាពនៃ **អាជ្ញាគតិយុត្ត**ស្ដេច ដូច្នេះរាល់រជ្ជកាលថ្មី អាជ្ញានេះ វាគ្រាន់តែមានតម្លៃត្រឹមតែជាតម្លៃ « **កាតព្វកិច្ចជាសីលធម៌**» របស់ **ព្រះរាជា**[110] ថ្មី តែប៉ុណ្ណោះ ព្រោះថាព្រះអង្គជា **តួអង្គជីវន្ត**[111] នៃរដ្ឋ ដែលជាតំណាងថ្មីនៃ **រាជ្យ**។ ប្រព័ន្ធនៃរបបផ្ដាច់ការនិយមអាទិទេព ជាប្រព័ន្ធមាន **ហេតុនៃនិតិសិទ្ធកម្ម** តែមួយគត់ គឺរាជាអំណាច និង**អនុសាធ្យ**[112] របស់វា ដែលគេទុក ជា **សិទ្ធិបញ្ញការ** កំពូលរបស់ស្ដេច។ ដូច្នេះអំណាចស្ដេច ក្នុងសម័យអង្គរ ជា **អំណាចបុគ្គលផ្ទាល់**[113] តែអំណាចនេះ គេយក**រាជ្យ** មកធ្វើគោលការណ៍របស់គេ ដែលជាគោលការណ៍អរូបី មានលក្ខណៈនិច្ចភាពដើម្បីឲខ្លួន មាននិច្ចភាពដូច **រាជ្យ**។

ក្នុងរបបនេះ គេឃើញមានគំនិតធំពីរ ដែលអាចយកមកបញ្ជាក់បានថាក្នុងសម័យអង្គរ ប្រជាជាតិខ្មែរ មានទ្រឹស្ដី នៃ **រដ្ឋ** ពិតប្រាកដ ទោះបីទ្រឹស្ដីនោះមានភាពលាយឡំគ្នាជាមួយនឹង **អំណាចបុគ្គលផ្ទាល់** របស់ព្រះរាជាក៏ដោយ។ គេសួរថា តើរដ្ឋមាន **អត្ថន័យគតិយុត្ត** ដូចម្ដេច សំរាប់សំគាល់ «**សញ្ញាណ**» របស់ខ្លួនក្នុងប្រព័ន្ធដឹកនាំក្នុងសម័យអង្គរ ?

ក្នុងវិទ្យាសាស្ត្រគតិយុត្ត និងវិទ្យានយោបាយ គេឲអត្ថន័យទៅលើ **រដ្ឋ** ថាជាផលិតផល នៃសង្គមក្នុងដំណាក់មួយនៃការលូតលាស់ ជាមធ្យោបាយ របស់អ្នកដឹកនាំ សំរាប់ធ្វើការបង្ខិតបង្ខំទៅលើអ្នកត្រូវគេដឹកនាំ។តាមវិធីនយោបាយ និងប្រវត្តិសាស្ត្រ **រដ្ឋ** ឲអត្ថន័យខ្លួនឯងថាជា **អង្គហេតុ**[114] ដែលមានកំណើតពី **ការ**

---

109 បុញ្ញាការី= អ្នកមុន ; Prédécesseur។
110 ព្រះរាជា= ស្ដេចកំពុងគ្រងរាជសម្បត្តិ។
111 តួអង្គជីវន្ត= Personnification vivante។
112 អនុសាធ្យ= Corollaire។
113 អំណាចបុគ្គលផ្ទាល់= Pouvoir personnalisé។
114 អង្គហេតុ= Fait។

**ញែកឲឃើញភាពខុសគ្នា**)[115] តាមនយោបាយ រវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។ ការញែកឲឃើញភាពខុសគ្នានេះ ជាឧបករណ៍ របស់អ្នកដឹកនាំសំរាប់គ្រប់គ្រងរដ្ឋ។ ទស្សនៈនេះជាគំនិតប្រាកដនិយម ជាធម្មជាតិរបស់វិទ្យាសាស្ត្រនយោបាយ និងប្រវត្តិសាស្ត្រវិទ្យា ដែលគេទុកវាជា **វិទ្យាសាស្ត្រនៃអង្គហេតុ**។ ផ្ទុយពី **នីតិសាស្ត្រ**[116] ដែលជា **វិទ្យាសាស្ត្រធម្មនិយាម**[117] គេឲអត្ថន័យ គតិយុត្ត នៃរដ្ឋ ជា សារព័ន នៃ **បទដ្ឋាន**[118] ដែលមាន «**ហេតុ**»[119] ជាអង្គហេតុ មានតម្លៃ នៃសង្គម នៅក្នុងបទដ្ឋាន នៃគតិយុត្ត និងបច្ចេកទេស»។

គេអាចបញ្ជាក់ថា «អង្គហេតុមានតម្លៃនៃសង្គមនេះ ជាអង្គហេតុដ៏ប្រសើរ ជាបាតុភូត នៃសង្គមវិជ្ជា ដ៏បរិសុទ្ធមួយ ដែលមានការញែកឲឃើញភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ ដើម្បីងាយស្រួលក្នុងការញែកនៃមុខនាទីរបស់អង្គភាពទាំងពីរនេះ។

ដូច្នេះ បើយើងសាងល្បងឲអត្ថន័យគតិយុត្ត នៃ**រដ្ឋខ្មែរ** តាម**វិទ្យាសាស្ត្រធម្មនិយាម** ក្នុងសម័យអង្គរ យើងអាចនិយាយបានថារដ្ឋខ្មែរ ជា បទដ្ឋាន នៃ «ការការពារ» អាណាប្រជានុរាស្ត្រ ដែលជាតួនាទីសំខាន់របស់ព្រះរាជា ហើយបទដ្ឋាននេះឋិតនៅលើការទទួលស្គាល់ **និតិអត្ថនោម័តិ** របស់ព្រះរាជាពីសំណាក់ប្រជារាស្ត្រ ដែលជា «សិទ្ធិបុគ្គលផ្ទាល់"របស់ព្រះអង្គ ជា **នីតិបុគ្គលផ្ទាល់** ជា **អនិច្ចសិទ្ធិ**[120]ដែលត្រូវរលាយសូន្យ ជាមួយនឹងមរណៈភាពរបស់ព្រះរាជា។

ដូចយើងដឹងហើយថា ស្តេចនិងរាស្ត្រជាអង្គភាពពីរខុសគ្នា មួយជាអ្នកដឹកនាំ មួយទៀតជាអ្នកត្រូវគេដឹកនាំ ស្តេច ជា **អនិច្ចបុគ្គល** តែរាជកិច្ចព្រះអង្គ ត្រូវបានស្តេចស្នងរាជ្យបន្តយកមកអនុវត្តក្នុងសករាជថ្មីបន្ទាប់ពីស្តេចថ្មីនេះបានប្រកាស

---

115 ការញែកឲឃើញភាពខុសគ្នា= Différenciation។
116 នីតិសាស្ត្រ= Droit។
117 វិទ្យាសាស្ត្រធម្មនិយាម= Science normative។
118 បទដ្ឋាន= Norme។
119 ហេតុ= ប្រើក្នុងន័យភាសាបារាំងថា Sujet។
120 អនិច្ចសិទ្ធិ= សិទ្ធិត្រូវតែបាត់បង់ ; Droit périssable។

រំលាយវាចោលសិនមុននឹង ព្រះអង្គអនុគ្រោះឲយកមកអនុវត្តឡើងវិញ។ ការរកនិច្ចភាព ជាលក្ខណៈសំខាន់របស់ខេមរៈរាជ្យខ្មែរ ដែលជាសណ្ឋាននៃ**រដ្ឋខ្មែរ**ក្នុងសម័យអង្គរ និងនៅក្នុងសម័យក្រោយអង្គរ។ ការទទួលស្គាល់របស់ព្រះរាជាថ្មីនូវ **អាជ្ញាគតិយុត្ត** របស់**ស្តេចចមតកជន**[121] នេះបានក្លាយជារាជប្បវេណីដែលគេយកមកធ្វើជា **កិច្ចវីតិ**[122] បញ្ចូលវាក្នុងពិធីរាជអភិសេកស្តេច ដែលមានលំដាប់លំដោយដូចរៀបរាប់ខាងក្រោមនេះ៖

« *ក្រោយពីព្រះរាជាទទួល* ***រាជទណ្ឌ*** *រួចហើយ ព្រះអង្គធ្វើជាអធិបតីក្នុងរាជពិធីហូតត្រាមុខងារ ពីរាជមន្ត្រី ដែលពួកគេបានទទួលវាពីស្តេចមតកជន បន្ទាប់ពីព្រះរាជាថ្មីបានពាល់ត្រានោះរួចហើយ មានន័យថា ព្រះអង្គបានដកហូតងារទាំងឡាយនោះសិន រួចហើយទើបព្រះអង្គធ្វើការប្រកាសប្រគល់ត្រាងារត្រឡប់នៅឲវិញដល់រាជមន្ត្រី នៅពេលនោះឯង រាជមន្ត្រីទាំងនោះបានទទួលភ្លាមនូវមុខតំណែងចាស់ខ្លួនឡើងវិញ* »។

តាមកិច្ចវីតិនេះ គឺជាការយល់ព្រមទទួលស្គាល់តំណែងចាស់របស់រាជមន្ត្រី និងអាជ្ញាគតិយុត្តនៃរជ្ជកាលចាស់ ពីសំណាក់ព្រះរាជាថ្មី។ ពិធីនេះ ធ្វើឡើងសំរាប់បញ្ជាក់អំពី **អំណាចបុគ្គលផ្ទាល់** របស់ព្រះរាជាថ្មីក្នុងរជ្ជកាលថ្មី ដែលគេទុកជាមូលដ្ឋាននៃការរៀបចំអំណាចព្រះរាជានៅក្នុងរដ្ឋខ្មែរនាសម័យដើម។

គេឃើញមានក្នុងសិលាចារិកខ្មែរសរសេរជាភាសាសំស្រ្កឹត បញ្ជាក់ថារដ្ឋផ្គុំដោយវត្ថុធាតុ៧យ៉ាង៖

«**ប្រមុខរដ្ឋ រាជសេនា ប្រជាពលរដ្ឋនិងទឹកដី រាជបូរី រតនសម្បត្តិ កងទ័ព** និង **សម្ពន្ធមិត្រ** »។

---

[121] ស្តេចមតកជន= Roi défund។
[122] កិច្ចវីតិ= Acte rituel។

វត្ថុធាតុទាំងឡាយនេះ មានន័យពីរគឺ **អង្គ** (**anga**) និង **prakrti** (ឬ ប្រទេស)៖

**ទី១**. **អង្គ** (សេរីរៈឬអវយវៈ)មាននន័យថាវត្ថុធាតុទាំង៧យ៉ាងនេះ ជាអវយវៈនៃខ្លួន **រដ្ឋ**។ ក្នុងគំនិតនេះ គេឃើញមានចារលើសិលាចារិកនៅប្រាសាទប្រែរូប ថា៖

«*ព្រះឥសូរ ព្រះអង្គយកអានុភាពរបស់ព្រះអង្គដែលកើតឡើងពីតណ្ហាដាក់ក្នុង អវយវៈព្រះអង្គ ឯចំណែកព្រះវិស្ណុ ជាអ្នកសង្គ្រោះនៃសត្វលោក ព្រះអង្គមានវត្ថុធាតុទាំង៧យ៉ាងជាស្រេចនៅក្នុងអវយវៈរបស់អង្គ ដែលវាមានកំណើតពីសេចក្តីអាសូររបស់ព្រះអង្គ*»។

ក្នុងគំនិតនេះគេចង់ប្រដូចអវយវៈនៃខ្លួនរដ្ឋ ទៅនឹង អវយវៈ ព្រះហារិហរា (ព្រះឥសូរ និង ព្រះវិស្ណុ រំលាយខ្លួនចូលគ្នាតែមួយ។

**ទី២. Prakrti** រឹតតែមានន័យល្អិតល្អន់ផង និងពិបាកយល់ផង គឺថា «**prakrti** កើតឡើងពី **អនុភាព** អ្វីមួយក្នុងពេលមួយ ហើយមាន **និយតភាព**[123] ដូចជាមាស កើតឡើងដោយខ្លួនឯង សំរាប់គេយកវាមកធ្វើ ជា ក្រវិលត្រចៀក។

គេឃើញមានចារលើសិលាចារិក ក្នុងសម័យសាងអង្គរវត្ត សរសេរប្រើរូបមន្តជាពាក្យកាព្យស្តី អំពីព្រះបាទស្រីសុរ្យាវរ្ម័ន ដែលមានសេចក្តី ដូច ទ្រឹស្តីខាងលើនេះ៖

«*ដោយសារព្រះអង្គគង់ក្នុងមណ្ឌលនៃវត្ថុធាតុទាំង៧យ៉ាង ដែលជាអានុភាពរបស់ព្រះអង្គ ទើបជាតិមានវិបុលភាព និងជោគជ័យ*»។

គេដឹងថាទ្រឹស្តីនេះជាទ្រឹស្តីរបស់ពួកហិណ្ឌូ ដែលខ្មែរយើងចម្លងយកមកធ្វើជាទ្រឹស្តីរដ្ឋខ្មែរ។ ទ្រឹស្តីហិណ្ឌូក្តី ខ្មែរក្តី គេឃើញថាក្នុងចំណោមនៃវត្ថុធាតុទាំង៧យ៉ាងនេះគេ

---

[123] និយតភាព= Régularité។

ឲតម្លៃខ្លាំងទៅលើប្រមុខរដ្ឋ ដូចក្នុងគំនិតខ្មែរ គេទុកស្តេចជាវត្ថុធាតុចម្បង ជាប្រធានរបស់ប្រទេស (**Pradhana Prakrti**)។

ទោះបីគេទុកស្តេចជាជាវត្ថុធាតុចម្បងក៏ដោយ តែបើព្រះអង្គជាស្តេចគ្មានគុណធម៌ គឺព្រះអង្គអាចនឹងធ្វើឲខូចបង់នូវវត្ថុធាតុដ៏ទៃទៀតជាពុំខាន។ ដូច្នេះប្រមុខរដ្ឋ ឬព្រះរាជា ក្នុងតួនាទីខ្លួនជាដឹកនាំ ត្រូវតាំងខ្លួនជាជំរកសំរាប់ការពារមិនឲខ្លួនជួបប្រទះនឹងបាបធម៌គ្រប់បែបយ៉ាង។ ជំរកការពារនេះត្រូវបានព្រាហ្មណ៍ **Kautilya** ជាអ្នកនិពន្ធក្បួន **Arthaçastra** ពន្យល់ថា"*ស្តេចមាន **អត្តគុណភាព**[124] ប្រើអំណាចដែលព្រះអង្គបានទទួល ធ្វើឲវត្ថុធាតុដែលគ្មានភាពរុងរឿងឲវាក្លាយទៅជាភាពប្រសើរបាន តែបើស្តេចគ្មានអត្តគុណភាពវិញ ព្រះអង្គធ្វើ **និរោធ**[125] ប្រទេសមួយដែលជាប្រទេសមានភាពរុងរឿងប្រកបដោយភក្តីភាព*។

ក្នុងអត្តគុណភាពនេះ គេទុកព្រះរាជាជាអ្នក**អបរាជ័យ**(អ្នកឈ្នះ)លើសត្រូវ៦យ៉ាង គឺ **កាមរត, កំហឹង, លោភលន់, អភិមានះ, មាយាការ** និង **សេចក្តីច្រណែន**[126]គ្រប់ព្រះរាជាណាដែលពុំអាចមានជ័យជំនះលើសត្រូវទាំង៦នេះបាន គេទុកព្រះអង្គជាព្រះរាជាគ្មានអត្ថិភាពជាព្រះមហាក្សត្រ។

សិលាចារិកខ្មែរឯទៀតៗចារថា"*ព្រះបាទរាជេន្ទ្រវរ្ម័ន ទ្រង់ប្រតិបត្តិរាជការណ៍យកិច្ចរបស់ព្រះអង្គចំពោះវត្ថុធាតុទាំង៧យ៉ាង ក្នុងគោលបំណងធ្វើឲព្រះអង្គក្លាយជាម្ចាស់នៃប្រទេស*"។

សិលាចារិកមួយទៀតចារទុកបង្ហាញភាពល្បីល្បាញព្រះបាទតារានិន្ទ្រវរ្ម័ថា «*ទោះបីព្រះអង្គមាន **ទីឃាយុ**[127] ក៏ដោយ តែព្រះអង្គនៅតែព្យាយាមជានិច្ចធ្វើមហាអភិវឌ្ឍន៍ នៃវត្ថុធាតុ៧យ៉ាងដើម្បីឲប្រទេសមានភាពរឹងប៉ឹង* »។

---

124 អត្តគុណភាព=Qualité personnelle។
125 និរោធ=បំផ្លាញឲសូន្យ ; Destruction។
126 La volupté ; colère ; cupidité ; orgueil ; illusion ; jalousie។
127 ទីឃាយុ=អាយុច្រើន Grand age។

គេសន្និដ្ឋានបានថាទ្រឹស្តីនៃវត្ថុធាតុ៧ជាធាតុផ្គុំនៃរដ្ឋ ជាមូលដ្ឋានសំខាន់នៃគំនិតនយោបាយពួកហិណ្ឌូដែលគេឃើញមាននៅក្នុងសម័យផ្ដើមអង្គរ។ គំនិតនេះត្រូវអ្នកប្រាជ្ញខ្មែរជំនាន់នោះយកមកកែច្នៃឲ្យរឹតតែមានជម្រៅសំរាប់ប្រើជាគោលការណ៍នៃវិធីដឹកនាំជាតិខ្មែរ។

ស្ដេចខ្មែរក្នុងសម័យដើម មុននៅឡើងគ្រងរាជសម្បត្តិ ព្រះអង្គត្រូវរៀនឲ្យចេះនូវគម្ពីរវេទទាំងបួន។ ការនេះ គេឃើញមានចារទុកលើសិលាចារិកនៅប្រាសាទប្រែរូបថា"*ព្រះបាទរាជេន្ទ្រវរ្ម័ន ទ្រង់បានសិក្សាគ្រប់មុខវិជ្ជា១៤យ៉ាង គម្ពីរវេទ៤យ៉ាង និងគម្ពីរវេទអាថ្វា៦យ៉ាង*"។

ស្ដេចខ្មែរក្នុងសម័យដើម ត្រូវចេះចំណេះឲ្យស្ទាត់ ដើម្បីដឹកនាំរដ្ឋ នូវវិទ្យាសាស្ត្រនយោបាយ ហៅថារាជាវិន័យ និតិសាស្ត្រា ហៅថាធម្មាសាស្ត្រ និងវិទ្យាសាស្ត្រយោធា។ គេតែងទុកព្រះរាជាណាដែលមានចំណេះចេះដឹងជ្រៅជ្រះ ជាកវី និងអ្នកស្គាល់រស់ជាតិ ជាស្ដេចចេះគោរពព្រឹទ្ធាចារ្យដែលជាគ្រូបាធ្យាយមានការពិសោធគ្រប់បែបយ៉ាងដូចមានចារទុកក្នុងសិលាចារិកថា"*ព្រះអង្គស្រឡាញ់ពួកព្រឹទ្ធាចារ្យណាស់ ដើម្បីសូមឲ្យពួកគាត់បង្រៀនព្រះអង្គគ្រប់មុខវិជ្ជាដែលពួកគាត់ធ្លាប់ចេះដឹង*"។

ការចេះដឹងរបស់ស្ដេចនេះ មានគោលបំណងតែមួយគត់ គឺការពារប្រជារាស្ត្រនិងប្រទេស ដែលគេឃើញមានចារទុកលើសិលាចារិកនៅប្រាសាទប្រែរូបថាៈ

«*ព្រះអង្គកើតចេញពីដៃព្រះព្រហ្ម ដែលមានកំណើតពីផ្កាឈូក មាន **បដិញ្ញាណ***[128] *ជាក្សត្យ ដែលជាងារមានលក្ខណៈសម្បត្តិកើតមានបានមកអំពីរាជកិច្ចនៃការសង្គ្រោះឲ្យចាកផុតអំពីសេចក្ដីវិនាសកម្ម ដែលជារាជកិច្ចមួយមានក្នុងធាតុព្រះអង្គតែម្ដង* »។

---

[128] បដិញ្ញាណ=ងារដែលគេទទួលស្គាល់ Titre de reconnaissance។

## ផ្នែកទី២

## ការរៀបចំអំណាចស្តេច និងរដ្ឋនៅសម័យអង្គរ

### រដ្ឋបាលមជ្ឈិម

គេដឹងថាព្រះមហាក្សត្រខ្មែរជា **ក្លោងមូលដ្ឋាន**[129] នៃការរៀបចំរដ្ឋបាលនៃខេមរៈរាជ្យខ្មែរ ដែលជាអ្នកគ្រប់គ្រងកិច្ចការប្រតិបត្តិ និងតុលាការ។ តាមឯកសារចិនក្នុងសម័យផ្តើមអង្គរ ព្រះរាជាខ្មែរ ព្រះអង្គធ្វើរាជសវនាការបីថ្ងៃម្តងនៅទីតាំងកណ្តាលនគរដើម្បីចាត់ចែងកិច្ចការរដ្ឋជាមួយនិងរាជមន្ត្រីនៃរាជរដ្ឋបាលមជ្ឈិម។ តាមការកត់ទុករបស់ជនជាតិចិនឈ្មោះ **ជីវតាខ្វាន់** ព្រះមហាក្សត្រនៅក្នុងសម័យអង្គរក៏នៅតែបន្តធ្វើរាជសាធារណសវនាការដូចសម័យដើមដែរ។ ដើម្បីជួយធុរៈព្រះអង្គក្នុងកិច្ចការរដ្ឋ ទ្រង់មានជំនួយពីសំណាក់ **ក្រុម្ការ**[130] ដែលដាក់តាម **យថាក្រម** ជាបួនថ្នាក់៖ **ឯក ទោ ត្រី ចត្វា**។ ការបែងចែកនេះ គេធ្វើឡើងឲស្របទៅនឹងការបែងចែកប្រទេសជាបួនសម្បត្តិ **យាវជីវិក**[131] គឺមានចំណែក ព្រះរាជា ព្រះរាជទាយាទ ព្រះឧបរាជ និងព្រះរាជជនី(ម្តាយស្តេច)ឬអគ្គមហិសី។ ការបែងចែកនេះ គេដឹងថាមានតាំងពីសម័យផ្តើមអង្គរមកម្លេះ តែគេឥតឃើញមាននៅក្នុងអក្សរចារឹកទាល់តែសោះថា នៅក្នុងសម័យអង្គរមានការបែងចែកបែបនេះ។នៅក្នុងរាជបញ្ញត្តិ គេមិនដែលឃើញមានសរសេរបញ្ជាក់អំពីតួនាទីព្រះអគ្គមហិសីអមព្រះរាជានោះទេ លើកលែងតែនៅក្នុងសម័យជិតចប់អង្គរ ក្នុងរជ្ជកាលព្រះបាទស្រីន្ទ្រវរ្ម័ន ឬឥន្ទ្រវរ្ម័នទី៣(១២៩៥-១៣០៧) មានចារអំពីព្រះអគ្គមហិសីព្រះអង្គ។ នៅក្នុងសម័យអង្គរ លើសិលាចារឹក គេមិនដែលឃើញពាក្យព្រះឧបរាជនោះដែរ។ បើតាមកញ្ញា **Bongert** ប្រវត្តិវិទូបារាំង ប្រមើលគិតថាការបែង

---

129 ក្លោងមូលដ្ឋាន=មូលដ្ឋានសំខាន់ Clé de voute។
130 ក្រុម្ការ=Corps de fonctionnaires។
131 យាវជីវិក=ប្រព្រឹត្ត ឬ មានដរាបដល់អស់ជីវិត។

ចែករាជសម្បត្តិជាបួនចំណែកនេះ ប្រហែលជាមហាក្សត្រខ្មែរសម័យនោះចម្លងតាមទ្រឹស្តីព្រាហ្មណ៍ **Kautilya** នៅប្រទេសឥណ្ឌាធ្វើអនុសាសចែកប្រទេសជាបួន **ខណ្ឌ**[132] ដើម្បីស្រួលគ្រប់គ្រងកិច្ចការសារពើពន្ធសំរាប់រដ្ឋ។

តាមក្បួននយោបាយដឹកនាំ ឬគតិយុត្តសាស្ត្រ ព្រះមហាក្សត្រខ្មែរមានឧបការីសំខាន់ៗជាច្រើនសំរាប់ជួយព្រះអង្គក្នុងកិច្ចការដឹកនាំនគរ មានពួកព្រាហ្មណ៍ មន្ត្រី បុរោហិត និងអាចារ្យ។ ពួកនិមួយៗអបអមដោយទីព្រឹក្សារៀងៗខ្លួនសំរាប់ជួយកិច្ចការរបស់ខ្លួន។ អ្នកទាំងឡាយនោះសុទ្ធតែមានងារជាអភិជនដែលព្រះរាជាបំពាក់ឲជាកិត្តិយស។ គេចែកឧបការីស្តេចជាពីរកិត្តិមជន មានពួកព្រាហ្មណ៍ដែលមានងារខ្ពង់ខ្ពស់ជាព្រះរាជគ្រូ និងពួករដ្ឋមន្ត្រីជាគ្រហស្ថ ដែលគេតែងហៅជំនាន់នោះថាមន្ត្រី។

## ក. ពួកព្រាហ្មណ៍និងព្រះរាជគ្រូ

តាមសិលាចារឹក ជួនសរសេរជាភាសាសំស្ក្រឹត ជួនជាភាសាខ្មែរ បញ្ជាក់បង្ហាញពីសារៈសំខាន់នៃព្រាហ្មណ៍ ដែលមានគុណសម្បត្តិជាព្រះវរៈគ្រូនៅអមព្រះមហាក្សត្រជាពិសេសចំពោះព្រះយុវក្សត្រ ដែលព្រះអង្គត្រូវការសិក្សាគ្រប់មុខវិជ្ជាពីវរៈគ្រូដើម្បីឲមានចំណេះសំរាប់ដឹកនាំប្រទេស ដូចមានជាឧទាហរណ៍ក្នុងដើមដំបូងនៃរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន និងព្រះបាទជ័យវរ្ម័នទី៥។

ព្រះវរៈគ្រូជាអ្នកទទួលបន្ទុកបង្រៀនព្រះរាជាគ្រប់មុខវិជ្ជាសំរាប់ដឹកនាំនគរ និងជាប្រធានវិធីករនៃការថ្វាយរាជសម្បត្តិដល់ព្រះមហាក្សត្រ ក្នុងមុខនាទីនេះ វរៈគ្រូមានអាជ្ញាខាងផ្លូវសីលធម្ម និងអំណាចនយោបាយក្នុងព្រះរាជាណាចក្រ ដែលជាបេសកកម្មដែលឃើញមានចារក្នុងសិលាចារឹកខ្មែរជាច្រើនទុកជាប្រវត្តិសាស្ត្រ។

យើងលើកយកចារឹកសាស្ត្រស្តីអំពីគ្រួសារព្រាហ្មណ៍ឈ្មោះ **Çivakaivalya** គាត់ធ្វើតាមសក្ខាបទរបស់ព្រះវរៈគ្រូ **Hiranyadana** ដែលជាអ្នកបង្គាប់ឲគាត់ធ្វើប្រពន្ធ

---

132 ខណ្ឌ=ប្រែថានេះក្នុងន័យ ; Division administrative។

ពិធីឲព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) ក្លាយជាទេវរាជា ដែលជាជំនឿថ្មីនៅក្នុងស្រុកខ្មែរ។ គ្រួសារព្រាហ្មណ៍ល្បីៗ ដូចជាគ្រួសារ**Saptadévakula Anintapura** ជាគ្រួសារដែលមានកូនចៅខ្លួនធ្វើការក្នុងព្រះរាជវាំងក្នុងឋានៈជាវរៈគ្រូ ជាហោរា ជាបុរោហិត ជាអាចារ្យ និងជាឧត្តមមន្ត្រីដែលជាមុខងារសំរាប់គ្រហស្ថ ដូចជាប្រធានតុលាការជាន់ខ្ពស់ ជាអធិការពិនិត្យស្ស័យគុណសម្បត្តិ និងគុណវិបត្តិ។ មហាក្សត្រខ្មែរស្រឡាញ់រាប់អានក្រុមគ្រួសារព្រាហ្មណ៍ទាំងនោះណាស់ ហើយគេឃើញជាញឹកញយគ្រួសារស្តេច នឹងគ្រួសារព្រាហ្មណ៍ធ្វើញាតិពន្ធជាមួយគ្នាដូចយ៉ាងអាពាហ៍ពិពាហ៍រវាងបុត្រីព្រះបាទរាជេន្ទ្រវរ្ម័នទី២ ព្រះនាមឥន្ទ្រារស្មីជាមួយនឹងកូនប្រុសរបស់ព្រាហ្មណ៍;ព្រះអង្គម្ចាស់ស្ត្រី ជាព្រះអនុជព្រះបាទជ័យវរ្ម័នទី៥បានរៀបការជាមួយព្រាហ្មណ៍ទេវាការា; ព្រាហ្មណ៍សាដាស្រី; ក្រោយពីបានរៀបការជាមួយញាតិរបស់ព្រះបាទឧទយោទិត្យវរ្ម័នទី២ ខ្លួនត្រូវបានព្រះរាជាតែងតាំងជាព្រះរាជគ្រូ; ព្រះនាងម្នាក់ដែលជាប្អូនថ្លៃរបស់ព្រះបាទសូរ្យវរ្ម័នទី១ ក៏ត្រូវបានព្រះរាជាផ្សំផ្គុំជាមួយព្រាហ្មណ៍សំខាន់ម្នាក់ដែរ។ ដូចយើងធ្លាប់បាននិយាយខាងលើរួចមកហើយថា នៅក្នុងសម័យអង្គរ វណ្ណៈព្រាហ្មណ៍និងវណ្ណៈក្សត្រិយៈ តាមសម្ព័ន្ធនៃអាពាហ៍ពិពា មានប្រស្រ័យជិតស្និទ្ធនឹងគ្នាណាស់ គេអាចទុកប្រស្រ័យនេះជាប្រស្រ័យរកប្រយោជន៍វណ្ណៈ ដើម្បីពង្រឹងលទ្ធិទេវរាជដែលជាមូលដ្ឋាននយោបាយដឹកនាំជាតិនៅក្នុងសម័យនោះ។ គេឃើញថាភារៈរបស់ព្រះរាជគ្រូដែលស្តេចបានប្រគល់ទៅឲពួកព្រាហ្មណ៍ជាភារៈមួយសម្រេបទៅនឹងសិក្ខាបទ និងជំនឿនៃព្រហ្មញ្ញសាសនាគោរពគម្ពីរវេទ។ មុខងាររបស់ព្រះរាជគ្រូមានច្រើនយ៉ាង មានមុខងារគ្រូបង្រៀន និងពន្យល់ដល់មហាក្សត្យអំពី **ធម៌ក្រិត្យា**[133] អប់រំផ្នែកសាសនា និងធ្វើជាពិធីករក្នុងពិធីប្រសិទ្ធិស្តេច។ មុខងារសំខាន់ទាំងពីរនេះហើយដែលជាមុខងារផ្តាច់មុខរបស់ព្រាហ្មណ៍ ដែលមានចែងនៅក្នុងគម្ពីរវេទ។

---

133 ធម៌ក្រិត្យា=ករណីយកិច្ចសីលធម៌ជាទូទៅ, Ensemble des devoirs moraux។

យោងទៅតាមការប្រស្រ័យជិតស្និទ្ធរវាងវណ្ណៈក្សត្រនិងព្រាហ្មណ៍ និងតួនាទីជាគ្រូរបស់ព្រះរាជា គេអាចស្មានបានថានៅក្នុងសម័យអង្គរ ទោះបីគេទុកស្តេចជា ក្លោងមូលដ្ឋាននៃអំណាចផ្តាច់ការ តែការដឹកនាំជាតិមានលក្ខណៈជាអង្គការ

**សហវិកតា**[134] ដែលមានពួកព្រាហ្មណ៍ និងក្រុមទីប្រឹក្សាជាសមាជិកនៅក្នុងអង្គការនេះ។ កំរិតសមគំនិតដ៏ខ្ពស់មួយរវៀងពួកព្រាហ្មណណ៍បុរោហិតជាមួយនឹងមហាក្សត្យខ្មែរ នាំឲគេអាចសន្មត់បានថា វាជាវិបត្តិមួយនៃការប្រព្រឹត្តទៅជាធម្មតារវាងអំណាចប្រតិបត្តិ និងអំណាចសាសនា ដែលជាអំណាចទី២ សំរាប់ជួយបង្ហាញផ្លូវដល់ព្រះរាជាឲដើរតាមធម៌ក្រិត្យា។ នៅពេលដែលព្រះរាជាដឹងបំណងនៃពួកព្រាហ្មណ៍ថាជាមនុស្សមានចំណង់ចង់មានបានកិត្តិយស មាសប្រាក់ដូចមនុស្សធម្មតា ព្រះអង្គច្បាស់ជារកមធ្យោបាយទិញពួកនេះឲលង់ខូចក្នុងតណ្ហាឥតកំរិតរបស់មនុស្សលោក។ ការនេះក៏មានបញ្ហាសសំរាប់ពួកព្រាហ្មណ៍វិញដែរ គឺថានៅពេលដែលពួកគេស្គាល់ចំណុចខ្សោយរបស់ព្រះរាជា ច្បាស់ជាពួកគេឆ្លៀតរកប្រយោជន៏តាមឧបាយបញ្ឆោតស្តេចឲដើរតាមមាគ៌ា ដែលគេបញ្ឆោតឲដើរដើម្បីរកផលប្រយោជន៏ដែលពួកគេចង់បាន។ ការប្រព្រឹត្តិបែបនេះជាការបើកទ្វារចំហដល់គ្រប់អំពើពុករលួយអាចហូរចូលដោយសេរីក្នុងអំណាចដឹកនាំជាតិ និងអំណាចសាសនា។ អំពើទាំងនេះបានធ្វើឲនៅក្នុងមជ្ឈដ្ឋានអ្នកដឹកនាំ ក្លាយជាមជ្ឈដ្ឋាននៃល្បិចកលទុច្ចរិត ដើម្បីរកប្រយោជន៏ឯកជនភ្លាមៗ ដែលនាំឲខូចប្រយោជន៏ជាតិ។ ចំណេរកាលតមក គុណវិបត្តិគ្រប់សារពើនេះបានដុះផ្សិតនៅអូអាប់យូក្នុងគំនិតអ្នកដឹកនាំជាតិ ធ្វើឲពួកគេយកអំពើពុករលាយជាមូលដ្ឋាននយោបាយដឹកនាំជាតិរបស់ខ្លួន ដើម្បីរក្សាអំណាចផ្តាច់ការ និងស្វែងរកភោគលាភលើទុក្ខវេទនារបស់រាស្ត្រ ដែលពួកគេតែងតែប្រកាសជាកំភរជានិច្ចថាខ្លួនជាអ្នកដឹកនាំ គឺជាអ្នកការពារ និងជាអ្នកថែរក្សាសេចក្តីសុខដល់អាណាប្រជានុរាស្ត្រ។

---

134 សហវិកតា=Collégial។

## ខ. រាជវង្សានុវង្សខ្មែរ

តាមការកត់ទុករបស់ជនជាតិចិន ឈ្មោះជីវតាខ្វាន់ មហាក្សត្យខ្មែរមានមហិសីប្រាំនាក់ **អគ្គមហិសី**មួយ និងអនុមហិសីបួននាក់ទៀតដែលមានតួនាទីជាតំណាង **ទិលានុទិស**[135] បើយោងតាមសិលាចារឹក គេឃើញថា អនុមហិសីទាំងបួន

គ្មានតួនាទីអ្វីជាសំខាន់នៅជិតអមមហាក្សត្រខ្មែរ ឯចំណែកអគ្គមហសីវិញ គេឃើញមានចារលើសិលាចារឹតស្តីអំពីអភិសេកព្រះម្ចាស់ស្ត្រីឥន្ទ្រទេវី ឲមានងារជាអគ្គមហិសីព្រះបាទជ័យវរ្ម័នទី៧ និងការប្រគល់ **នាមបច្ឆាមរណៈ**[136] ដល់ព្រះអគ្គមហសីក្រោយពីបានទទួលមរណៈដូចមហាក្សត្យដែរ ការនេះបញ្ជាក់ឲឃើញថាអគ្គមហិសីមានតួនាទីសំខាន់មួយដែរក្នុងអំណាចស្តេច។ តាមសិលាចារឹតដែរ អគ្គមហិសីរបស់ស្តេចមួយភាគធំច្រើនតែជាកូនស្រី របស់ពួកឧត្តមមន្ត្រីដែលពួកគេថ្វាយដល់ព្រះរាជា ឲធ្វើជាស្នំស្តេចជាអាទិ ហើយបន្ទាប់មកស្នំខ្លះក៏បានស្តេចលើកតាំងជាអគ្គមហិសី ឧទាហរណ៏ដូចជាអគ្គមហិសីព្រះបាទជ័យវរ្ម័នទី៨ ព្រះនាមចក្រាវរាជាទេវី អគ្គមហិសីព្រះបាទស្រីន្ទ្រជ័យវរ្ម័ន ត្រូវជាប្អូនស្រីពៅរបស់លោករដ្ឋមន្ត្រីមធុគ្រាសុវី..ល..។ មហិសីស្តេច និងព្រះអង្គម្ចាស់ស្ត្រីច្រើនមានងារជា **កន្យា**[137] លោក Dupond, ប្រវត្តិវិទូ, សរសេរថាពាក្យនេះជាពាក្យមានប្រភពពីជនជាតិឥណ្ឌូណេស៊ី។

យើងនិយាយអំពី **ព្រះរាជទាយាត** តាមឃើញចារលើសិលាចារិកខ្មែរ ព្រះអង្គមានសម្បត្តិផ្ទាល់របស់ព្រះអង្គ ដែលព្រះរាជាថ្វាយដល់ព្រះអង្គ។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានថ្វាយងារជាព្រះរាជទាយាតព្រមនឹងឧបយោគគ្រប់សារពើក្នុងស្រុកខ្មែរដល់ព្រះអង្គម្ចាស់ចាមម្នាក់ ព្រះនាមវិជ្ជាណន្តា ដែលបានរត់មកសូមជ្រោកកោនក្រោមអំណាចព្រះអង្គ។ ការនេះបញ្ជាក់បង្ហាញថាងារព្រះរាជទាយាតមិនមែន សំរាប់ប្រើចំពោះតែអ្នកដែលអាចស្នងរាជ្យស្តេចបាននោះឡើយ

---

135 ទិលានុទិស=Les quatre points cardinaux។
136 នាមបច្ឆមរណៈ=ឈ្មោះគេដាក់អោយក្រោយស្លាប់, Nom posthume។
137 កន្យា=កញ្ញា, Jeune fille។

ងារនេះក៏អាចជាងារជាកិត្តិយសមួយដែលព្រះរាជាថ្វាយឲនរណាម្នាក់។ ព្រះរាជទាយាតត្រូវបានតែងតាំងឡើងតាមពីធីអភិសេកជាឧឡារិក ការនេះជាការបញ្ជាក់បង្ហាញពីតួនាទីសំខាន់មួយក្នុងអំណាចស្ដេច។

នៅប្រទេសឥណ្ឌាក្នុងសម័យបុរាណ ងារជា **រាជបុត្រា** ជាងារដែលគេអាចឲដល់បុគ្គលណាមួយមិនចាំបាច់បុគ្គលនោះមានត្រកូលជាស្ដេចនោះទេ។ នៅស្រុកខ្មែរគេឃើញមានប្រើងារពីរ ហើយគ្មានការបែងចែកឲច្បាស់នោះឡើយ ងារពីរនេះគឺ"រាជាបុត្រា"នឹង"រាជាកុមារ" ជាងាររបស់ព្រះអង្គម្ចាស់គ្រប់រូបដែលបានទទួលភារៈដឹកនាំកិច្ចការសំខាន់ពីព្រះរាជា ដូចមានចារទុកលើសិលាចារឹកក្នុងសម័យនគរភ្នំឬល្វូណនថា"ព្រះអង្គម្ចាស់គុណធារវ៉ូនត្រូវព្រះរាជាតែងតាំងជាម្ចាស់ដីភកដែលជាដែនដីចាក់ដីធ្វើឲស្ងួនលើដីល្បប់ទន្លេមេកុង្គ។ ដែនដីនេះ ជាដីវាលកក់នៅប្រទេសឡាវសព្វថ្ងៃនេះ។ បញ្ញតិព្រះបាទជ័យវ៉ូនទី៥ បញ្ជាក់ឲឃើញដែរថាព្រះអង្គម្ចាស់មួយអង្គ ដែលទ្រង់ បង្គាប់ឲសាងវិហារដ៏ធំមួយត្រូវបានព្រះអង្គប្រទានងារជា **កំរាលដែន**[138] អញ្ញរាជាកុមាររាជាបុត្រា។

### គ. រដ្ឋមន្ត្រីឬមន្ត្រី

ដំណែងនេះ ព្រះរាជាច្រើនប្រគល់អោយពួកអភិជន ដែលជាជនមានជាប់ញាតិសន្ដាននឹងត្រកូលស្ដេច តែគេឃើញមានពួកព្រាហ្មណ៍កាន់ដំណែងនេះដែរ។ នៅក្នុងឋានានុក្រម ឋានៈរដ្ឋមន្ត្រីជាឋានៈបន្ទាប់ពីពួកបុរោហិត តែគណរដ្ឋមន្ត្រីជាមូលដ្ឋានជាសារវន្តរបស់ម៉ាស៊ីននៃរាជការ និងនយោបាយដឹកនាំរបស់របបរាជាធិបតេយ្យដែលមានចែងនៅក្នុងនីតិសាស្រ្តា និងធម៌សាស្រ្តា។ តាមទ្រឹស្ដីព្រាហ្មណ៍ **Kautilya** (នៅប្រទេសឥណ្ឌា)ពួករដ្ឋមន្ត្រីជាវត្ថុធាតុមួយក្នុងចំណោមវត្ថុធាតុទាំងប្រាំពីរយ៉ាងដែលគេទុកជាខ្លួននៃរដ្ឋ។ ទ្រឹស្ដីនេះប្រហែលស្ដេចខ្មែរយើងយកមកអនុវត្តនៅស្រុកខ្មែរ បើយោងតាមសិលាចារឹកនៅប្រាសាទប្រែរូប ដែលមានសេច

138 កំរាលដែន=ជាម្ចាស់ដែនដី កំរាឬកំរាល=គ្រោប គ្រប់គ្រង តែនឬដែន=ដំបន់ ដែនដី។

ក្តីថា *«ព្រះរាជា (រាជេន្ទ្រវរ្ម័ន) មានគ្រប់សីលធម៌ដែលព្រះអង្គប្រាថ្នាចង់បាន ដោយសារព្រះអង្គតែងតែស្តាប់យោបល់មន្ត្រីរបស់ព្រះអង្គជានិច្ច»*។

រួមសេចក្តីមក គេអាចសន្និដ្ឋានបានថា តាមទ្រឹស្តី អំណាចរាជានិយមជាឯកភូត អំណាច ដែលមានស្តេចជាម្ចាស់តែមួយតែបើគេពិនិត្យមើលតាមរបៀបធ្វើវិញគេ ឃើញថាអំណាចផ្តាច់ការនៃរាជាធិបតេយ្យក្នុងសម័យបុរាណខ្មែរ ជាអំណាចមាន សណ្ឋានជា **អប្បជននាំធិបតេយ្យ**[139] ដែលជារបៀបគ្រប់គ្រងអំណាចនៅក្នុងកណ្ តាប់ដៃជនមួយក្រុមតូច មានពួកព្រះអង្គម្ចាស់ ពួកអភិជន ពួកព្រាហ្មណ៍ និង ពួកលោកម្ចាស់សក្តិភូមិ ដែលជាញាតិសន្តាននឹងពូជស្តេច។

### ឃ. កិច្ចការបញ្ញត្តិ

បើគេយកកិច្ចការប្រតិបត្តិ កិច្ចការបញ្ញត្តិ និងកិច្ចការតុលាការ ដែលមាននៅ ក្នុងសង្គមនយោបាយដឹកនាំខ្មែរ ក្នុងសម័យនិយមព្រហ្មញ្ញសាសនា មកពិនិត្យ មើលគេអាចស្មានបានថា កិច្ចការទាំងបីនេះ ជាពិសេសកិច្ចការបញ្ញត្តិ ទោះបីគេ ឃើញមានវាក្នុងការអនុវត្តខ្លះក្តី តែក្នុងទ្រឹស្តីវិញ វាមិនសូវមានសារៈសំខាន់ច្រើន នោះឡើយ ព្រោះថានីតិរដ្ឋដែលមានដើមកំណើតពីគិតិយុត្តវិទ្យាដែលយកធម៌វេទ ដែលជាធម៌កើតចេញពីដង្ហើមព្រះឥន្ទ្រ មិនមែនជាស្នាដៃមនុស្សនោះឡើយបើ ជាស្នាដៃអាទិទេព មនុស្សជាអ្នកគោរពព្រះគ្មានសិទ្ធិណាថាខ្លួនជាអ្នកទទួលខុស ត្រូវលើកិច្ចការបញ្ញត្តិ ដែលមានអាទិទេពជាម្ចាស់។ ស្តេចដែលជាមនុស្ស ព្រះអង្គ គ្មានមុខនាទីណាក្នុងកិច្ចការបញ្ញត្តិ តែព្រះអង្គត្រូវមានករណីយកិច្ចគោរពនិង ប្រតិបត្តិតគខុសនូវអ្វីដែលព្រះបង្កើតឡើង ក្នុងឋានៈព្រះអង្គជាតំណាងព្រះ ក្នុងឋានមនុស្សលោក។ ដូចដែលយើងធ្លាប់បាននិយាយពីខាងលើរួចមកហើយ ថាការវិវឌ្ឍន៍ច្បាប់សត្វលោកគឺជាការវិវឌ្ឍន៍មួយស្របតាមច្បាប់លោកធាតុដូច្នេះ

---

139 អប្បជននាំធិបតេយ្យ=របៀបគ្រប់គ្រងអំណាចក្នុងកណ្តាប់ដៃជនមួយក្រុមតូច, Oligarchie។

មនុស្សមិនអាចមានដើមគំនិតបង្កើតច្បាប់ សំរាប់មនុស្សក្រៅពីចាំទទួលយកច្បាប់លោកធាតុមកអនុវត្តតែប៉ុណ្ណោះ។

ដូច្នេះមហាក្សត្រខ្មែរក្នុងសម័យអង្គរ ព្រះអង្គមានកិច្ចការសំខាន់តែពីរប៉ុណ្ណោះ គឺ កិច្ចការប្រត្តិបត្តិ និងតុលាការ ដែលជាអំណាចសំរាប់បង្ខំមនុស្សឲគោរពច្បាប់អាទិទេពក្នុងនគរ ហើយដាក់ទោសដល់ជនណា ដែលមិនគោរពច្បាប់នោះ កិច្ចការទាំងពីរនេះ ខ្មែរយើងហៅរួមថា"ដំណែងនៃការប្រត្តិបត្តធម៌"ដែលមានព្រះមហាក្សត្រជា **សិទ្ធកម្មជន**[140]។

## ង. កិច្ចការគតិយុត្ត

ព្រះមហាក្សត្រជាឧត្តមចៅក្រមក្នុងព្រះរាជាណាចក្រ តុលាការគ្រប់ជាន់ថ្នាក់ដែលមាននៅក្នុងនគរមិននៅក្រោមអំណាចព្រះរាជា ហើយគ្មានយុត្តិធម៌ណាមួយដែលមិននៅក្រៅពីយុត្តធម៌ព្រះមហាក្សត្រនោះឡើយ។ ក្នុងសម័យអង្គរ ព្រះមហាក្សត្រទោះបីព្រះអង្គជាឧត្តមចៅក្រមតែមួយគត់ក្នុងព្រះរាជាណាចក្រ តែព្រះអង្គមិនបំពេញកិច្ចការតុលាការផ្ទាល់នោះទេ។ ការរៀបចំកិច្ចការតុលាការមានមូលដ្ឋានជាការផ្សំគ្នារវាងប្រព័ន្ធយុត្តិធម៌ពីរ គឺ **យុត្តិធម៌ព្រះមហាក្សត្រ**[141] និង**យុត្តិធម៌រាជប្រតិភូ**[142]។

យោងតាមសិលាចារឹកខ្មែរ ក្នុងពេលធម្មតា អំណាចតុលាការហាក់បីដូចជាព្រះរាជាប្រគល់អោយតំណាងព្រះអង្គជាអ្នកបំពេញជំនួសព្រះអង្គ ប្រតិភូនេះមានងារជា «**អធិការគុណសម្បត្តិ និងគុណវិបត្តិ** » ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ហ្នឹង ហើយ រដ្ឋមន្ត្រីនេះមានប្រធានរាជាតុលាការជាអ្នកជំនួយ មានងារជា **សម្បត្តិព្រះ** (**Sabbapati**) ដំណែងទាំងពីរនេះ ព្រះរាជាច្រើនប្រគល់ឲគេស្សរជនខ្ពង់ខ្ពស់ក្នុង

---

140 សិទ្ធកម្មជន=អ្នកកាន់ដំណែង, Titulaire។
141 យុត្តិធម៌ព្រះមហាក្សត្យ=យុត្តិធម៌បំពេញផ្ទាល់ដោយអង្គការកំពូលណាមួយ, Justice retenue។
142 យុត្តិធម៌បំពេញដោយតំណាងស្តេច, justice déléguée។

រាជាណាចក្រ។ ឥស្សរជនទាំងពីរនេះ មាននៅក្រោមអំណាចខ្លួន ចៅក្រមជាច្រើន ក្នុងនគរបំពេញកិច្ចការតុលាការក្នុងឋានៈជាប្រតិភូ។

តែកិច្ចការយុត្តិធម៌ខ្លះ ព្រះមហាក្សត្រយកមកសម្រេចផ្ទាល់ខ្លួនឯង ព្រះអង្គបំពេញកិច្ចការនេះក្នុងឋានៈជាចៅក្រមសាលាឧទ្ធរណ៍ ឬជាអ្នក **វិនិច្ឆ័យដោយគ្មានបើកផ្លូវឧទ្ធរណ៍**[143] យុត្តិធម៌ព្រះមហាក្សត្រនេះគេឃើញមានចារលើសិលាចារឹកទួលប្រាសាទ អ្នកដើមចោទមានឈ្មោះវាមស្វា មិនសុខចិត្តការវិនិច្ឆ័យរបស់អធិការគុណសម្បត្តិ និងគុណវិបត្តិ ពីរឿងជម្លោះកម្មសិទ្ធិរបស់ខ្លួន ដាក់ពាក្យបណ្ដឹងទៅព្រះមហាក្សត្រសូមអោយព្រះអង្គជួយរកយុត្តិធម៌អោយខ្លួន។

កិច្ចការនេះមានចារលើសិលាចារឹកថា *«ព្រះរាជាពិនិត្យពាក្យបណ្ដឹងជា មួយរដ្ឋមន្ត្រីនិងទីប្រឹក្សាកិច្ចការតុលាការ ទទួលស្គាល់ថាអធិការគុណសម្បត្តិ និងគុណវិបត្តិមិនបានធ្វើការវិនិច្ឆ័យឲបានត្រឹមត្រូវនោះឡើយ"*។ តាមសិលាចារឹតនៅប្រាសាទប្រែរូបមានចារថា"*ព្រះរាជាធ្វើព្រះរាជសវនាការរកយុត្តិធម៌ជារៀងរាល់ថ្ងៃ មិនថាថ្ងៃឬយប់នោះឡើយ* »។

**ច. កិច្ចការប្រតិបត្តិ**

ក្នុងសម័យអង្គរកិច្ចការប្រតិប្តិរបស់ព្រះរាជាមានពីរ៖

**ច១/ កិច្ចការការបរទេស**

គឺមានសកម្មភាពនយោបាយការបរទេសដូចជាការទំនាន់ទំនងជាផ្លូវទូតមួយប្រទេសចិន ឥណ្ឌា ជ្វា និងប្រទេសជិតខាងដ៏ទៃទៀត។

**ច២/ កិច្ចការក្នុងប្រទេសសកម្មភាពនយោបាយផ្ទៃក្នុងមាន៖**

---

143 វិនិច្ឆ័យដោយគ្មានបើកផ្លូវឧទ្ធរណ៍=Juger en dernier ressort។

ការបង្កើតមូលស្ថាបនាសាសនា ការរៀបចំភូមិដែលនៅជិតប្រាសាទសាសនាឲបានល្អ ការកសាងមន្ទីរពេទ្យ ការប្រកាសរាជបញ្ញត្តិនានាស្តីអំពីការចាត់ទុកកន្លែងណាមួយជាកន្លែងសាសនាជាទីសក្ការបូជា អំណោយរបស់ព្រះមហាក្សត្រជាទីដី ឬទ្រព្យអ្វីមួយសំរាប់ថែរក្សាសាសនា ឬរក្សាជំនឿនៃប្រជារាស្ត្រ។ល។

សកម្មភាពដែលគេឃើញមានច្រើនគឺ ការបញ្ជាក់ពីព្រះរាជានូវការទទួលស្គាល់នៃការលក់ដូរទីដីឲឯកជន ឬរវាងឯកជននឹងឯកជន។ សកម្មភាពនេះគេឃើញមានចារលើសិលាចារឹក នៅទួលប្រាសាទស្តីអំពី ប័ណ្ណកម្មសិទ្ធិទីដីដែលព្រះរាជាប្រគល់ឲរាជប្រតិភូជាអ្នកចាត់ចែង។ ទីដីដែលមានប័ណ្ណកម្មសិទ្ធិត្រូវអ្នករាជការមកបោះបង្គោលជាផ្លូវការនៅពេលណាដែលព្រះរាជាចេញបញ្ញត្តិអោយជាអំណោយទីដីនោះដល់ម្ចាស់កម្មសិទ្ធិ។ ក្នុងចំណុចនេះបញ្ជាក់ឲឃើញថា ព្រះមហាក្សត្រជាម្ចាស់កម្មសិទ្ធិទីដីទាំងអស់ក្នុងព្រះរាជាណាចក្រ ក្នុងឋានៈព្រះអង្គជាអាណាត្តិកហកនៃព្រះធរណី ដែលខ្មែរជំនាន់នោះច្រើនហៅស្តេចថា «កំរាតែនផ្ទៃក្រោម» ដែលមានន័យថា «ម្ចាស់ផ្ទៃដី »។ ងារកំរាតែននេះ ប្រហែលជាមានន័យដែរ ថា «កំរាលដែនដី » ។

## ផ្នែកទី៣

### ការរៀបចំអំណាចស្តេច និងរដ្ឋនៅសម័យក្រោយអង្គរ

នៅក្នុងសម័យក្រោយអង្គរ រាជាអំណាចនៅតែជាអំណាច**អប្សូជនាំធិបតេយ្យ** ព្រះមហាក្សត្រនៅតែជាអ្នកកាន់អំណាចផ្តាច់ការ អមដោយពួកព្រះអង្គម្ចាស់ ពួករដ្ឋមន្ត្រី និងទីប្រឹក្សា ហើយពួកបុរោហិតនៅតែមានតួនាទីសំខាន់ដដែលនៅក្នុងក្រុមទីប្រឹក្សារបស់ព្រះរាជា ប៉ុន្តែឥទ្ធិពលនយោបាយរបស់ពួកបុរោហិតនៅជិតអមស្តេចមានការចុះថយច្រើនណាស់ ក្នុងរបបរាជាធិបតេយ្យនៅសម័យក្រោយអង្គរ។ ចំណេរកាលបន្តៗមក ពួកបុរោហិតគ្រាន់ជាសំណល់នៃអតីតកាល ដែលរបបរាជានិយមខ្មែររក្សាទុកសំរាប់ធ្វើជាពិធីករក្នុងពិធីបុណ្យប្រពៃណីក្នុងព្រះរាជវាំងតែប៉ុណ្ណោះ។ ក្នុងសម័យទំនើបខ្មែរ គេចាត់ទុកពួកបុរោហិតខ្មែរជាជនប្រសើរលុះត្រាតែពួកទាំងនេះតាំងខ្លួនជាពុទ្ធសាសនិកជនពិតប្រាកដ។ នៅក្នុងគ្រប់បុព្វកថានៃរាជច្បាប់ គេយកឈ្មោះសម្តេចព្រះសង្ឃរាជមកដាក់ជំនួសព្រះរាជគ្រូ

បន្ទាប់ពីស្តេច តែទោះបីសម្តេចសង្ឃរាជមាន **ឧបយោគ**[144] នៅក្នុងព្រះរាជាណាចក្រក៏ដោយ តែព្រះអង្គពុំសូវមានឥទ្ធិពលនយោបាយទៅលើព្រះរាជាដូចព្រះរាជគ្រូនោះឡើយ តួនាទីរបស់ព្រះសង្ឃរាជមានកំរិតត្រឹមតែជាទីព្រឹក្សាព្រះមហាក្សត្រក្នុងវិស័យ **សតិបញ្ញា**[145] ឬសាសនា។

ក្នុងសម័យក្រោយអង្គរ ឥស្សរជនសំខាន់ ដែលជាអ្នកជំនួយព្រះរាជាក្នុងកិច្ចការនគរគឺរដ្ឋមន្ត្រី មានចំនួនប្រាំនាក់៖

**អគ្គមហាសេនា** (រដ្ឋមន្ត្រីទី១), **វាំង** (រដ្ឋមន្ត្រីកិច្ចការវាំង), **យោមរាជ្យ** (រដ្ឋមន្ត្រីកិច្ចការយុត្តិធម៌), **ក្រឡាហោម** (រដ្ឋមន្ត្រីកិច្ចការសមុទ្រ) និង **ចក្រី** (រដ្ឋមន្ត្រីកិច្ចការសង្គ្រាម)។

ទោះបីព្រះមហាក្សត្រជាអ្នកផ្តាច់ការនិយមយ៉ាងណាក៏ដោយ តែពួករដ្ឋមន្ត្រី ដែលមានទ្រង់ទ្រាយជាគណៈរដ្ឋមន្ត្រី មានអំណាចអាចសម្រេចកិច្ចការបាន ជូនកាលអាចជាគ្រឿងទប់នឹងការបំពាន ឬការភាន់ច្រឡំនៃការសម្រេចរបស់ព្រះមហាក្សត្រ ដូចមានឧទាហរណ៍ក្នុងរជ្ជកាលព្រះបាទជ័យជេត្ថាទី២ គណៈរដ្ឋមន្ត្រីអនុញ្ញាតិតាមលិខិតឲពួកបព្វជិតប៉រទុយហ្គ៊ែរ (Portugais) ខាងសាសនាយេស៊ូគ្រិស្តមានសិទ្ធិគ្រប់គ្រាន់ធ្វើបរិវត្តន៍ចំពោះបុគ្គលខ្មែរណា ឬអ្នកងារ(ទាសៈទាសី)ដែលមានបំណងចង់កាន់សាសនាយេស៊ូជំនួយសពុទ្ធសាសនាបាន។ ក្នុងលិខិតនេះមានបញ្ជាក់ថាគណៈរដ្ឋមន្ត្រីជាអ្នកអនុញ្ញាត្តិឲអនុវត្តសេចក្តីសម្រេចនេះមុននឹងមានការសម្រេចជាស្ថាពរពីព្រះរាជា។ ប្រាកដមែនពិតហើយថាព្រះមហាក្សត្រមានអំណាចផ្តាច់ការអាចហូតតំណែងរដ្ឋមន្ត្រីបានតាមព្រះរាជហទ័យ តែការសម្រេចបែបនេះ ជាអំពើមួយដែលខ្មែរទុក ជាអំពើទុរាចាររបស់ស្តេច ដូចយើងធ្លាប់និយាយខាងលើរួចមកហើយថា អំណាចរាជានិយមជំនាន់អង្គរ ក្រោយអង្គរ

---

144 ឧបយោគ=មានកិត្តិយស, Jouissance។
145 សតិបញ្ញា=វិញ្ញាណ ប្រាជ្ញា, Spirituel។

ក្តីជាអំណាច **អប្បជនាំធិបតេយ្យ** ដូច្នេះអ្នកដែលកាន់ដំណែងរដ្ឋមន្ត្រី សុទ្ធជា **អង្គជាតជន**[146] នៃប្រព័ន្ធរាជអំណាច។

ក្នុងសម័យក្រោយអង្គរ ព្រះមហាក្សត្រខ្មែរនៅតែជាម្ចាស់នៃអំណាចប្រតិបត្តិ និងអំណាចតុលាការ តែសេរីភាពគ្មានកំរិតរបស់ព្រះអង្គក្នុងវិស័យធ្វើទណ្ឌកម្មមានការចុះថយច្រើន ព្រោះព្រះអង្គតែងទុកព្រះអង្គជាពុទ្ធសាសនិជនពិតប្រាកដដែលមិនមែនជាជនប្រកាសទោស ធ្វើអំពើអាក្រក់របស់ខ្លួនដោយពាក្យសម្តី ឬដោយកាយវិការណាមួយនោះឡើយ។ ស្តេចល្អជាស្តេចគោរព**ទសពិធធម៌**ដែលមានចែងក្នុងធម៌រាជា មានមារយាទជាបីតារបស់រាស្ត្រ ជាមគ្គុទ្ទេសក៏ ច្រើនជាងជាអ្នកគ្រប់គ្រង។ តែទោះបីព្រះមហាក្សត្រខ្មែរជំនាន់នោះខំធ្វើអាកប្បកិរិយាឲ្យស្រុបនឹងពុទ្ធធម៌យ៉ាងណាក៏ដោយ ក៏ព្រះអង្គមិនទុកពុទ្ធធម៌ជាអំណាចនិតិបញ្ញត្តិនោះដែរ ព្រះអង្គ ដូចព្រះមហាក្សត្រខ្មែរនៅសម័យអង្គរដែលជាបុញ្ញាធិការី ទុកធម៌សាស្ត្រាជារច្ចនាសមញ្ញព័ន្ធធម្មតា មានពុទ្ធសិក្ខាបទជាវិធាននៃ **នីតិធម្មនិយាម**[147] តែប៉ុណ្ណោះ ដូច្នេះវិធានទាំងនោះ វាគ្មានលក្ខណៈជាវិធានមានដើមហេតុសំរាប់តាំងគោលការណ៏ជាសារវន្ត និងជាទួទៅនៃវិធានរបស់នីតិសាស្ត្រដែលជាច្បាប់សំរាប់រកហេតុក្នុងវិវាទកម្មដែលអាចមានកើតឡើង។

តាមការសំគាល់ខាងលើនេះ ក្នុករណីទី១ គ្រប់ **ច្បាប់វិជ្ជាមាន**[148] និងច្បាប់ធម្មជាតិ ច្បាប់ទាំងនោះ គឺមានតែច្បាប់វិជ្ជមានទេដែលជាច្បាប់មានសណ្តាប់ធ្នាប់គេស្គាល់ជាដាច់ខាតនូវការបង្កើតឡើង នឹងលក្ខណៈនៃវិធានពិសិដ្ឋរបស់វា **គឺសុក្រឹតភាពពេញលក្ខណៈ**[149] **ភាពមិនប្រែប្រួលបាន**[150] និង **អផុសនីយភាព**[151]។

---

146 អង្គជាតជន=ជនដែលជាវត្ថុធាតុទាំងស្រុងរបស់ប្រព័ន្ធអ្វីមួយ, L’homme qui est en partie du système។
147 នីតិធម្មនិយាម=ច្បាប់សំរាប់សំគាល់បទដ្ឋាន, Droit normative។
148 ច្បាប់វិជ្ជមាន=ច្បាប់បង្កើតដោយមនុស្សដូចជាច្បាប់រដ្ឋជាអាទិ, Loi positive។
149 គឺសុក្រឹតភាពពេញលក្ខណៈ= perfection achevée។
150 ភាពមិនប្រែប្រួលបាន= immuabilité។
151 អផុសនីយភាព(ភាពមិនអាចប៉ះពាល់បាន= intangibilité។

គេដឹងថានៅស្រុកខ្មែរក្នុងសម័យព្រាហ្មណ៍សាសនា គឺគ្មានការចែកដាក់លាក់រវាងសិទ្ធិវិជ្ជមាន និងសិទ្ធិធម្មជាតិ ព្រោះសិទ្ធិទាំងពីរនេះរស់ជាមួយគ្នាក្នុងសកលភាព។ ដូច្នេះអ្វីដែលជាសិទ្ធិស្តេចធ្វើអ្វីមួយ គឺត្រូវទុកទង្វើនេះជាអំពើរក្នុងអំណាចនីតិប្រតិបត្តិ និងអំណាចតុលាការរបស់ព្រះអង្គ មិនមែននៅក្នុងអំណាចនីតិបញ្ញត្តិនោះទេ។ គេដឹងថា រាជានិយមខ្មែរក្នុងសម័យអង្គរ បើយោងតាមទ្រឹស្តីមិនមានកិច្ចការបញ្ញត្តិស្តេចណាមួយដែលគេអាចទុកជានីតិរបញ្ញត្តិនោះឡើយ តែថាកិច្ចការនេះ ដែលវាមានរចនាសម្ព័ន្ធធម្មតា យកសិក្ខាបទសីលធម៌ និង **វិធានធម្មនិយាម** ជាគោលការណ៍ សំរាប់បន្ថយនូវសិទ្ធិពិសិដ្ឋរបស់ស្តេច ក្នុងលក្ខណ:បន្ថយនេះ គេអាចទុកកិច្ចការខ្លះជាកំណើតនៃកិច្ចការបញ្ញត្តិរបស់ស្តេចដែលវាកំពុងក្លាយជាអំណាចនីតិបញ្ញត្តិ។ សេចក្តីប្រកាសរបស់ស្តេចតម្រូវឲប្រជារាស្ត្រគោរពបទដ្ឋានណាមួយ លុះត្រាតែការប្រកាសនេះ វាស្របទៅនឹងគោលការណ៍សីលធម៌។ ដើម្បីឲការប្រកាសព្រះអង្គមានតម្លៃជាច្បាប់ នៅក្នុងសម័យក្រោយអង្គរ ព្រះមហាក្សត្រខ្មែរ ព្រះអង្គតែងតែកាន់តរិយាបថរបស់ព្រះអង្គឲស្របជានិច្ចជាមួយគោលការណ៍សីលធម៌។ ឧទាហរណ៍ឃើញមាននៅក្នុងបុព្វកថារបស់ក្រម (ច្បាប់)នានា ដូចមាននៅក្នុងក្រមបំណុល ក្រមការជំនុំ។ល។ សេចក្តីប្រកាសរបស់ព្រះរាជាតែងតែចាប់ផ្តើមពាក្យថា ព្រះរាជាគោរពពុទ្ធសិក្ខាបទនិងធម៌សាស្ត្រប្រកាសជាផ្លូវការឲគោរពរាជក្រមរបស់ព្រះអង្គ។

គេអាចនិយាយសង្ខេបបានថា ពុទ្ធសាសនាក្នុងសម័យក្រោយអង្គរផ្តល់ឲរបបរាជានិយមនូវបច្ចេកទេសការតែងច្បាប់រដ្ឋ និងសីលធម៌សណ្ឋិតលើគោលការណ៍មនុស្សធម៌ដែលជាការធ្វើឡើងវិញដ៏ល្អនូវច្បាប់ជាច្រើនដែលមាននៅក្នុងសម័យព្រហ្មញ្ញសាសនាឲមានលក្ខណ:ជាច្បាប់មានសប្បុរសធម៌ក្នុងការផ្តន្ទាទោស មានសម្បជញ្ញក្នុងការការពារបរិស្ថាន ការពារសិទ្ធិភរិយានៅចំពោះមុខទុរាចារភាពរបស់ស្វាមី ។ល។

ព្រះពុទ្ធសាសនាជា **បដិរូបការី**[152] ធ្វើឲសង្គមខ្មែរមានភាពជាសង្គមមានគំនិតមនុស្សធម៌ជាគោលការណ៍សង្គម ព្រោះថា នៅក្នុងក្រមទាំងឡាយ ត្រូវតែយកគោលការណ៍ពុទ្ធធម៌ជាគ្រឹះជានិច្ច។

សុក្រឹតភាពពេញលក្ខណៈ ភាពមិនប្រែប្រួលបាន និង**អផុសនីយភាព**(ភាពមិនអាចប៉ះពាល់បាន) នៃពុទ្ធធម៌ នាំឲធម៌នេះ មានលក្ខណៈខុសពីច្បាប់ធម្មជាតិដែលជាច្បាប់មិនអាចគិតទុកជាមុនបាន១០០% ភាពទាំងបីរបស់ពុទ្ធធម៌ខាងលើនេះឯង ដែលនាំឲគេសន្និតបានថា ធម៌ព្រះពុទ្ធ ជាដើមកំណើតមួយនៃនីតិបញ្ញត្តិនៅប្រទេសខ្មែរ។

---

[152] បដិរូបការី=ជាអ្នកកែប្រែ, Réformateur។

# ជំពូក ទី៣ - រដ្ឋខ្មែរ ហើយនឹងការរៀបចំអំណាចក្នុងសម័យអាណានិគមបារាំង

## ១.ការរំឭកជាសង្ខេបនៃប្រវត្តិសាស្ត្រ

គេអាចចោទសួរជាសំនួរថា អាណាព្យាបាលបារាំងជាអ្នកស្រោចស្រង់ជាតិខ្មែរ ឬជាអ្នករំដោះរាជានិយមខ្មែរពីនឹមយួនសៀម?យើងជាខ្មែរ តើយើងអាចមានលទ្ធភាពនឹងឆ្លើយសំនួរខាងលើនេះបានដែរឬទេ ? បើខ្មែរយើងជាអ្នកចេះភាសាបរទេស គាត់បានអានសុសសព្វសៀវភៅប្រវត្តិសាស្ត្រ របស់ប្រវត្តិវិទូល្បីៗជាជនជាតិបរទេស ជាពិសេសជនជាតិបារាំង ដែលលោកបានសរសេរអំពីសម័យអាណាព្យាបាលបារាំងនៅស្រុកខ្មែរ អ្នកចេះទាំងនោះ ច្បាស់ជាធ្វើឲគាត់ទាក់ចិត្តលើរបៀបធ្វើប្រយោគរបស់អ្នកនិពន្ធច្រើនជាងន័យដែលមាននៅក្នុងប្រយោគ។ ក្រោមឥទ្ធិពលនៃសោភ័ណភាពនៃប្រយោគ និងអានុភាពនៃពាក្យបរទេសធ្វើឲខ្មែរយើងព្រមទទួលទាំងអស់នូវអ្វីដែលពួកអ្នកនិពន្ធបានសរសេរបង្ហាញអំពីទស្សនៈរបស់គេ ដោយភ្លេចគិតថាខ្លួនឯង និងជាតិរបស់ខ្លួន ជាតួចម្បងរស់នៅក្នុងព្រឹត្តិការណ៍ដែលអ្នកនិពន្ធទាំងនោះលើកយកមកសរសេរ ជាពិសេសសំរាប់ធ្វើជាសៀវភៅសិក្សាឲខ្លួនសិក្សា។ ការខ្វះប្រតិកម្មនេះនាំឲអ្នកនិពន្ធទាំងនោះក្លាយទៅជាគ្រូនៃគំនិតខ្មែរ ព្រោះអ្វីៗដែលគេបានសរសេរ វាក្លាយទៅជាការពិតដាច់ខាត ឥតមានខ្មែរណា ឬនរណាម្នាក់ទៀតអាចដូរមួយពាក្យបាននោះឡើយ។ **អភិញ្ញាណ**[153] របស់គេអំពីជាតិខ្មែរមានលក្ខណៈជា **ការចេះគុណវុឌ្ឍិ**[154]សាកល ឬការចេះទាំងអស់ ដែលយើងអាចឲឈ្មោះថាជាលទ្ធិផ្តាច់ការលើសម្បជញ្ញខ្មែរ។

---

[153] អភិញ្ញាណ= ការចេះដឹង ; Connaissance។

[154] ការចេះគុណវុឌ្ឍិ= ការចេះមានដែលមានគុណភាព ; Connaissance qualifiée។

**ឯកាធភាព**[155] នេះនាំឲខ្មែរយើងក្លាយជា អ្នកទស្សនាអកម្ម នៃប្រវត្តិសាស្ត្ររបស់ជាតិខ្លួនឯង ឯចំណែកប្រវត្តវិទូបារាំងបានក្លាយដោយចេតនាក្តីឬអចេតនាក្តី ជាអ្នកចក្រពនិយមនៃការចេះអំពីប្រវត្តិសាស្ត្រខ្មែរ ហើយគេទុកការចេះដឹងអោយរបស់ខ្មែរទាំងឡាយអំពីជាតិខ្លួន ជាការចេះដឹងមួយឥតមានមូលដ្ឋានវិទ្យាសាស្ត្រ ឬជារឿងព្រេងតែប៉ុណ្ណោះ។

នៅក្នុងកំឡុងឆ្នាំ១៩៦០ សពសម្តេចស៊ីហនុបានអនុញ្ញាតិឲបង្កើតមហាវិទ្យាល័យប្រវត្តិសាស្ត្រ តែទ្រង់បានមានបញ្ញាច្បាស់លាស់ថា មហាវិទ្យាល័យនេះ មានបេសកកម្មសំរាប់អប់រំតែអ្នកអភិរក្សប្រាសាទបុរាណខ្មែរតែប៉ុណ្ណោះ មិនមែនជាមជ្ឈមណ្ឌល សំរាប់អប់រំអ្នកប្រវត្តិសាស្ត្រនោះឡើយ ព្រោះថាប្រវត្តិសាស្ត្រខ្មែរ ចំពោះសពស៊ីហនុ មិនមែនជាមុខវិជ្ជាសំរាប់យុវជនខ្មែរយកមកសិក្សានោះទេ តែវាជាមនោគមវិជ្ជា របស់របបរាជានិយម ដែលគេបានតាក់តែងរួចស្រេចអស់ហើយ សំរាប់យុវជនខ្មែរយកមកធ្វើជាជំនឿពិសិដ្ឋ ហើយយកវាមករៀនសូត្រឲចេះចាំតែប៉ុណ្ណោះ ហេតុនេះឯងបានជាខ្មែររហូតមកដល់បច្ចុប្បន្នកាលនេះនៅតែនាំគ្នាសូត្រប្រវត្តិសាស្ត្រជាតិខ្លួនឯងដូចសេកដែលម្ចាស់វាបង្ហាត់ឲនិយាយតាមដូច្នេះឯង។

ក្នុងរយៈពេល៩០ឆ្នាំ (១៨៦៣-១៩៥៣) ស្រុកខ្មែរឋិតនៅក្រោមអាណាព្យាបាលបារាំងដែលជាប្រទេសមួយដែលគេទុកជាអ្នកការពារសេរីភាព ភាតរភាព និងសមភាពរបស់ប្រជាពលរដ្ឋបារាំង បើនិយាយឲខ្លីគឺជាប្រទេសការពារសិទ្ធិមនុស្សមានកេរ្តិ៍ឈ្មោះក្នុងពិភពលោក តែទ្រឹស្តីជាសាកលរបស់បារាំងនេះ គេមិនបានយកមកអនុវត្តនៅស្រុកខ្មែរនោះឡើយ ទី១ព្រោះគេយល់ឃើញថាប្រជារាស្ត្រខ្មែរមិនទាន់មាន**បក្កភាព**[156] អាចយល់បាននូវអ្វីដែលហៅថាសិទ្ធិមនុស្ស ទី២ព្រោះគេទុកអារ្យធម៌ របស់ជាតិសាសន៏គេ ខ្ពស់ជាងអារ្យធម៌ជាតិសាសន៏ខ្មែរ ដូច្នេះប្រជារាស្ត្រខ្មែរត្រូវចាំបាច់ប្រើពេលវេលាដ៏យូរដើម្បីខំប្រឹងធ្វើ **សមានកម្ម**[157] ឲចិត្តខ្មែរដូចចិត្តបារាំងសិនទើបអាចយល់បាននូវអ្វីដែលហៅថាវិទ្យាសាស្ត្រ អ្វីដែល

---

155 ឯកាធភាព= ភ្ជាប់មុខ ; Monopole។
156 បក្កភាព= មជ្ឈិមវ័យ ; Maturité។
157 សមានកម្ម= ធ្វើឲដូច ; Assimilation។

ហៅថាភាពទំនើប ទី៣ព្រោះគេទុកស្រុកខ្មែរជាទឹកដីដែលគេដណ្តើមបានសំរាប់ធ្វើជំនួញដើម្បីប្រយោជន៍គេ។ ការវិនិច្ឆ័យទុកជាមុនបែបនេះហើយ ដែលនាំឲអាណានិគមជនបារាំងនៅស្រុកខ្មែរ ក្នុងចិរវេលាកាលសម័យអាណាព្យាបាលបារាំង ទុកខ្លួនជាឧត្តមបុគ្គលប្រៀបធៀបនឹងបុគ្គលខ្មែរ និងជា **ខ្សែនាយក**[158] នៃនយោបាយចក្រពត្រនិយម លើប្រទេសអាណានិគមរបស់ខ្លួន នៅក្នុងពិភពលោក។

ក្នុងរយៈពេល៩០ឆ្នាំ បារាំងបានបង្ខំ"មនុស្សខ្មែរ «ឲដូរចិត្តទៅជា"អនុមនុស្សបារាំង» ដែលធ្វើឲមនុស្សខ្មែរក្លាយឥតដឹងខ្លួនជា **អនុករ**[159] នូវអាកប្បកិរិយានៃមនុស្សបារាំង។ បារាំងដូរចិត្តមនុស្សខ្មែរតាមការអប់រំ ដូចជាការផ្លាស់ភាសាសិក្សាពីខ្មែរទៅបារាំង តាមវប្បធម៌ ដូចេជាអក្សរសាស្ត្រ កំណាព្យ តាមវិជ្ជាវិទ្យាសាស្ត្រគ្រប់វិស័យ តាមអំណាចដឹកនាំ អំណាចតុលាការ ។ល។ **បារាំងភាវរូបូនីយកម្ម** ដោយបង្ខំនេះបានជ្រាបចូលជាពិសេសក្នុងសតិវរជនខ្មែរ ដែលបានសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រទំនើប ហើយនាំគ្នាទុកការចេះថ្មីនេះជាភាពឧត្តមបំផុតលើវប្បធម៌ជាតិខ្លួនឯង ហើយបាន យល់ឃើញថាបើចង់ឲខ្លួនក្លាយជា«**តួអង្គមនុស្ស**[160] ដ៏ឧត្តុងឧត្តម» គឺខ្លួនត្រូវតាំងខ្លួនជាអ្នកចេះដឹង នូវចំណេះទំនើបរបស់បារាំង ដោយបំភ្លេចថាខ្លួនជាមនុស្សខ្មែរ។ វរជនខ្មែរជំនាន់នោះទុកអ្វីដែលជារបស់បារាំង ឬ បរទេសសុទ្ធជាវត្ថុមានតម្លៃខ្ពស់ជាងរបស់ជាតិខ្លួនឯង គំនិតនេះបានក្លាយទៅជាវប្បធម៌របស់វរជនខ្មែររហូតមកដល់សព្វថ្ងៃនេះ នាំគ្នាទុកវប្បធម៌ជាតិ ជាពិសេសអក្សរជាតិ ភាសាជាតិ អក្សរសាស្ត្រជាតិខ្លួនឯងជាអនុវប្បធម៌ប្រៀបធៀបទៅនឹងវប្បធម៌របស់បស្ចិមប្រទេស។ ក្នុងវប្បធម៌បែបនេះ វរជនភាគច្រើនក្នុងសម័យអាណាព្យាបាលបារាំង មិនត្រឹមតែទុកបារាំងជាចៅហ្វាយខ្លួននោះទេ គឺគេនាំគ្នាទុកបារាំងជាម្ចាស់គំនិតរបស់គេថែមទៀត ដែលយើងអាចឲឈ្មោះគំនិតនេះបានថាជា «***វប្បធម៌ខ្ញុំបរទេស***»។

---

158 ខ្សែនាយក= Ligne directrice។
159 អនុករ= អ្នកធ្វើតាមគេ ; Imitateur។
160 តួអង្គមនុស្ស= Etre។

វប្បធម៌ខ្ចីបរទេសនេះ នាំឲវរជនខ្មែរ ដាក់អ្វីដែលជា **បច្ចេកទេសបរទេស** នៅក្នុងសតិខ្លួនជាប្រជ្ញារបស់ខ្លួនតែម្តង ដែលមានភាពខុសគ្នាស្រឡះពីគំនិតវរជនជប៉ុនក្នុងសម័យ Meiji គឺជាសម័យ (១៨៦៨-១៩១២) ដែលប្រទេសជប៉ុនគេបើកទ្វារប្រទេសគេឲមាន ការទំនាក់ទំនង នឹងមស្ចិមប្រទេស គំនិតវរជនជប៉ុនក្នុងសម័យនោះគឺគេចាត់ទុកគំនិតជាតិគេជាម្ចាស់នៃបច្ចេកទេសបរទេស ព្រោះវាគ្រាន់តែជាមធ្យោបាយ សំរាប់បំរើគំនិតជាតិ ដើម្បីរកប្រយោជន៏ជូនដល់ជាតិគេ ដែលគេហៅគំនិតនេះថា «គំនិតជប៉ុនបច្ចេកទេសបរទេស» ក្នុងគំនិតនេះគេទុកគំនិតជាតិគេជាប្រាជ្ញារបស់គេ។ ប្រាជ្ញាជាតិនេះវាមាននៅក្នុងអក្សរជាតិ ភាសាជាតិគេ វប្បធម៌ជាតិ ហេតុនេះឯងបានជាគេនាំគ្នាខំបកប្រែគ្រប់ចំណេះរបស់បរទេស ជាភាសាជាតិ គេក្នុងគោលដៅធ្វើប្រជាធិបតេយ្យូនីយកម្មចំណេះទាំងឡាយនោះឲជនជាតិគេអាចយកមកសិក្សាចំណេះនេះបាន របៀបបែបនេះគេឲឈ្មោះថា” ការយកចំណេះថ្មីនេះមកធ្វើជារបស់ជាតិ”គឺថាអ្វីដែលគេបានចេះពីបរទេសគឺដោយសារប្រាជ្ញាជនជាតិជប៉ុន ដែលគេទុកជាឧត្តមប្រាជ្ញាព្រោះគេយល់ឃើញថាបច្ចេកទេសជាចំណេះសាកល ឯចំណែកគំនិតជាតិជាឧត្តម **ប្រាជ្ញាបរិច្ឆិន្ន**[161] របស់ជាតិនិមួយៗ ដូច្នេះគេទុកគំនិតជាតិ មានភាពឧត្តមបំផុតលើបច្ចេកទេសបរទេស។ ក្នុងសម័យ Meiji វរជនជាតិជប៉ុនទុកចំណេះពួកបស្ចិមប្រទេសជាចំណេះថ្មីដែលត្រូវតែរៀនឲចេះ តែចំណេះនេះ គេមិនទុកជាម្ចាស់នៃគំនិតរបស់គេ ដូចវរជនខ្មែរ ក្នុងសម័យអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) នោះឡើយ។ ឧទាហរណ៍បែបនេះមិនមែនមាននៅតែក្នុងប្រទេសជប៉ុននោះទេគេឃើញនៅក្នុងប្រទេសជិតខាងយើងដែរ ដូចជានៅប្រទេសយៀកណាម និងប្រទេសសៀម ដែលគេឲតម្លៃជានិច្ច ទៅលើគំនិតជាតិគេលើសគំនិតបរទេស ឧទាហរណ៏ជាក់ស្តែងគឺ មានការបោះពុម្ពច្រើនណាស់សៀវភៅជាភាសាជាតិគេនូវគ្រប់មុខវិជ្ជាវិទ្យាសាស្ត្រ អក្សរសាស្ត្រ ទស្សនៈវិជ្ជាល្បីៗរបស់អ្នកប្រាជ្ញបស្ចិមប្រទេស សំរាប់ឲយុវជនរបស់គេយកមកសិក្សា និងពិចារណាប្រៀបធៀបនឹងចំណេះដែល

---

161 ប្រាជ្ញាបរិច្ឆិន្ន= Intelligence spécifique។

មានក្នុងគំនិតជាតិគេដើម្បីរក «**តម្លៃបន្ថែម**[162]» ដែលមានក្នុងចំណេះថ្មីនេះ ដែលគេអាចទាញយកជាប្រយោជន៍ពីវាសំរាប់ជាតិគេ។

វរជនយួនសៀមគេទុកភាសា អក្សរ វប្បធម៌ជាតិគេជាតម្លៃជាតិ និងតម្លៃខ្លួនគេផ្ទាល់ផងលើឆាកអន្តរជាតិ ប៉ុន្តែគេព្យាយាមរៀនភាសាអង់គ្លេសក្តី បារាំងក្តីឬភាសាបរទេសឯទៀតក្តីសំរាប់ជាតម្លៃបន្ថែមនៃការចេះដឹងរបស់គេតែណ្ណោះ តែទោះបីយ៉ាងណាក៏ដោយ ក៏គេមិនដែលទុកតម្លៃបន្ថែមនេះជាសញ្ញានៃឧត្តមភាពរបស់គេចំពោះមុខជនជាតិរបស់គេនោះឡើយ។ អ្នកចេះដឹងយួនសៀមនៅពេលណាគេមានកំរិតការចេះដឹងគេកាន់តែខ្ពស់ឡើង គេពិតជាចេះភាសាជាតិគេច្បាស់លាស់ហើយ គេប្រើជានិច្ចភាសាជាតិ សំរាប់ឲតម្លៃដល់ជាតិគេលើឆាកអន្តរជាតិ។ ស្ថានភាពនេះវាមានភាពផ្ទុយស្រឡះពីអ្នកចេះដឹងខ្មែរយើង គាត់មិនសូវហានសរសេរភាសាជាតិទេ ដូចលោកប៊ុណ្ណចន្ទមុល គាត់ធ្លាប់បានសរសេរក្នុងសៀវភៅរបស់គាត់មួយមានចំណងជើងថា «គុកនយោបាយ»ថា វរជនខ្មែរគាត់មិនសូវចង់ចេះភាសាខ្មែរទេព្រោះគាត់ខ្លាចថាខ្លួនមិនមែនជាអ្នកចេះ សរសេរជាភាសាបារាំងឬអង់គ្លេសគឺជាសញ្ញាចេះដឹងរបស់អ្នចេះដឹងខ្មែរ គំនិតនេះមាននៅក្នុងសតិវរជនខ្មែររហូតមកដល់សព្វថ្ងៃនេះ ដែលយើងបាននិយាយរួចមកហើយថាជា «គំនិតខ្ញុំគេ»។ វរជននៃប្រទេសជឿនលឿនតែងតែទុកការចេះដឹងរបស់គេម្នាក់ៗជាការទទួលខុសត្រូវក្នុងការការពារប្រយោជន៏ជាតិ មិនមែនជាភាពក្រអឺតក្រអោងចំពោះមុខរាស្រ្តនោះឡើយ។

អស់រយៈជិតមួយសតវត្ស អាជ្ញាធរអាណាព្យាបាលបារាំងនៅតែបន្តដឹកនាំប្រជារាស្រ្តខ្មែរដូចរបបរាជានិយម ហើយបារាំងនៅតែទុកខ្មែរជា **រាស្រ្ត**[163] របស់ព្រះរាជាខ្មែរដែលមានបារាំងជាអ្នកការពារ និងជាអ្នកធានារក្សាសន្តិសុខរបស់ព្រះអង្គ។ ក្នុងលក្ខណៈនេះ យើងអាចធ្វើអនុមានបានថា អំណាចអាជ្ញាធរបារាំងមិនមែនមកជំនួសអំណាចផ្តាច់ការស្តេចនុះទេ តែវាមកដាក់តម្រួតគ្នាទៅជាទម្ងន់ថ្មីមួយ

---

162 តម្លៃបន្ថែម= Valeur ajoutée។
163 រាស្រ្ត= ប្រជាពលរដ្ឋ ក្រោមការត្រួតត្រា របស់អ្នកដឹកនាំ ; Sujet។

ទៀតសំរាប់ប្រជារាស្ត្រខ្មែរ ខ្មែរម្នាក់ត្រូវតែខ្លាចអំណាចស្តេចផង ហើយត្រូវតែគោរពអាជ្ញាធរបារាំងថែមទៀត អំណាចទាំងពីរនេះជាជ័រលុបបំបាត់ចោលនូវអត្តសញ្ញាណនៃ"មនុស្សខ្មែរ"ឲរស់មានលក្ខណៈត្រឹមជា **បសុសត្វ**[164] សំរាប់បំរើអំណាចតែប៉ុណ្ណោះ។ នៅក្នុងឥណ្ឌូចិនបារាំងដែលផ្សំដោយប្រទេសបី ខ្មែរយួនឡាវ អាជ្ញាធរអាណានិគមបារាំងគេធ្វើការចាត់ជាថ្នាក់ដែនដីនៃប្រទេសទាំងបីជា **ដែនដីអភិបាលតាមឋានានុក្រមលំដាប់ស័ក្តិ**[165] ដូចជាគេយកប្រទេសយៀកណាមធ្វើជារដ្ឋបាលមជ្ឈិម និងជាមជ្ឈមណ្ឌលអប់រំជាន់ខ្ពស់ គេយកប្រទេសខ្មែរនិងឡាវធ្វើត្រឹមជារដ្ឋបាលខេត្ត និងជាមជ្ឈមណ្ឌលអប់រំមធ្យម តាមការធ្វើបែបនេះ បារាំងបានឲឯកសិទ្ធិច្បាស់ដល់ជនជាតិយួន ជ្រើសរើសតែជនជាតិយួនយកមកធ្វើជាឧបការីគេនៅក្នុងរដ្ឋបាលមជ្ឈិម ហើយជួយឲជនជាតិយួនលើសខ្មែរនិងលាវ ឲបានរៀនវិជ្ជាជាន់ខ្ពស់គ្រប់វិស័យ ដែលនាំឲជនជាតិយួនក្លាយជាជនជាតិ មានគុណវុឌ្ឍិ ខាងវិជ្ជាជីវៈគ្រប់វិស័យលើសជនជាតិខ្មែរនិងឡាវនៅក្នុងសម័យអាណានិគមបារាំង។ ក្នុងចំណុចនេះ បារាំងអាចលើកយកច្បាប់នៃចំនួនភាគច្រើននៃជនជាតិយួននៅក្នុងឥណ្ឌូចិនមកធ្វើជាហេតុផល តែហេតុផលនេះវាមានភាពផ្ទុយស្រឡះពីសន្ធិសញ្ញា អាណាព្យាបាលបារាំង ជាមួយប្រទេសកម្ពុជាដែលជាសន្ធិសញ្ញារវាងរដ្ឋមួយនិងរដ្ឋមួយ ដែលបារាំងគ្មានសិទ្ធិណាមួយសោះអាចបញ្ចូលប្រទេសកម្ពុជាទៅក្នុងឥណ្ឌូចិនបារាំង ដែលជាការបង្កើតរបស់ខ្លួនសំរាប់តែរកប្រយោជន៍ផ្ទាល់របស់ខ្លួន ហើយនាំឲខូចប្រយោជន៍ជាតិខ្មែរដែលជាប្រទេសនៅក្នុងការឧបត្ថម្ភរបស់ខ្លួន។ ការបង្កើតឥណ្ឌូចិនបារាំងនេះទៀតគឺពិតជាគ្រោះកាចរបស់ប្រជាជាតិខ្មែរ។ ខ្មែរយើងមួយចំនួននៅតែយល់ឃើញថាសន្ធិសញ្ញាអាណាព្យាបាលបារាំង វាមានប៉ែកជាវិជ្ជមានរបស់វា គឺរំដោះប្រទេសខ្មែរពីនឹមយួនសៀម តែបើខ្មែរយើងលើកយកលទ្ធផលផ្តាច់ព្រ័ត្រ របស់អាណាព្យាបាលបារាំងមកពិនិត្យ យើងឃើញថាប្រទេសខ្មែរយើងបានបាត់ទឹកដីមានទំហំជាងពាក់កណ្តាលនៃផ្ទៃដីខ្មែរយើងបច្ចុប្បន្ន **ជាកម្រៃចំពោះ**[166] ប្រទេសយួនសៀម។

---

[164] បសុសត្វ= Animaux domestique។
[165] ដែនដីអភិបាលតាមឋានានុក្រមលំដាប់ស័ក្តិ= Territoire administratif hiérarchisé។
[166] ជាកម្រៃចំពោះ= Au profit de។

ពិតណាស់ហើយថា បារាំងបានទាមទារបានមកវិញពីប្រទេសសៀមមកឲខ្មែរវិញនូវអាណាខេត្តមួយចំនួន ដូចយ៉ាងខេត្តបាត់ដំបង សៀមរាប ម្លូព្រៃ បារាំងបាននាំមកនូវប្រព័ន្ធ អប់រំវិទ្យាសាស្ត្រ រដ្ឋការទំនើប សាធារណសុខាភិបាលសម័យបង្កើត **ហេដ្ឋារចនាសម្ព័ន្ធ**[167] សំរាប់ធ្វើអភិវឌ្ឍន៍សេដ្ឋកិច្ច តែការខ្វះការកែទម្រង់រចនាសម្ព័ន្ធសង្គមសក្តិភូមិខ្មែរ របៀបដឹកនាំផ្តាច់ការផុតសម័យ វាធ្វើឲសមិទ្ធិកម្មជាវិជ្ជមានរបស់បារាំងដែលយើងបានរៀបរាប់ខាងលើនេះ ហើយបារាំងគេទុកជាជំនួយរបស់គេដល់ជាតិខ្មែរ មិនមានលក្ខណៈជាជំនួយសំរាប់ធ្វើ**អភិវឌ្ឍន៍ឋិតថេរ**[168] សំរាប់ជាតិខ្មែរ។

ក្រោយពីសម័យអាណាព្យាបាលបារាំង ប្រទេសខ្មែរ បានជួបប្រទះនូវវិបត្តិនយោបាយពុំអាចជំនះបាន ដែលនាំឲប្រទេសខ្មែរ ខានបានធ្វើដំណើរលើមាគ៌ាលទ្ធិប្រជាធិបតេយ្យសេរីពិតប្រាកដ ដែលជាកត្តាមួយដែលនាំឲប្រជាពលរដ្ឋខ្មែរជួបប្រទះនូវទុក្ខវេទនាគ្រប់បែបយ៉ាងរហូតមកដល់សព្វថ្ងៃនេះ។

តែខ្មែរយើង ពុំអាចដាក់កំហុសទាំងស្រុងទៅលើអាណានិគមបារាំងនៅតល្អូចិនអំពីការជួបប្រទះនូវទុក្ខគ្រប់បែបយ៉ាងរបស់ខ្លួននោះឡើយ ការដាក់កំហុសនេះដែលខ្មែរយើងតែងតែលើកយកវាមកធ្វើការដោះស្រាយ ដើម្បីគេចពីការទទួលខុសត្រូវរបស់ខ្លួន។ ក្នុងចំណុចនេះគួរយើងនាំគ្នាអង្គុយគិតមួយរយៈ ហើយសួរជាសំនួរដល់ខ្លួនឯងថា”ហេតុអ្វីបានជាប្រទេសជិតខាងយើង មានយួនសៀមជាអាទ៍ គេតែងតែមានជ័យជំនះលើយើងជានិច្ចក្រោយពីសម័យអង្គរមក ?តើបរាជ័យយើងជាគ្រោះថ្នាក់មួយដងមួយកាលរបស់ជាតិយើងតែប៉ុណ្ណោះឬទេ ?យើងគួរយល់ថាបរាជ័យទីមួយរបស់ខ្មែរយើង យើងអាចទុកវាជាគ្រោះថ្នាក់បាន ហើយយើងអាចយកវាមកធ្វើជាការដោះស្រាយយករួចខ្លួនបាន តែបើបរាជ័យរបស់ខ្មែរយើងវាមានគ្រប់ពេលវេលាចាប់ពីសតវត្សទទី១៥ មកដល់បច្ចុប្បន្នកាល ស្ថានភាពបែបនេះ តម្រូវឲខ្មែរយើងពិចារណារកមូលផលពិតនៃបរាជ័យនេះដើម្បីរក

[167] ហេដ្ឋារចនាសម្ព័ន្ធ= Infrastructure។
[168] អភិវឌ្ឍន៍ឋិតថេរ= Développement durable។

ផ្ទាំកែស័ក្តិសិទ្ធិ មិនមែននៅត្រឹមតែនាំគ្នាបួងសួងព្រះសូមឲព្រះអង្គនាំមកនូវសេចក្តីក្លាហាន នៃបុព្វបុរសខ្មែរយើ នៅសម័យអង្គរ ឲមកបដិសន្ធិក្នុងព្រលឹងខ្មែរយើងបច្ចុប្បន្ន ដើម្បីជួយសង្គ្រោះជាតិ ដែលកំពុងជួបប្រទះនឹងគ្រោះថ្នាក់ដល់អាយុជីវិត តែអ្នក**សំបូងសង្រួង**(បួងសួង)ទាំងនោះឥតបានគិតថា សម័យអង្គរជាសម័យសក្តិភូមិ នៅពេលនោះត្រូវអំណាចផ្តាច់បង្ខំឲបុព្វបុរសខ្មែរយើងយកសេចក្តីក្លាហានរបស់គាត់មកបម្រើអំណាចដើម្បីប្រយោជន៏អំណាចតែប៉ុណ្ណោះ ដូច្នេះត្រូវខ្មែរយើងបច្ចុប្បន្ននេះទេ ដែលត្រូវមានសេចក្តីក្លាហានខ្លួនឯងដើម្បីសង្គ្រោះជាតិ និង រំដោះព្រលឹងបុព្វបុរសយើងពីអំពើឃោរឃៅ នៃអំណាចផ្តាច់ការដែលគាត់ជាអ្នករងគ្រោះ ទោះបីស្លាប់បាត់ទៅហើយ រហូតមកដល់សព្វថ្ងៃនេះ។ ដំណោះស្រាយថ្មី ដើម្បីរំដោះជាតិពីភយន្តរាយ ដែលជាតិខ្មែរយើងកំពុងជួបប្រទះសព្វថ្ងៃនេះ ខ្មែរយើងពុំអាចរកវាឃើញនៅក្នុងអតីតកាល របស់ជាតិយើងបាននោះឡើយ ព្រោះខ្មែរយើងមិនមែនជាម្ចាស់នៃអតីតកាលរបស់ខ្លួន ម្ចាស់របស់អតីតកាលខ្មែរ គឺអានុភាពនៃរាជានិយមខ្មែរ ដែលមានជំនួយពីអានុភាពនៃប្រវត្តវិទូបរទេសមួយចំនួនជាអ្នកធ្វើអន្ទងឲរាជានិយមខ្មែរក្លាយទៅជាម្ចាស់កម្មសិទ្ធិផ្តាច់មុខនៃប្រវត្តិសាស្ត្រជាតិខ្មែរ។ គួរខ្មែរយើងទទួលស្គាល់ថាជោគជ័យរាជានិយមខ្មែរដែលគ្មាន នរណាអាចប្រកែកបាន គឺជាជោគជ័យនៃឧបាយបញ្ឆោតតាមមេរៀនប្រវត្តិសាស្ត្រជាតិ នៅក្នុងមេរៀននោះ ស្តេចគ្រប់ជំនាន់ គេបានលើកគុណូបការ របស់គេយកមកអួតដើម្បីឲប្រជាពលរដ្ឋខ្មែរកោតគោរពរហូតមកដល់សព្វថ្ងៃនេះ។ ដូចយើងឃើញស្រាប់ហើយ ក្នុងសម័យអាណាព្យាបាលបារាំងក្តី សម័យឯករាជ្យក្តី សម័យសង្គ្រាមរំដោះជាតិពីឃ្មួនកុម្មុយនិស្ត(១៩៧០-១៩៧៥) និង (១៩៧៩-១៩៨៩) សម័យ UNTAC ក្តី គេតែងតែយករាជានិយមខ្មែរមកធ្វើជាការដោះស្រាយតែមួយគត់សំរាប់ជាតិខ្មែរ ទោះបីគេដឹងច្បាស់ថាការដោះស្រាយនេះជាការដោះស្រាយដែលគេលែងយកមកប្រើហើយក៏ដោយ។ ដូច្នេះបើអ្នកស្នេហាជាតិសព្វថ្ងៃនៅតែយល់ឃើញថា រាជានិយមជាការដោះស្រាយនូវបញ្ហាខ្មែរគឺច្បាស់ជាគាត់នាំគ្នាដើរតាមស្នាមវែងអន្លាយទ័លដដែលជាពុំខានឡើយ។ ការដោះស្រាយបញ្ហាខ្មែរដែលខ្មែរកំពុងជួនប្រទះសព្វថ្ងៃនេះ គឺមានក្នុងសម្បជញ្ញជាតិរបស់ខ្លួនម្នាក់ៗដែលជាកម្លាំងជាតិពិតប្រាកដ។ បើខ្មែរយើងមិនទុក «គំនិតខ្ញុំគេ» ជា

គំនិត**ពេលលេញ**[169] នោះទេ ខ្មែរយើងនៅតែរស់ក្នុងទុក្ខជានិច្ច ដែលយើងតែងតែទុកវាជាកម្មពៀររបស់ជាតិខ្មែរយើង។ យើងដឹងរួចហើយថាក្នុងសម័យអាណាព្យាបាលបារាំង បារាំងគេមិនបានជួយបើកទ្វា"ផ្លូវការពិត"ឲប្រជាពលរដ្ឋខ្មែរដើរទៅរកសុភមង្គលដោយខ្លួនឯង តែនៅក្នុងសម័យឯករាជ្រ ខ្មែរយើងក៏មិនខំប្រឹងប្រែងស្វែងរកមូលហេតុពិតនៃទុក្ខរបស់ខ្លួនឯងនោះដែរ យើងឃើញថានាប្ចុប្បន្នកាលនេះ ប្រជាពលរដ្ឋខ្មែរកំពុងរស់ឥតស្គាល់អតីតកាលខ្លួនពិត និងគ្មានសេចក្តីសង្ឃឹមក្នុងអានាគតកាលខ្លួន ស្ថានភាពនេះហើយដែលជាគ្រោះថ្នាក់ដល់អាយុជីវិតពិតរបស់ជាតិខ្មែរ។ អ្នកដែលមានកំហុសគឺខ្មែរយើងតែម្តង ឧទាហរណ៍ជាក់ស្តែងគឺការហូរចូល នៃជនជាតិយួនមកក្នុងទឹកដីខ្មែរដូចទឹកជំនន់ហូរចូលឥតមានទំនប់ទុប និងការបាត់បង់ទឹកដីជាតិដែលមានប្រទេសយៀកណាមជាអ្នកទទួលផល។

## ២.អំណាចរបស់អាជ្ញាធរអាណាព្យាបាលបារាំងនៅស្រុកខ្មែរ

អាជ្ញាធរបារាំងនៅស្រុកខ្មែរក្នុងសម័យអាណាព្យាបាលបារាំង (១៨៦៣-១៩៥៣)ជាអាជ្ញាធរដាក់ក្រោមការត្រួតត្រាអាជ្ញាធរអាណានិគមបារាំងនៅឥណ្ឌូចិន ដែលមាន ទីតាំងនៅក្រុងហាណូយក្នុងប្រទេសវៀតណាម ដែលជាទីស្តីការនៃ **អភិបាលនាយក**[170] បារាំងនៅឥណ្ឌូចិន ឯចំណែកនៅស្រុកខ្មែរក៏ដូចជាស្រុកឡាវដែរ អ្នកតំណាងអគ្គអភិបាលនៅក្នុងប្រទេសទាំងពីរនេះ មានងារជា **អ្នកប្រចាំការជាន់ខ្ពស់**[171] ហើយនៅតាមខេត្តនិមួយៗមានអ្នកប្រចាំការបារាំងម្នាក់ មានងារជា **អ្នកប្រចាំការខេត្ត** ក្នុងតួនាទីជា **អនុរក្ស**[172] មើលកិច្ចការរដ្ឋបាលខ្មែរ ដែលមានចៅហ្វាយខែត្រខ្មែរជាអ្នកដឹកនាំផ្ទាល់។

---

169 ពេលលេញ= Temps révolu។
170 អភិបាលនាយក= Gouverneur général។
171 អ្នកប្រចាំការជាន់ខ្ពស់= Résident supérieur។
172 អនុរក្ស= surveillant។

ចាប់ពីឆ្នាំ១៨៧០ អាជ្ញាធរបារាំងចាប់ផ្តើមពង្រឹងអំណាចគេនៅស្រុកខ្មែរ ដោយមានការបែងចែកកិច្ចការរដ្ឋភាលជាពីរផ្នែក៖

១. កិច្ចការដែលអាជ្ញាធរបារាំងគេទុកដាក់ក្រោមអាណាព្យាបាលបារាំង ដូចជាវិស័យសាធារណៈការ សុខាភិបាល និងសិក្សាធិការ។

២. កិច្ចការដែលអាជ្ញាធរបារាំងគេទុកឲរដ្ឋបាលខ្មែរដឹកនាំផ្ទាល់ ដូចជាវិស័យទារពន្ធពីប្រជារាស្ត្រ កសិកម្ម ពាណិជ្ជកម្ម និងចោរប្លន់តាមសមុទ្រ។

គួរកត់សំគាល់ដែរថាក្នុងឆ្នាំ១៨៧០ ស្តេចនរោត្តមបានបង្កើត"ពន្ធបុគ្គល"មានអ្នកជាប់ពន្ធជាជនជាតិខ្មែរ អាណិកជនយួន សៀម ឡាវ និងជ្វាដែលរស់នៅលើទឹកដីខ្មែរ ឯចំណែកជនជាតិចិនវិញ បារាំងគេទុកជា **អនីតជន**[173] ពីច្បាប់ខ្មែរ ដូច្នេះចិនផុតរួចពី «ពន្ធបុគ្គល» ដោយហេតុនេះអាជ្ញាធរខ្មែរមិនទុកអាណិកជនចិនជា «រាស្ត្ររបស់ស្តេចខ្មែរ » នេះដែរ។ មកដល់ឆ្នាំ១៨៨២ **អាជ្ញាបារាំងបង្ខំ ស្តេចនរោត្តម**[174] ឲឈប់ទារ «ពន្ធបុគ្គល» ពីជនជាតិយួនដែលរស់នៅលើទឹកដីខ្មែរ ដូច្នេះជនជាតិយួនជាកសិករនៅបង់ត្រឹមតែពន្ធ «ដីស្រែ» ឲរាជការខ្មែរតែប៉ុណ្ណោះ។ វិធានការនេះបង្កើតឡើងដោយអាជ្ញាធរបារាំងនៅ **កូសាំងស៊ិន** (ទឹកដីកម្ពុជាក្រោមបច្ចុប្បន្ន) ដើម្បីទាក់ទាញជនជាតិយួនឲមករស់នៅកម្ពុជាកាន់តែច្រើនក្នុង **គោលលបំណងលេបទឹកដីខ្មែរនេះឲទៅជនជាតិយួន**។

យើងឃើញមានការវិវឌ្ឍន៍ នៃសន្ធិសញ្ញារវាងរាជាណាចក្រកម្ពុជា និងប្រទេសបារាំងចុះថ្ងៃទី១១កក្កដាឆ្នាំ១៨៦៣ ដែលស្តេចខ្មែរទទួលយល់ព្រមឲប្រទេសបារាំងធ្វើជាអ្នកអាណាព្យាបាលព្រះអង្គ ដូរនឹងការអនុញ្ញាត ឲព្រះចៅអធិរាជបារាំងតែងតាំងព្រះរាជតំណាង របស់ព្រះអង្គនៅអមព្រះចៅកម្ពុជា មានមុខនាទីជាអ្នកការពារស្តេចខ្មែរ។ ក្នុងសេចក្តីសន្ធិសញ្ញានេះ បារាំងគេហាមដាច់ខាតដល់ព្រះរាជាខ្មែរមិនអនុញ្ញាតឲកុងស៊ុលប្រទេសណាមួយមកតាំងតំណាងក្នុងព្រះរាជាណា

---

173 អនីតជន= ជននៅក្រៅច្បាប់ : Personne qui n’est pas soumise à la loi។
174 Alain Forest – Le Cambodge et la colonisation française។

ចក្រខ្មែរ ដោយគ្មានការអនុញ្ញាតពីអ្នកប្រចាំការជាន់ខ្ពស់បារាំងនៅកូសាំងស៊ិន អនុញ្ញាត ឲជនជាតិបារាំងមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយសេរីហើយ មានសិទ្ធិជាម្ចាស់នៃកម្មសិទ្ធិរបស់ខ្លួនដែលគេមាននៅស្រុកខ្មែរ ដូរនឹងការអនុញ្ញាតិឲជនជាតិខ្មែរមានសិទ្ធិទៅរស់នៅក្នុងគ្រប់ដែនដីបារាំង ហើយជាម្ចាស់នៃកម្មសិទ្ធិរបស់ខ្លួនលើទឹកដីបារាំងវិញដែរ។ បន្តមកក្នុងអនុសញ្ញាចុះថ្ងៃទី១៧មិថុនា ឆ្នាំ១៨៨៤ រវាងអភិបាលកូសាំងស៊ិន លោក CharlesThomson និងព្រះរាជាខ្មែរ ដែលជាអនុសញ្ញាឲអាជ្ញាធរបារាំងមានអំណាចគ្រប់គ្រាន់ធ្វើការកែទម្រង់រចនាសម្ព័ន្ធក្នុងវិស័យ រដ្ឋបាល តុលាការ និងពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រខ្មែរ នៅពេលណា ដែលបារាំងគេយល់ឃើញថាមានប្រយោជន៏ក្នុងបេសកកម្មអាណាព្យាបាលរបស់គេ។ ការវិវឌ្ឍន៏នេះនាំឲប្រទេសខ្មែរដូរដោយមិនចំពីលក្ខន្តិកៈខ្លួនជា ប្រទេសក្រោមអាណាព្រាបាល ទៅជាប្រទេសក្រោមអាណានិគមបារាំងដូចប្រទេសវៀតណាម។

បើយើងយកសន្ធិសញ្ញារវាងរាជាណាចក្រកម្ពុជានិងប្រទេសបារាំងចុះថ្ងៃទី១១កក្កដាឆ្នាំ១៨៦៣មកពិនិត្យ យើងឃើញថា បារាំងគេការពារស្រុកខ្មែរនៅពេលណាដែលគេអាចមានប្រយោជន៏ក្នុងការការពារនោះ ហើយជាពិសេសគេតែងតែទុកប្រយោជន៏ របស់បារាំងជាធំក្នុងការសម្រេចអ្វីមួយ ដូចយ៉ាងការកាត់ផ្តាច់ទឹកដីកម្ពុជាក្រោមឲទៅប្រទេសវៀតណាមខាងត្បូង ។ល។

ប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលបារាំងបានផុតភ័យខ្លះពិតមែនពីមហិច្ឆិតាវាតទឹកដីពីសំណាក់ប្រទេសជិតខាងមានយួននិងសៀម តែអាណាព្យាបាលបារាំងនេះតម្រូវឲស្រុកខ្មែររស់ជាប្រទេសឯកោ ឈប់មានការទំនាក់ទំនងនឹងប្រទេសដ៏ទៃទៀតដែលខ្លួនធ្លាប់មានរាប់សតវត្សរួចមកហើយ ដូច្នេះការទាក់ទងជាមួយបារាំង មិនមែនជាការបើកទ្វារប្រទេសកម្ពុជាដល់ពិភពលោកខាងក្រៅនោះឡើយ ផ្ទុយទៅវិញជាការបិទទ្វារប្រទេសសំរាប់ទុកឲប្រទេសបារាំងតែមួយគត់សម្រេច លើជោគវាសនា របស់ប្រជាពលរដ្ឋខ្មែរ។ យើងអាចប្រៀបបានអាណាព្យាបាលបារាំងទៅនឹងផ្ទៃមេឃដែលខ្មែរយើងមើលឃើញពីបាតអណ្តូង មានពណ៌ខៀវភ្លឺល្អ តែវាគ្រាន់តែជាពន្លឺតូចមួយបំភាន់ភ្នែកខ្មែរតែប៉ុណ្ណោះ។

**៣. អំណាចអាជ្ញាធរបារាំង និងអំណាចស្តេចខ្មែរ**

ក្នុងសម័យអាណាព្យាបាល អាជ្ញាធរបារាំង គេមិនបានលុបអំណាចប្រពៃណីព្រះរាជាខ្មែរនោះទេ តែគេបង្កើតអំណាចថ្មីនៅអមអំណាចប្រពៃណីស្ដេច នៅចំពោះមុខអំណាចស្ដេច បារាំងគេទុកគេជាទីប្រឹក្សាជាន់ខ្ពស់ ឧទាហរណ៍ **អ្នកប្រចាំការនាយក** បារាំងនៅស្រុកខ្មែរមានសិទ្ធិអាចចូលជួបព្រះរាជាបានតាមចិត្តគេ ដើម្បីពិភាក្សាកិច្ចការរដ្ឋ អគ្គអ្នកប្រចាំការនេះមានសិទ្ធិចូលប្រជុំជំនុំគណរដ្ឋមន្ត្រីដែលមានព្រះរាជាជាប្រធានអង្គប្រជុំ ផ្ទុយទៅវិញអ្វីដែលបារាំងគេចាត់ទុកជាអំណាចរបស់គេ ព្រះរាជាខ្មែរគ្មានសិទ្ធិណាមួយមកជ្រៀតជ្រែងចូលនោះឡើយ ដូចមានចែងក្នុងអនុសញ្ញា១៧មិថុនាឆ្នាំ១៨៨៤ ស្ដីអំពីអំណាចបារាំង និងកំរិតអំណាចព្រះរាជាខ្មែរ។ ក្នុងអំណាចថ្មីរបស់អាជ្ញាធរបារាំង គេរៀបចំខែត្រធំៗប្រាំបី ក្នុងចំណោមខែត្រ៥៧របស់ខ្មែរ ដាក់ក្រោមការត្រួតត្រាផ្ទាល់របស់គេ ខែត្រទាំង៨នោះមាន ក្រូចឆ្មា ពោធិសាត កំពត កំពង់ធំ ក្រចេះ ភ្នំពេញ បាណាម និងកំពង់ឆ្នាំង បារាំងគេជាអ្នកតែតាំងអភិបាលខេត្តខ្មែរ ជាអ្នកទារពន្ធសំរាប់រតនាគារសាធារណៈ បន្ទាប់មកទៀត នៅខែតុលាឆ្នាំ១៨៨៤ បារាំងគេបានលុបចោលតុលាការខ្មែរ បង្កើតតុលាចម្រុះខ្មែរបារាំងដែលមានជនជាតិបារាំងធ្វើជាចាងហ្វាង។ វិធានការទាំងឡាយនេះនាំឲមានការទោមនស្សក្នុង **ក្រម្ការ** (រាជការ)ខ្មែរព្រោះខ្លួនត្រូវបានបារាំងលុបបុព្វសិទ្ធិខ្លួននៅចំពោះមុខប្រជារាស្ត្រ រហូតដល់ទៅឈប់ឲខ្លួនមានសិទ្ធិជា **ទាសបតិ** (ម្ចាស់ទាសៈទាសី) របស់ខ្លួន ព្រោះថានៅក្នុងអនុសញ្ញា១៧មិថុនា១៨៨៤ អាជ្ញាធរបារាំងបានប្រកាសឈប់ឲមានទាសភាពនៅស្រុកខ្មែរ។

នាខែមករាឆ្នាំ១៨៨៥មានកើតចលនាតស៊ូមួយ ប្រឆាំងនឹងបារាំង ដឹកនាំដោយព្រះអង្គម្ចាស់ស៊ីវុត្ថា ជាព្រះអនុជស្ដេចនរោត្ដម ដែលធ្លាប់បានបេះបោលម្ដងរួចហើយប្រឆាំងនឹងព្រះរាម ក្នុងឆ្នាំ១៨៦០ ជំទាស់នឹងការប្រគល់សិទ្ធិដល់ព្រះរាមនេះ ពីព្រះចៅសៀម ព្រះនាមមង្គុត ឲបន្តសោយរាជសម្បត្តិពីព្រះបិតា ព្រះចៅអង្គដួងក្រោយពីព្រះអង្គសោយទិវង្គត។ ការបេះបោលលើកទី២របស់ស៊ីវុត្ថាមានលក្ខណៈជាបេះបោលប្រជាមានិត មានការគាំទ្រពីប្រជារាស្ត្រ ជាពិសេសមានការគាំទ្រជាសំងាត់ពីស្ដេចនរោត្ដមថែមទៅទៀត ការនេះដែលនាំឲអាជ្ញាធរបារាំងមានការពិបាកនឹងបង្ក្រាប សម្រេចធ្វើការចរចារជាមួយស្ដេចនរោត្ដមឲជួយបង្ក្រាបការបេះបោល ដូរនឹងការកាត់បន្ថយចំនួនខែត្រប្រាំបីដែលបារាំងយកមកត្រួតត្រាផ្ទាល់មកត្រឹមប្រាំ មានខែត្រកំពត កំពង់ធំ ក្រចេះ ពោធិសាត និង

ភ្នំពេញ អ្នកប្រចាំការបារាំងតាមបណ្តាខេត្រទាំងនោះ ឈប់មានសិទ្ធិខ្ពស់លើចៅហ្វាយខេត្រខ្មែរ ហើយបារាំងឈប់ធ្វើជាអ្នកទារពន្ធ លើកលែងតែពន្ធអាភៀន ស្រា និងពន្ធគយ បារាំងគេនៅតែឲ្យភ្នាក់ងាររដ្ឋាករជាតិទារពន្ធដដែល ឯចំណែកវិស័យតុលាការ បារាំងគេសុខចិត្តប្រគល់ត្រឡប់ឲមកនៅក្រោមអាជ្ញាធរខេត្រខ្មែរវិញ លើសពីនេះទៅទៀត;ជនជាតិបារាំងក្តី អឺរុបក្តី បើមានបំណងចង់សង់លំនៅឋាន អាគារពាណិជ្ជកម្ម ឬធ្វើកសិកម្មលើទឹកដីខ្មែរត្រូវចាំបាច់ ធ្វើពាក្យសុំអនុញ្ញាតពីអ្នកប្រចាំការជាន់ខ្ពស់បារាំងនៅកម្ពុជាជាមុន ហើយមុននឹងអនុញ្ញាតប្រគល់ដីសម្បទានឲដល់អាណិកជនបរទេសទាំងនោះអ្នកប្រចាំការជាន់ខ្ពស់នេះត្រូវចាំបាច់ សុំយោបល់ពីព្រះរាជាខ្មែរជាមុនសិន;ថែមទៀត អំណើះតទៅបើបារាំងចង់ធ្វើអន្តរាគមន៍យោធាបារាំងក្នុងទឹកដីកម្ពុជា អាជ្ញាធរយោធាបារាំងត្រូវធ្វើពាក្យសុំ ជាផ្លូវការជាមុនថ្វាយដល់ព្រះរាជាខ្មែរមានន័យថា កងទ័ពបារាំងតាំងទីក្នុងទឹកដីខ្មែរត្រូវដកថយចេញពីស្រុកខ្មែរហើយចំនួនអាណិកជនបរទេសរស់នៅស្រុកខ្មែរត្រូវមានចំនួនបន្ថយ។ បន្ទាប់ពីបារាំងបង្ក្រាបបានជោគជ័យ ដោយមានជំនួយពីស្តេចនរោត្តម លើការបះបោលនេះមក ខសំខាន់ទាំងឡាយនេះ ជាពិសេសក្នុងវិស័យយោធា ដែលបារាំងបានសន្យាជាមួយព្រះរាជាខ្មែរ បារាំងគេមិនដែលយកមកអនុវត្តនោះឡើយ មិនតែប៉ុណ្ណោះក្នុងសារាចរចុះថ្ងៃទី២៧កក្កដាឆ្នាំ១៨៨៦ អាជ្ញាធរបារាំងគេសរសេរបញ្ជាក់ថាគេនៅតែអនុវត្តអនុសញ្ញា១៧មិថុនាទាំងស្រុង តែជាការអនុវត្តមួយតាមលំដាប់ ហើយស្របនិង **វេទយិតភាព**[175] របស់ជាតិខ្មែរ។

ការដណ្តើមយកអំណាចពីស្តេចខ្មែរដែលយើងបានលើកយកមករៀបរាប់ខាងលើនេះ យើងអាចទុកវាជារដ្ឋប្រហាររបស់បារាំង ដែលបារាំងគេចុះនាមវាជាបេសកកម្មអារ្យធម៌ និងធ្វើ **នវូបនីយកម្ម**[176] នៃរដ្ឋបាលខ្មែរផង តែបារាំងគេទុកឲព្រះរាជាខ្មែរនៅមានអំណាចប្រពៃណីលើរាស្ត្រ របស់ព្រះអង្គដើម្បីរក្សាត្បានុភាពនៃរាជានិយម ដែលបារាំងគេយល់ឃើញថាវាជាកត្តានៃឯកភាពនៃជាតិសាសន៍

---

175 វេទយិតភាព= ត្រូវនឹងអារម្មណ៍ ; Sensibilité។
176 នវូបនីយកម្ម= ភាពទំនើប ; Modernisation។

ខ្មែរ និងជាគូសន្ទនាគួរយកជាការបានចំពោះគេ ហេតុនេះឯងយើងយល់ឃើញថាអំណាចអាជ្ញាធរបារាំង និងអំណាចប្រពៃណីនៃព្រះរាជាខ្មែរក្នុងសម័យអាណាព្យាបាលបារាំងរស់នៅជាមួយគ្នាក្នុងសភាពដាក់តម្រួតគ្នាផង និងស្របគ្នាផង តែសភាពទាំងពីរនេះ គឺបារាំងជាអ្នកបកស្រាយ កាត់យល់ដោយយោលតាមប្រយោជន៍របស់បារាំងជាធំ គឺថាគ្រប់សណ្ឋាននៃវិវាទកម្មនឹងអំណាចស្ដេចកើតចេញមកពីប្រជារាស្ត្រខ្មែរ បារាំងគេជាអ្នកចេញមុខការពារអំណាចស្ដេចដែលគេទុកជាអំណាចឥតអាចខ្មែរណាម្នាក់បំពាបំពានបាននោះឡើយ ក្នុងស្ថានភាពបែបនេះហើយ ដែលបារាំងគេទុកអំណាចប្រពៃណីស្ដេចជាអំណាចស្របគ្នានឹងអំណាចរបស់គេ ផ្ទុយទៅវិញ នៅពេលណាមានកើតវិវាទកម្មរវាងអាជ្ញាធរបារាំងនឹងអាជ្ញាធរស្ដេចខ្មែរ បារាំងជាអ្នកបកស្រាយរកហេតុផលថាតើអ្នកណាជាអ្នកយល់ខុស អ្នកណាជាអ្នកយល់ត្រូវ **ភាពប្រសើរជាង**[177] របស់អំណាចបារាំងនេះហើយ ដែលបារាំងគេទុកអំណាចគេនិងអំណាចស្ដេចខ្មែរជាអំណាចដាក់តម្រួតគ្នា អំណាចណាមួយឋិតនៅពីលើ ឬឋិតនៅពីក្រោម គឺវាឋិតនៅលើការបកស្រាយរបស់បារាំង ឧទាហរណ៍ដូចយ៉ាងបារាំងកាត់ទឹកដីកម្ពុជាក្រោមពីស្រុកខ្មែរបញ្ចូលទៅក្នុងស្រុកយួន ។ល។ ភាពប្រសើរជាងនៃអំណាចបារាំងលើអំណាចស្ដេច មិនមានន័យថាបារាំង គេទុកជាមោឃៈ ឬលុបចោលអំណាចស្ដេចនៅពេលមានកើតវិវាទនោះទេ បារាំងគេគ្រាន់តែព្យួរអំណាចស្ដេចតែប៉ុណ្ណោះ។

អវត្តមាននៃអំណាចនីតិបញ្ញតិនៅក្នុសសម័យអាណាព្យាបាលបារាំង យើងអាចចាត់ទុកអំណាចអាជ្ញាធរបារាំង ជាអំណាចផ្ដាច់ការផងជាអំណាចចក្រពត្រផងជាសណ្ឋានបំពានដាក់ស្ដែង របស់អ្នកខ្លាំងលើអ្នកខ្សោយ ដូច្នេះអ្វីដែលបារាំងបានសម្រេចក្នុងសណ្ឋានបំពាននេះ ខ្មែរយើងនាបច្ចុប្បន្ននេះអាចចាត់ទុកវាជាមោឃៈ ព្រោះគ្មានអ្វីអាចបញ្ជាក់បានថា ជាសេចក្ដីសម្រេចជាស្ថាពរនោះឡើយចំពោះមុខច្បាប់ជាតិនិងអន្តរជាតិ។

---

177 ភាពប្រសើរជាង= Primauté។

គួរកត់សំគាល់ដែរថា បេសកកម្មអារ្យធម៌របស់បារាំងនៅស្រុកខ្មែរមានការទង្គិចជាក់ស្តែងនឹងអត្ថិភាព នៃអារ្យធម៌អង្គររបស់ខ្មែរដែលតម្រូវឲបារាំងទទួលស្គាល់ថាជាតិសាសន៍ខ្មែរជា ជាតិសាសន៍មួយមានអារ្យធម៌ខ្ពង់ខ្ពស់រួចស្រេចទៅហើយ ឥតចាំបាច់យកអារ្យធម៌បារាំង ឬ បស្ចិមប្រទេស មកធ្វើជាគំរូសំរាប់ធ្វើការអភិវឌ្ឍន៍សង្គមខ្មែរនោះឡើយ ម្យ៉ាងមួយទៀត បេសកកម្មនវូបនីយកម្មរដ្ឋបាលខ្មែររបស់បារាំងមានកំរិតត្រឹមតែយក **ការរៀបចំ** ផ្នែកបច្ចេកទេសដើម្បីសម្រួល **សារពើច័ក្រ**[178] រដ្ឋបាលអាជ្ញាធរបារាំងសំរាប់ងាយស្រួលត្រួតត្រារដ្ឋបាលខ្មែរតែប៉ុណ្ណោះ តែបារាំងមិនបានយកគោលការណ៍លិទ្ធិប្រជាធិបតេយ្យមកធ្វើជាមូលដ្ឋានក្នុងច្បាប់ដឹកនាំជាតិខ្មែរនោះឡើយ មែនទែនទៅយើងអាចចាត់ទុកបានថារយៈពេល៩០ឆ្នាំ នៃអាណាព្យាលបារាំងនៅស្រុកខ្មែរគ្រាន់តែជារយៈពេលព្យួរចោលមួយនូវ **អភិក្រម**[179] នៃអត្តង្គតប្រទេសខ្មែរ ដែលខុសពីបំណងខ្មែរចង់ឲបេសកកម្ម របស់អាណាព្យាបាលបារាំងមានលក្ខណៈជាថ្នាំសំរាប់ដាក់ឲជារោគអត្តង្គតខ្មែរអស់ច្រើនសតវត្សរួចមកហើយ។ បើខ្មែរយើងមានការខកចិត្តលើអាណាព្យាបាលបារាំង គឺក្នុងចំណុចភាពមិនស័ក្តិសិទ្ធិនេះឯង។

អំណាចអាជ្ញាធរអាណាព្យាបាលបារាំង នៅស្រុកខ្មែរមិនត្រឹមតែមានភាពមិនស័ក្តិសិទ្ធិក្នុងការនាំប្រជាជាតិខ្មែរទៅរកភាពចំរើនលូតលាស់ឲទាន់សម័យ ផ្ទុយទៅវិញ អំណាចនេះនាំមកថែមនូវអំណាចថ្មីមួយសំរាប់ការពារអំណាចហួសសម័យរបស់ស្តេចខ្មែរ និងអំណាចអាណានិគមនិយម ដែលជាអំណាចសំរាប់សង្កត់សង្កិនប្រជារាស្ត្រខ្មែរឲរស់បន្តក្នុង **អន្ធការនិយម**[180] ដែលជារូបភាពមួយផ្ទុយស្រឡះពីការយល់ឃើញ របស់ជនជាតិបារាំងមួយចំនួនដែលបានមកត្រួតត្រាប្រទេសខ្មែរថា ប្រជារាស្ត្រខ្មែរជាម្ចាស់ទឹកដីខ្លួន រស់ក្នុងភាពក្រលំបាក តែដោយសារពុទ្ធសាសនាអាចរស់ប្រកបដោយ **សមតា**[181] ដែលជា «សិល្បៈនៃការរស់នៅ» មួយពិត

---

178 សារពើច័ក្រ= Rouage។
179 អភិក្រម= Processus។
180 អន្ធការនិយម= ភាពល្ងង់ខ្លៅ ; Obscurantisme។
181 សមតា= Equilibre។

ប្រកដ។ តែខ្មែរយើងត្រូវដឹងថា សិល្បៈនៃការរស់នៅ «**ដែលនៅក្រោម**[182] ភាពក្រលំបាករាល់ថ្ងៃជាមហាទុក្ខរបស់ប្រជារាស្ត្រខ្មែរ មិនមែនជាសមតានោះឡើយ។ អ្វីទៅ ដែលជាសេចក្ដីថ្លៃថ្នូរ របស់ខ្មែរម្នាក់ៗ នៅក្នុងភាពក្រលំបាកជាអចិន្ត្រៃយ ដែលជាអនាគតតែមួយគត់របស់ខ្លួន ?

## ៤. អំណាចរបស់អាជ្ញាធរអាណាព្យាបាលបារាំងនៅស្រុកខ្មែរក្នុងរយៈពេល និងក្រោយសង្គ្រាមលោកលើកទី២

បន្ទាប់កងទ័ពអាឡឺម៉ង់វាយចូលលុកលុយប្រទេសប៉ូឡូញនាថ្ងៃទី១កញ្ញាឆ្នាំ១៩៣៩ ដោយគ្មានការប្រកាសសង្គ្រាមជាមុន ប្រទេសអង់គ្លេស និងប្រទេសបារាំងបានប្រកាសសង្គ្រាមនឹងប្រទេសអាឡឺម៉ាញ។ ថ្ងៃទី៧កញ្ញា កងទ័ពបារាំងបានធ្វើការវាយប្រហារយ៉ាងស្មើយកងទ័ពអាឡឺម៉ង់ ដោយប្រើកងអង្គទ័ពពីរមានចំនួន៩កងពលធំ វាយចេញពីដំបន់ Sarre ចូលទៅក្នុងដីអាឡឺម៉ាញចម្ងាយ១០គីឡូម៉ែត្រក្នុងរយៈពេល១០ថ្ងៃ។ របៀបរៀបចំជាកងឯកភាពពលធំរបស់កងទ័ពបារាំងមិនអាចមានលទ្ធភាពអាចវាយលុកយ៉ាងខ្លាំងទៅលើកងទ័ពអាឡឺម៉ង់ ដោយខ្វះ**មធ្យោបាយភស្តុភារ**[183] សំរាប់គាំពារកងទ័ព ដោយហេតុនេះក្នុងរយៈពេលតែ៥សប្ដាហ កងទ័ពអាឡឺម៉ង់វាយយ៉ាងរហ័សចូលប្រទេសបារាំងធ្វើឲបែកខ្ញែកកងទ័ពបារាំង ហើយនាំឲប្រជាពលរដ្ឋបារាំងមានអហេតុភ័យនាំគ្នារត់ចេញពីដំបន់សង្គ្រាម មានចំនួនប្រមាណ១០លាននាក់ ដែលគេឲឈ្មោះថា «**អពាយព**»[184] ក្នុងស្ថានភាពបែបនេះ លោកសេនាប្រមុខប៉េតាំង(Pétain) ជានាយករដ្ឋមន្ត្រីបានធ្វើការសម្រេចចិត្តសូមយុទ្ធសន្តិភាពពីសំណាក់ប្រទេសអាឡឺម៉ាញ ហើសយុទ្ធសន្តិភាពនេះបានចុះហត្ថលេខា រវាងប្រទេសបារាំងនិងអាឡឺម៉ាញនៅថ្ងៃទី២២មិថុនាឆ្នាំ១៩៤០។ កងទ័ពអាឡាម៉ង់បែងចែកប្រទេសបារាំងជាពីរដំបន់ ដំបន់កាន់កាប់ដោយកងទ័ពអាឡឺម៉ង់ មានទីក្រុងបារីសជាទីស្តីការអគ្គមេបញ្ញាការអាជ្ញាធ

---

182 ដែលនៅក្រោម= Sous-jacent។
183 មធ្យោបាយភស្តុភារ= Moyen logistique។
184 អពាយព= ការចេញចោលទីកន្លែងដែលធ្លាប់រស់នៅ នៃប្រជាជន ឬ ក្រុមមនុស្ស ; Exode។

រអាឡឺម៉ង់ និងដំបន់ត្រួតត្រាដោយបារាំង មានទីក្រុង Vichy ជាទីស្នាក់ការរដ្ឋាភិបាលបារាំង។

យុទ្ធសន្តិភាពនេះត្រូវលោកឧត្តមសេនីយ Charles de Gaulle អតីតអនុរដ្ឋលេខាធិការក្រសួងការពារជាតិចេញមុខប្រឆាំង ហើយធ្វើការអំពាវនាវពីប្រទេសអង់គ្លេសនៅថ្ងៃទី១៨មិថុនា ឲប្រជាពលរដ្ឋបារាំងដើបប្រឆាំងការកាន់កាប់កងទ័ពអាឡឺម៉ង់ និងរដ្ឋាភិបាលលោក Pétain ហើយឲនាំគ្នារត់ចេញពីស្រុកមកប្រទេសអង់គ្លេសស្ម័កចិត្តចូលបំរើកងទ័ពបារាំងសេរីដែលមានលោកជាប្រមុខ។

ឯចំណែកនៅស្រុកខ្មែរវិញ អាជ្ញាធរអាណាព្យាបាលបារាំង បានគាំទ្រ រដ្ឋាភិបាល Pétain ប្រឆាំងនឹងពួកសម្ពន្ធមិត្តដែលជាសត្រូវនឹងប្រទេសអាឡឺម៉ាញហ្វាសីស ដែលមាន Hitler ជាអ្នកដឹកនាំ។ ក្នុងឆ្នាំ១៩៤១ ក្រោយពីស្ដេច មនីវង្សសោយទីវង្គត លោកឧត្តនាវី Decoux អភិបាលនាយក បារាំង នៅឥណ្ឌូចិនបានជ្រើសរើសព្រះអង្គម្ចាស់ នរោត្តម សីហនុ មានអាយុ១៨ វស្សាបន្តរាជ្យពីជីតា ដែលគ្មាននរណាមួយនឹកស្មានទុកជាមុនសោះនោះឡើយ ព្រោះខ្មែរគ្រប់គ្នាជឿក្នុងចិត្តថាអ្នកដែលស្នងរាជ្យគឺព្រះអង្គម្ចាស់មនីរេត ដែលជាបុត្រាស្ដេចមនីវង្ស។

ចាប់ផ្ដើមសង្គ្រាមលោកលើកទី២ អំណាចអាជ្ញាធរបារាំងនៅស្រុកខ្មែរមាន **ស្ថានភាពចាស់**[185] ដែលមានតាំងពីឆ្នាំ១៨៩៧ (កិច្ចព្រមព្រៀងចុះនីថ្ងៃទី១១កក្កដា)[186] មក ដូច្នេះអំណាចព្រះរាជាខ្មែរគ្រាន់ជាឡប់ឡែរបស់អំណាចបារាំងសំរាប់ទុកជា **មាយាការ**[187] ដល់ប្រជារាស្ត្រខ្មែរ ដែលមិនបានយកចិត្តទុកដាក់អំពីការទំនាក់ទំនងជាគតយុត្តរវាងខ្មែរបារាំង តែប៉ុណ្ណោះ។ នៅថ្ងៃទី២៤កញ្ញាឆ្នាំ១៩១៩ អាជ្ញាធរបារាំងប្រកាសបញ្ញាតិ[188] ដែលគេអាចទុកជាបញ្ញាតិដ៏សំខាន់មួយស្ដីអំពីការរៀបចំក្នុងវិស័យរដ្ឋបាលឃុំ បន្ទាប់មកនៅក្នុងឆ្នាំ១៩២២ បញ្ញាតិពីរត្រូវបាន

---

185 ស្ថានភាពចាស់= statuquo។

186 កិច្ចព្រមព្រៀងចុះនីថ្ងៃទី១១កក្កដា= ព្រះរាជាអាចសម្រេចអ្វីមួយបាន លុះត្រាមានការអនុញ្ញាតពីអាជ្ញាធរបារាំងជាមុន។

187 មាយាការ= សេចក្ដីបំភាន់ចិត្ត ; Illusion។

188 បញ្ញាតិ= Ordonnance។

បារាំងប្រកាសឲរដ្ឋបាលខ្មែរយកមកអនុវត្ត ដែលគេអាចចាត់ទុកវាជា**គ្រោង**[189] នៃអង្គការនយោបាយ និងរដ្ឋបាលខ្មែរ ដែលមានបែងចែងច្បាស់លាស់ អំពីព្រំដែនខែត្រ និងស្រុកដែលជាអាទ៍នៃរូបភាពទំនើបថ្មីមួយនូវរចនាសម្ព័ន្ធរបស់រដ្ឋខ្មែរ។ សារាចរក្នុងឆ្នាំ១៩៣៦ក្នុងគោលដៅធ្វើ **វិមជ្ឈការ**[190]រដ្ឋបាលខ្មែរ ប្រគល់សិទ្ធិឲអាជ្ញាធរខ្មែរប្រចាំខែត្រ មានអំណាចសម្រេចកិច្ចការដែលទាក់ទងនឹងខែត្ររបស់ខ្លួន តែនិន្នាការគួរឲចាប់អារម្មណនេះត្រូវបានបញ្ឈប់នៅពេលដែលសង្រ្គាមលោកលើកទី២បានផ្ទុះឡើង[191]។

គួរកត់សំគាល់ដែរថាអាជ្ញាធរអាណាព្យាបាលបារាំងបានបង្កើតឲមាន**ស្ថាប័នតំណាងរាស្រ្ត** ថ្នាក់ឃុំ ថ្នាក់ខែត្រ និងសភាជាតិៈ

១.ទីប្រឹក្សាឃុំ(ឃុំមានប្រជាពលរដ្ឋរស់នៅចាប់ពី២០០០ដល់១០.០០០នាក់)រាជបញ្ញតិក្នុងឆ្នាំ១៩១៩ ប្រកាសថា អ្នកស្រុកគ្រប់សញ្ញាតិ ដែលមានអាយុចាប់ពី២១ឆ្នាំទៅ អាចមានសទ្ធិបោះឆ្នោតជ្រើសរើសទីប្រឹក្សាឃុំ និងឈរជាបេក្ខជន ក្នុងល័ក្ខណ្ឌដែលអ្នកស្រុកនោះមានឈ្មោះក្នុងបញ្ជីពន្ធបុគ្គល និង ពន្ធខ្លួន[192] អាណត្តិទីប្រឹក្សាឃុំមានកំរិត៤ឆ្នាំ។ ក្នុងឆ្នាំ១៩៤៣ អាជ្ញាធរបារាំងផ្អាកការបោះឆ្នោតទីប្រឹក្សាឃុំ។

២.ទីប្រឹក្សា **និវេសដ្ឋាន**[193] សំរាប់ខែត្រ ; ១០ឃុំមានតំណាងទីប្រឹក្សាម្នាក់ជ្រើសរើសឡើងដោយអាជ្ញាធរបារាំងមួយចំនួន បណ្តាជនខ្មែរឬជនដែលបារាំងគេទុកដូចជាខ្មែរ និងមួយចំនួនទៀតជ្រើរើសតាមការបោះឆ្នោតដោយ **សហសេវិក**[194] ដាក់កម្រិត ចៅហ្វាយខែត្រ និងចៅហ្វាយសង្កាត់ចាត់ទុកជា **សិទ្ធិសមាជិក**[195] ទីប្រឹក្សានិវេសដ្ឋាន មានតួនាទីត្រឹមតែ ឲយោបលដល់អ្នកប្រចាំការបារាំងក្នុងវិស័យការ

---

189 គ្រោង= Armature។
190 វិមជ្ឈការ= Décentralisation។
191 Essai sur la démocratie au Cambodge – Octobre 1961 de Philippe PRESCHEZ។
192 ពន្ធខ្លួន= capitation។
193 និវេសដ្ឋាន= résidence។
194 សហសេវិក= collège។
195 សិទ្ធិសមាជិក= Membre de droit។

រៀបចំថវិការខែត្រ និងសាធារណការ តែប៉ុណ្ណោះ។ ទីប្រឹក្សានេះបានបង្កើតឡើងក្នុងឆ្នាំ១៩០៣ ហើយបញ្ចប់សកម្មភាពរាយរង និងតាមចំណង់ចិត្តអាជ្ញាធរបារាំង ក្នុងឆ្នាំ១៩៤០។

៣.ក្នុងឆ្នាំ១៩១២ អគ្គអភិបាលឥណ្ឌូចិន លោក Albert Sarraut បានបង្កើត**សភាផ្តល់យោបល់នៃជនជាតិដើម**[196] ជ្រើសតាំងសមាជិកឡើងតាម **វិធីបោះឆ្នោតដាក់កម្រិត**[197] ក្នុងរយៈបីឆ្នាំម្តង។ ក្នុងបំណងនេះ អាជ្ញាធរបារាំងបានអនុញ្ញាតិឲបង្កើតសភាផ្តល់យោបលខ្មែរនៅក្នុងឆ្នាំ១៩១៣ ដែលមានសមាជិក៣នាក់ជ្រើសរើសឡើងតាមការបោះឆ្នោតពីសហសេវិកនៃទីប្រឹក្សានិវេសដ្ឋាន អ្នករាជការ ឬអតីតអ្នករាជការ និងអ្នកមានសញ្ញាប័ត្រ សមាជិកមួយចំនួនទៀតត្រូវបានតែងតាំងឡើងដោយគណរដ្ឋមន្ត្រីក្នុងមួយឆ្នាំម្តង ចំនួនតែងតាំងមិនត្រូវលើស១ភាគ៨ នៃចំនួនសមាជិកជាប់ឆ្នោត។ សភានេះមានអំណាចស្តួចស្តើង ណាស់ អាជ្ញាធរបារាំងគេជាអ្នកសម្រេចថាត្រូវកោះប្រជុំដើម្បីសួរយោបលហើយគេហាមឃាត់ដាច់ខាតមិនឲស្នើបំណងអ្វីមួយនោះឡើយ ក្រៅពីពិនិត្យរបៀបវារៈដែលព្រះរាជា និង អ្នកប្រចាំការជាន់ខ្ពស់បារាំងនៅស្រុកខ្មែរគេដាក់ឲពិនិត្យតែប៉ុណ្ណោះ។ នៅថ្ងៃទី១០មេសាឆ្នាំ១៩៤០ សភានេះត្រូវបានអាជ្ញាធរបារាំងគេរំលាយចោល ហើយបង្កើត **សភាអ្នកតំណាងប្រជាពលរដ្ឋខ្មែរ**[198] ជំនួសវិញ។ តាមពិតសភាថ្មីនេះមានអត្ថិភាពនៅលើតែក្រដាស ព្រោះព្រឹត្តិការណ៍សង្គ្រាមលោកលើកទី២ធ្វើឲអាក់ខានមិនអាចនឹងកោះប្រជុំដើម្បីសួរយោបលបាន។

ជប៉ុនដែលមានទីតាំងទ័ពនៅឥណ្ឌូចិនតាមកិច្ចព្រមព្រៀងរដ្ឋាភិបាល លោក Pétain និង រាជរដ្ឋាភិបាលជប៉ុនចុះថ្ងៃទី៣០សីហា១៩៤០ អនុញ្ញាតិឲកងទ័ពជប៉ុនប្រើសប្រាសទឹកដីឥណ្ឌូចិនធ្វើសង្គ្រាមនឹងកងទ័ពសម្ពន្ធមិត្តនៅអាស៊ី នៅថ្ងៃទី៩មិនាឆ្នាំ១៩៤៥ កងទ័ពជប៉ុនបានឡោមព័ទ្ធចាប់បារាំងទាំងអស់នៅឥណ្ឌូចិន។នៅស្រុកខ្មែរកងទ័ពជប៉ុនដេញចាប់បារាំងគ្រប់ទីកន្លែង ជាពិសេសនៅភ្នំពេ

196 សភាផ្តល់យោបល់នៃជនជាតិដើម= Assemblée Consultative Indigène។
197 វិធីបោះឆ្នោតដាក់កម្រិត= Mode de scrutin restreint។
198 សភាអ្នកតំណាងប្រជាពលរដ្ឋខ្មែរ= Chambre des Représentants du Peuple du Cambodge។

ញ។នៅថ្ងៃទី១២មិនា១៩៤៥កងទ័ពជប៉ុនបានអនុញ្ញាតិឲស្តេចសីហនុប្រកាសឯករាជ្យ ដូច្នេះថ្ងៃទី១២មិនានេះ ខ្មែរយើងអាចចាត់ទុកជាថ្ងៃបញ្ចប់បេសកកម្មអាណាព្យាបាលបារាំងជាផ្លូវការនៅស្រុកខ្មែរ ព្រោះស្តេចខ្មែរមាននីតិសម្បទានគ្រប់គ្រាន់ក្នុងឋានៈព្រះអង្គជាអធិបតី នៃប្រជាពលរដ្ឋខ្មែរអាចលុបចោលកិច្ចព្រមព្រៀងទាំងឡាយជាមួយប្រទេសបារាំងដោយមិនបាច់មានការព្រមព្រៀងជាមុនពីបារាំងនោះទេ។ តាមគិតយុត្ត ថ្ងៃទី១២មិនា១៩៤៥ ជាទិវានៃឯករាជ្យពិតប្រាកដមួយរបស់ប្រទេសនិងប្រជាពលរដ្ឋខ្មែរ ដែលមានមហាក្សត្យខ្មែរ នរោត្តមសីហនុ ជាអ្នកប្រកាសជាឧឡារិកនៅចំពោះប្រជារាស្ត្រខ្មែរ តែឯករាជ្យនេះត្រូវបារាំងបំពាននៅក្រោយសង្គ្រាមលោកលើកទី២ ចាប់អ្នកស្នេហាជាតិខ្មែរមួយចំនួន ជាពិសេសលោកស៊ឹងង៉ុកថាន់យកទៅប្រទេសបារាំង ដោយចោទប្រកាន់លោកថាធ្វើសហការជាមួយជប៉ុន ឯចំណែកស្តេចសីហនុត្រូវរដ្ឋអំណាចបារាំងថ្មី ដែលមានលោក de Gaulle ជាប្រមុខយល់ព្រមឲសោយរាជ្យសម្បត្តិបន្តទៅទៀតទោះបីព្រះអង្គជាអ្នកប្រកាសឯករាជ្យស្រុកខ្មែរពីបារាំង និងអាជ្ញាធរបារាំង Vichyជាអ្នកប្រគល់រាជបល្ល័ង្កថ្វាយព្រះអង្គក៏ដោយ។ វិធានការបារាំងបែបនេះបង្ហាញថាបារាំងគេជ្រើសរើសយក **ស្ថានភាពចាស់** មកអនុវត្តិនៅស្រុកខ្មែរវិញដដែល។ ការយកស្ថានភាពចាស់មកអនុវត្តិនៅឥណ្ឌូចិននេះឯងដែលនាំឲមានកើតចលនារំដោះជាតិនៅវៀតណាមក្តី នៅកម្ពុជាក្តី នៅឡាវក្តីប្រឆាំងនឹងអំណាចបារាំង ដែលអ្នកស្នេហាជាតិក្នុងជំនាន់នោះទុកជាអំណាចចក្រពត្រនិយម។

ទំនាក់ទំនងជាមួយបារាំងអស់រយៈជិតមួយសតវត្ស មិនបានបញ្ចប់លទ្ធិផ្តាច់ការនិយមនៅស្រុកខ្មែរនោះឡើយ តែលទ្ធិផ្តាច់ការនេះលាក់ខ្លួនក្នុងសង្គម **និច្ចលនិយម**[199]មួយ បង្ហាញស្រមោលខ្លួនជាសុខមាលភាពប្រកបទៅដោយភាពស្ងប់ស្ងាត់ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋដែលមានជំនឿដាច់ខាតថាអត្ថិភាពរបស់ខ្លួនក្នុងទុក្ខវេទនាក្តី ក្នុងសុភមង្គលក្តី ជាបុណ្យបាប ដែលខ្លួនបានទទួលពីអំពើដែលខ្លួនបានធ្វើពីជាតិមុន ដូច្នេះអតីតកាល និង អានាគតកាលរបស់ប្រជា

[199] និច្ចលនិយម= immobilisme។

ពលរដ្ឋខ្មែរ  ជាជីវិតតែមួយគត់រស់សំរាប់តែបំរើអំណាចអ្នកដឹកនាំក្នុងផ្នត់គំនិតនៃការគោរពប្រពៃណីផ្តាប់មុខ  ដែលអ្នកដឹកនាំគេបង្កើតឡើងសំរាប់តែបំរើផលប្រយោជន៏របស់គេ   ដូចយ៉ាងបារាំងគេរក្សាអំណាចប្រពៃណីស្តេចខ្មែរដើម្បីងាយស្រួលក្នុងការត្រួតត្រាប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ។

# សេចក្តីសន្និដ្ឋាន

អំណាចនៅស្រុកខ្មែរតាំងពីសម័យដើម រហូតមកដល់សម័យបញ្ចប់សង្គ្រាមលោកលើកទី២ គ្មានមានការលូតលាស់សំរាប់ជាមូលដ្ឋាននៃភាពចម្រើននៃសេរីភាពប្រជាពលរដ្ឋ។ ស្តេចខ្មែរជំនាន់ដើម និងអាជ្ញាធរអាណាព្យាបាលបារាំងនៅស្រុកខ្មែរតែងតែអប់រំប្រជាពលរដ្ឋខ្មែរឲយល់ច្រឡំអំពី **វឌ្ឍនភាព** ជាមួយនិងសេរីភាព ឧទាហរណ៏ដូចខ្មែរយើងតែងទុកឬយល់ឃើញថាសម័យរុងរឿងអង្គរជាសម័យមួយដែលប្រជារាស្ត្រខ្មែរមានសេរីភាព សម័យដែលបារាំងគេនាំចំណេះវិទ្យាសាស្ត្រចូលមកក្នុងស្រុកខ្មែរថា រាស្ត្រខ្មែរមានសេរីភាព ហ៊ុនសែន និយាយថា ស្រុកខ្មែរមានវឌ្ឍនភាព ហើយគាត់ធ្វើអនុមានជា **វិចិន្ដា**[200] ថារាស្ត្រខ្មែរមានសេរីភាពដូចស្តេចសីហនុអន្ទងថា វឌ្ឍនភាពក្នុងសម័យសង្គមរាស្ត្រនិយម ជាសម័យដែលរាស្ត្រខ្មែរមានសេរីភាព។ វឌ្ឍនភាពដែលធ្លាប់មាននៅក្នុងស្រុកខ្មែរគ្រប់វស្សកាលជាវឌ្ឍនភាពមិនមែន ជាអំពើកើតចេញមកពីសេរីភាព របស់ប្រជាពលរដ្ឋដែលជាអ្នកស្គាល់ **ល្បត់**[201] នៃប្រជាជាតិខ្លួនប្រើសេរីភាពដើម្បីធ្វើឲមានវឌ្ឍនភាពក្នុងសង្គម ផ្ទុយទៅវិញវឌ្ឍនភាពទាំងឡាយនោះ ដែលអ្នកកាន់អំណាចគេជាអ្នកបង្កើត សំរាប់ប្រើជាអាវុធសំរាប់បំបាត់សេរីភាពប្រជាពលរដ្ឋឲខំរស់សំរាប់បំរើអំណាចតែប៉ុណ្ណោះ។ នៅស្រុកខ្មែរអំណាចជាបញ្ហាសំរាប់សង្គម អ្នកកាន់អំណាចមានវិធានការគ្រប់បែបយ៉ាង ដើម្បីរក្សាអំណាច ព្រោះវាជាលាភឬបុណ្យនៃការចិញ្ចឹមជីវិតរបស់ខ្លួន ក្នុងគំនិតនេះធ្វើឲខ្លួនក្លាយទៅជា**លុទ្ធបុគ្គល**)[202] ឯចំណែករាស្ត្រទុកអំណាចរបស់អ្នកនាំជាបន្ទុកដ៏ធំឬ **ឧបបីឡកកម្ម**[203] នៃការចិញ្ចឹមជីវិតរបស់ខ្លួន ក្នុងគំនិតនេះធ្វើឲខ្លួនក្លាយជា **អ្នកជតានិយម**[204] រស់នៅក្នុងសង្គម

---

200 វិចិន្ដា= សេចក្ដីរវើរវាយ។
201 ល្បត់=កំណត់ឬកម្រិតវត្ថុអ្វីមួយ កំណត់ដែលលត់លោហជាតិមានដែកជាដើម។
202 លុទ្ធបុគ្គល=មនុស្សលោភ អ្នកដែលចង់បានតែប្រយោជន៏ផ្ទាល់ខ្លួន។
203 ឧបបីឡកកម្ម=អកុសលកម្មពីព្រេងនាយដែលជាប់តាមមកផ្តល់បៀតបៀនឲនោមនូវសេចក្តីទុកលំបាក។
204 អ្នកជតានិយម= fataliste។

គ្មានអានាគតធ្វើការងារធូនធ្ងរ សំរាប់តែក្រពះរួញស្វិតឥតអាចបង្កើតសារជាតិសំរាប់ចិញ្ចឹមប្រាជ្ញាបាន។ គំនិតខ្មែរ"កម្មនិងបុណ្យ"ជាគំនិតរបស់អ្នកដឹកនាំគេចិញ្ចឹមវាឲរស់ជានិច្ចក្នុងសង្គមខ្មែរព្រោះវាជាមធ្យោបាយសំរាប់ចិញ្ចឹមអំណាចដែលគេទុកជាលិខិតអនុញ្ញាតសំរាប់រកប្រយោជន៏គ្រប់បែបយ៉ាង។ នៅស្រុកខ្មែរពាក្យអំណាចជាវេចនសព្ទនឹងពាក្យសោយ ឬស៊ីសម្បត្តិ មានអំណាចគឺមានសម្បត្តិសំរាប់ស៊ី ដូចគេថាស្ដេចសោយរាជ្យសម្បត្តិ ឯអស់លោកមន្ត្រីមានចំណែកតាមឋានៈស័ក្តិដែលស្ដេចចែកអោយ ខ្មែរយើងតែងនិយាយថា **«ធំស៊ីតាមធំតូចស៊ីតាមតូច»** រីឯរាស្ត្រស៊ីផលជាអប្បបរិមាណដែលកើតចេញពីញើសរបស់ខ្លួន។ ក្នុងសង្គមខ្មែរមានមនុស្សពីរក្រុម មួយក្រុមតូចបំផុតរស់នៅក្នុងភាព **អកម្មិក**[205] មួយក្រុមទៀតមានភាគច្រើនបំផុតរស់ក្នុងភាពជាពលកម្មធ្វើការសំរាប់រស់ត្រដាបត្រដួសផង និង បង់ពន្ធឲអ្នកកាន់អំណាច ដោយគ្មានបានទទួលការបន្ទុកបម្រុង មកវិញ ដើម្បីសុខុមាលភាព ពីសំណាក់អ្នកកាន់អំណាចនោះទេ។

ធាតុអំណាចនៅស្រុកខ្មែរជាធាតុចង្រៃបំផុតសំរាប់សង្គមខ្មែរ យើងសួរថាតើថ្ងៃណាទើបខ្មែរយើងនាំគ្នាដូរធាតុចង្រៃនេះចោលបាន?អ្នកដឹកនាំគ្រប់សម័យតាំងពីស្រុកខ្មែរបានឯករាជ្យ មកក្នុងកំឡុងឆ្នាំ១៩៥៣ តែងតែមានគំនិតកែ របបនយោបាយផ្ដាច់ការឲក្លាយជារបបលទ្ធិប្រជាធិបតេយ្យ តែបំណងចង់កែនេះមានតែក្នុងសំដី សូមឲរាស្ត្រដូរចិត្តគំនិត តែខ្លួនឯងវិញឥតមានដូរមួយសរសៃសក់ឡើយ បើសូមឲរាស្ត្រកែ តែត្រូវទុកខ្លួនឲនៅពីលើរាស្ត្រជានិច្ច មិនដែលទុករាស្ត្រជាជនាធិបតី យកលទ្ធិប្រជាធិបតេយ្យមកបាំងដើម្បីគ្រាន់តែសំរាប់ឲអំណាចផ្ដាច់ការខ្លួនមានជម្មានុរូប តែប៉ុណ្ណោះ ដូចសព្វថ្ងៃហ៊ុនសែនរៀបចំការបោះឆ្នោតយកពាក្យលទ្ធិប្រជាធិបតេយ្យ ជាសម្លេង តែយកកំបិត សំរាប់សម្លុតរាស្ត្រនិងអ្នកប្រឆាំងខ្លួន ដើម្បីអ្វី ? គឺដើម្បីរក្សាអំណាចផ្ដាច់ការនោះឯង៕

**ចប់**

---

205 អកម្មិក= oisiveté។